ហ៊ុន សែន

# បទអន្តរាគមន៍ និង សេចក្តីអធិប្បាយ
# ស្តីពី
# «ការទារបោះបង្គោលខណ្ឌសីមាព្រំដែនគោក និង ការកំណត់ព្រំដែនសមុទ្រ រវាង ព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម»

សម័យប្រជុំពេញអង្គរដ្ឋសភា

ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១២



សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន ៖**
« ... ធានាឱ្យបានដាច់ខាតថា កម្ពុជានឹងមិនខាត
ឬ បាត់បង់ដី សូម្បីតែ ១ ម៉ែត្រក្រឡាក៏ដោយ ... »

# អារម្ភកថា

ក្នុងឱកាសបកស្រាយជុំវិញសំណួរ របស់សមាជិកសភាគណបក្សសមរង្ស៊ី **សុន ឆ័យ** ក្នុងកិច្ចប្រជុំពេញអង្គនៃរដ្ឋសភា ថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០១២ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បានផ្តល់នូវការពន្យល់ មានចរិតសរុបគ្រប់ជ្រុងជ្រោយ អំពីគោលនយោបាយ លទ្ធផល និងកិច្ចខិតខំប្រឹងប្រែងបន្តទៀតយ៉ាងមោះមុត និងប្តូរប្តេជ្ញ របស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហាព្រំដែនរវាងកម្ពុជា និងវៀតណាម។

ជាលើកដំបូងហើយក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា ក្រោមការដឹកនាំរបស់សម្តេចតេជោ ដែលយើងទាំងអស់គ្នាបានស្តាប់នូវបទបង្ហាញលំអិត ប្រកបដោយទស្សនៈប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងភូមិបច្ចេកទេស ដោយឥតលាក់លៀម ជាមួយជំនឿថា ព្រំដែនគោក, ហើយនៅពេលខាងមុខ, ព្រំដែនសមុទ្រនៃប្រទេសទាំងពីរ, កម្ពុជា-វៀតណាម, នឹងក្លាយទៅជាព្រំដែន សន្តិភាព មិត្តភាព និងសហប្រតិបត្តិការ យ៉ាងពិតប្រាកដ។

យោងលើសារសំខាន់ដូចនេះ ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី បានទទួលការអនុញ្ញាតឱ្យចងក្រង និងបោះពុម្ព អមជាមួយសៀវភៅ «**អត្ថបទគោល របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន សម្រាប់អធិប្បាយ និងផ្តល់ការបំភ្លឺ ស្តីពី ការបោះបង្គោលខណ្ឌសីមាព្រំដែនគោក និងការកំណត់ព្រំដែនសមុទ្រ រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម**» ក្នុងសម័យ

ប្រជុំពេញអង្គរដ្ឋសភា ដែលបានចេញផ្សាយរួចហើយ នូវបទអន្តរាគមន៍ រួមជាមួយការដកស្រង់សេចក្តីអធិប្បាយ ដើម្បីជាមូលដ្ឋានដ៏សំខាន់ មួយទៀត សម្រាប់ប្រើប្រាស់ ក្នុងការស្វែងយល់ ពិគ្រោះ ព្រមទាំង សំអាងបាន គ្រប់ពេល ទប់ទល់នឹងការបកស្រាយគ្មានមូលដ្ឋាន និងកេងចំណេញនយោបាយ អំពីការដោះស្រាយបញ្ហាព្រំដែនរវាង កម្ពុជា និងវៀតណាម ដោយមជ្ឈដ្ឋានអគតិទាំងឡាយ។

សូមជំរាបថា ខ្លឹមសារអន្តរាគមន៍ ត្រូវបានរៀបរៀងដោយប្រើពុម្ពអក្សរ Khmer OS Content ទំហំ ១២ និងខ្លឹមសារការដកស្រង់សេចក្តី អធិប្បាយ ត្រូវបានរៀបរៀងដោយប្រើពុម្ពអក្សរ Khmer OS Metal Chrieng ទំហំ ១២ ដែរ។

ភ្នំពេញ ថ្ងៃទី ០៩ សីហា ឆ្នាំ ២០១២

ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# មាតិកា

សេចក្ដីផ្ដើម បទអន្ដរាគមន៍ និងការអធិប្បាយ
១ អំពី ព្រំដែនគោក ............................................ ២៤
ទិដ្ឋភាពទូទៅ ............................................ ២៥
ទិដ្ឋភាពច្បាប់ និងប្រវត្តិសាស្រ្ត ............................................ ២៧
ការបន្ដដោះស្រាយបញ្ហាព្រំដែនគោកជាមួយវៀតណាមដោយ
រាជរដ្ឋាភិបាល ............................................ ៤៤
២ អំពី ព្រំដែនសមុទ្រ ............................................ ៧៣
អំពី កោះត្រល់ ............................................ ៧៩
អំពី កោះវៃ ............................................ ៨៤
៣ អំពីសំណួររបស់ឯកឧត្តម សុន ច័យ ............ ៨៨
សំណួរទី ១ ............................................ ៨៩
សំណួរទី ២ ............................................ ៩៨
សំណួរទី ៣ ............................................ ១០១
សំណួរទី ៤ ............................................ ១០៨
បញ្ជីឧបសម្ព័ន្ធ (ផែនទីនិងឯកសារ ដែលបានបង្ហាញជូន
អង្គសភា) ............................................ ១១២

ឧបសម្ព័ន្ធ ១........................................................ ១១២
ឧបសម្ព័ន្ធ ២........................................................ ១១៥
ឧបសម្ព័ន្ធ ៣........................................................ ១២១
ឧបសម្ព័ន្ធ ៤........................................................ ១២៣
ឧបសម្ព័ន្ធ ៥........................................................ ១២៤
ឧបសម្ព័ន្ធ ៦........................................................ ១២៥
ឧបសម្ព័ន្ធ ៧........................................................ ១២៦
ឧបសម្ព័ន្ធ ៨........................................................ ១២៨
ឧបសម្ព័ន្ធ ៩........................................................ ១៣១
ឧបសម្ព័ន្ធ ១០...................................................... ១៣២
ឧបសម្ព័ន្ធ ១១...................................................... ១៣៧
ឧបសម្ព័ន្ធ ១២...................................................... ១៤០
ឧបសម្ព័ន្ធ ១៣...................................................... ១៤៣
ឧបសម្ព័ន្ធ ១៤...................................................... ១៤៧
ឧបសម្ព័ន្ធ ១៥...................................................... ១៥១

# បទអន្តរាគមន៍ និងសេចក្តីអធិប្បាយ របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ ព្រះរាជាណាចក្រកម្ពុជា ស្តីពី "ការងារបោះបង្គោលខណ្ឌសីមាព្រំដែនគោក និង ការកំណត់ព្រំដែនសមុទ្រ រវាង ព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម"

សម័យប្រជុំពេញអង្គរដ្ឋសភា, ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០១២

*សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា*
*ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃរដ្ឋសភាដ៏ឧត្តុងឧត្តម*
*ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃរាជរដ្ឋាភិបាល*
*ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ជាទីមេត្រី !*

ថ្ងៃនេះ ខ្ញុំពិតជាមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយបានមករាយការណ៍ធ្វើបទបង្ហាញជូនដល់ អង្គរដ្ឋសភាដ៏ឧត្តុងឧត្តមនៃយើង លើបញ្ហាពាក់ព័ន្ធនិងការងារបោះបង្គោលខណ្ឌសីមាព្រំដែនគោក និង ការកំណត់ព្រំដែនសមុទ្រ រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម។

ជាបឋម ខ្ញុំសូមយកឱកាសនេះ ថ្លែងអំណរគុណចំពោះឯកឧត្តម **សុន ឆ័យ** តំណាងរាស្ត្រមណ្ឌលភ្នំពេញ នៃគណបក្សសម រង្ស៊ី រួមជាមួយនឹងតំណាងរាស្ត្រដទៃទៀត នៃគណបក្សសមរង្ស៊ី ដែលបានលើកសំណួរមកកាន់រាជរដ្ឋាភិបាល ស្តីពីបញ្ហាព្រំដែនរវាងកម្ពុជា និង វៀតណាម ដែលជាបញ្ហាដ៏មានសារសំខាន់ សម្រាប់អាយុជីវិតរបស់ជាតិទាំងមូល។

ថ្វីត្បិតតែ ជារួមសំណួរទាំងអស់នេះ មានលក្ខណៈជាការចោទប្រកាន់មកលើរាជរដ្ឋាភិបាល ក្នុងគោលបំណងញុះញង់ធ្វើឲ្យមានការភាន់ច្រឡំ នៅក្នុងចំណោមសាធារណមតិជាតិ និង អន្តរជាតិ ដើម្បីកេងចំណេញខាងនយោបាយ ក៏ប៉ុន្តែ ខ្ញុំយល់ថា ការដែលឯកឧត្តម **សុន ឆ័យ** លេងល្បែងនយោបាយ តាមរយៈយន្តការប្រជាធិបតេយ្យឆ្លងតាមស្ថាប័នរដ្ឋសភារបស់យើងនេះ វានៅតែជាប្រការដែលល្អប្រសើរជាង ការប្រព្រឹត្តិរបស់ប្រធានគណបក្សឯកឧត្តម ពោល គឺ ឯកឧត្តម **សម រង្ស៊ី** ដែលបានដើរទៅដកបង្គោលតម្រុយព្រំដែន ដោយខុសច្បាប់នោះដែរ។ ដូច្នេះ នេះគឺជាមូលហេតុដ៏សំខាន់មួយ ដែលតម្រូវឲ្យខ្ញុំមកផ្តល់ការបំភ្លឺដោយផ្ទាល់នៅចំពោះអង្គរដ្ឋសភានៃយើងនាថ្ងៃនេះ ទោះបីថា វាមិនមែនជាមូលហេតុតែមួយគត់ និង សំខាន់ជាងគេនោះក៏ដោយ។

*ខ្ញុំសូមបញ្ជាក់បន្តិច (អំពី) ពាក្យដែលថាមកឆ្លើយដោយផ្ទាល់មាត់ និងឆ្លើយជាលាយលក្ខណ៍អក្សរ។ ពាក្យដែលថាផ្ទាល់មាត់ មិនមែនបានសេចក្តីថាបិទភ្នែកហើយនិយាយនោះទេ គឺបានសេចក្តីថា មានការអានដ៏ត្រឹមត្រូវតាមបែបបទរបស់វាផងដែរ។ អ្វីដែលខ្ញុំសូមសរសើរ ឯកឧត្តម* **សុន ឆ័យ** (គឺ) *ទោះបីថាមិនពិរោះស្តាប់ ក៏ប៉ុន្តែខ្ញុំគិតថា ឯកឧត្តមបានលេងតាមវិធានប្រជាធិបតេយ្យអាស្រ័យសភា។ ឯកឧត្តម បានប្រើប្រាស់ទីកន្លែងនេះ(រដ្ឋសភា) ដើម្បីចោទសួរចំពោះ រាជរដ្ឋាភិបាល ចំពោះខ្លួនខ្ញុំជានាយករដ្ឋមន្ត្រី ឬចំពោះសមាជិកសមាជិកានៃរាជរដ្ឋាភិបាលដទៃទៀត (អំពីកិច្ចការទាំងឡាយ) ពាក់ព័ន្ធនឹងផលប្រយោជន៍*

*របស់ប្រទេសជាតិ។*

*ការដែលឯកឧត្តម លេងតាមគោលការណ៍ប្រជាធិបតេយ្យអាស្រ័យសភា វាប្រសើរជាងប្រធានរបស់ឯកឧត្តម ដែលបានបំផុសគ្នា ទៅដើរដកតម្រុយបង្គោលព្រំដែនដោយខុសច្បាប់ ហើយតាមរយៈនោះ អះអាងថា (ខ្លួន) ជាអ្នកទោសមនសិការ។ តើនោះជាទង្វើនៃជនពាលដែលលេង(ល្បែង)នយោបាយតាមចិញ្ចើមថ្នល់ ឬក៏ជាទង្វើរបស់សមាជិកសភាពិតប្រាកដ? ទោស (ពីការដកតំរុយបង្គោលព្រំដែន) មិនអាចអត់ឱនឲ្យបានទេ។ ដូចខ្ញុំបានបញ្ជាក់នៅក្នុងសភារួចហើយ កុំថាឡើយតម្រុយបង្គោលប៉ុន្មានដើមនោះ សូម្បីដើមឈើទាល ឬដើមគគីរពាប់រយដើម ក៏វាមិនថ្លៃដែរ ប៉ុន្តែ តម្លៃរបស់វាទីនេះ នៅត្រង់បញ្ហាច្បាប់នោះឯង។*

*ដូច្នេះ ខ្ញុំសូមកោតសរសើរជាថ្មីម្តងទៀតចំពោះ ឯកឧត្តម* ***សុន ឆ័យ*** *ក៏ដូចជាសហការីរបស់ខ្លួន ដែលខុសពីប្រធានរបស់ឯកឧត្តម មិនធ្វើទង្វើប្រាសចាកពីដំណើរការប្រជាធិបតេយ្យនៅក្នុងសភា។ (តាមពិតទៅ) ទោះបីខ្ញុំមកបំភ្លឺនៅទីនេះ មួយពាន់ដងមួយម៉ឺនដងទៀត ក៏គ្មានអ្នកណាអាចកែប្រែបាន នូវអ្វីដែលពួកឯកឧត្តមបានចោទប្រកាន់មកលើខ្ញុំ ក៏ដូចជា រាជរដ្ឋាភិបាល និងគណបក្សប្រជាជនបានដែរ ព្រោះវាជាការសន្និដ្ឋាន*

*ទុកជាមុនរួចស្រេចទៅហើយ។ (ខ្ញុំដឹងថាវា) គ្មានលទ្ធផលទេ (ក្នុងការដែលខ្ញុំ) នឹងផ្តល់ចម្លើយ ប៉ុន្តែខ្ញុំមានការចាំបាច់ថ្ងៃនេះ គឺមិនមែនឆ្លើយសម្រាប់តែឯកឧត្តម* **សុន ឆ័យ** *និងអ្នកតំណាងរាស្ត្ររបស់ឯកឧត្តមប៉ុណ្ណោះទេ។ ខ្ញុំមានការចាំបាច់ដើម្បីទូលប្រគេនចំពោះព្រះសង្ឃគ្រប់ព្រះអង្គ និងប្រជាពលរដ្ឋនៅទូទាំងប្រទេសដើម្បីបានជ្រាបអំពីសារបាន និងជាតុពិតនៃបញ្ហាទល់ដែនថាតើយ៉ាងដូចម្តេចខ្លះ។*

*ខ្ញុំព្រះករុណាខ្ញុំសូមយកឱកាសនេះ សុំការអធ្យាស្រ័យយោគយល់ពី ព្រះតេជគុណព្រះសង្ឃគ្រប់ព្រះអង្គ និងជនរួមជាតិ ដោយសារថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំត្រូវបង្ខំចិត្តនិយាយនូវអ្វីៗដែលជាចំណុចខ្សោយរបស់ជាតិ។ ប៉ុន្តែ បើខ្ញុំព្រះករុណាខ្ញុំមិននិយាយទេ វានឹងក្លាយទៅជាបាបកម្ម ការពិបាកទ្រាំទ្រមួយដោយសុខចិត្តឈឺចាប់ខ្លួនឯង ដោយសារថា (យើងប្រឹងប្រែង) ដើម្បីការពារផលប្រយោជន៍ជាតិ តែជនអគតិនៅតែពុំអាចយល់បាន អំពីអ្វីដែលជាតម្រូវការពិតប្រាកដរបស់ជាតិនោះ។*

*ដូចជា ករណីចំណុចខ្សោយនៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា និងបញ្ហាផ្ទៃដីរបស់កម្ពុជា ដែលវាមិនមែនស្ថិតនៅត្រឹម ១៨១ ០៣៥ គីឡូម៉ែត្រក្រឡានោះជាដើម តើត្រូវយកដីលើសពីនោះទៅណា? នេះសុទ្ធតែជាបញ្ហារសើបរបស់*

ប្រទេសជាតិ ប៉ុន្តែ ខ្ញុំព្រះករុណាខ្ញុំអត់ទ្រាំលែងកើតហើយ ហើយចាំបាច់ត្រូវទំលាយអាថ៌កំបាំងនេះ ទោះបីថា ប្រទេសជិតខាងរបស់យើង អាចយកវាធ្វើជាចំណុច(តថ្លៃបាន) ក្នុងការចរចានៅពេលក្រោយៗ សូមបញ្ជាក់ទូល និងប្រគេនព្រះសង្ឃ ក៏ដូចជាជនរួមជាតិឲ្យបានជ្រាបថា ពួកប្រឆាំង ពួកអគតិ បានតម្រូវឲ្យខ្ញុំព្រះករុណាខ្ញុំគ្លឹះកកាយយកបញ្ហាទាំងនេះ ដើម្បីឆ្លើយតបជាមួយនិងអ្វីដែលហៅថាតម្លាភាព ដែលតម្លាភាពនោះ វាបានធ្វើឲ្យមានការទន់ខ្សោយ នូវគោលជំហរមួយចំនួនរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងការចរចាព្រំដែនជាមួយនិងប្រទេសជិតខាងយើងជាបន្តទៅទៀតៗ

ការកំណត់ដោយអត្តនោម័តិរបស់ឯកឧត្តម **សុន ឆ័យ** និងសហសេរីករបស់ខ្លួន គឺពុំអាចមានអ្នកណាកែប្រែបានទេព្រោះវាបានក្លាយទៅជា ចរឹតនយោបាយដាច់ណាត់របស់ពួកប្រឆាំងរួចស្រេចទៅហើយៗ អ្វីដែលឯកឧត្តម **សុន ឆ័យ** បានលើកឡើង ហើយក៏ជាសំនួរដែលឯកឧត្តមទាំងឡាយ បានប្រជុំគ្នាកាលពីម្សិលមិញនេះ ចាប់ពីម៉ោង ៣ និង ១៥ នាទី ដល់ម៉ោង ៤ និង ១៥ នាទី ក៏ដូចជា កាលពីថ្ងៃទី ៣ សីហា ដែលពួក ឯកឧត្តមបានប្រជុំគ្នា ពីម៉ោង ៣ និង ២៥ នាទី ដល់ម៉ោង ៥ និង ៤៥ នាទី នៅវិលវល់ជុំវិញតែបញ្ហាដដែលៗ ទេៗ ថ្ងៃនេះ ខ្ញុំនឹងអាច

*ទំលាយនូវបញ្ហាមួយចំនួន ព្រោះខ្ញុំមានតម្រូវការចាំបាច់ដើម្បីនឹងបំភ្លឺ ហើយតបឆ្លើយជាមួយនិងអ្វីដែលជា ការឃោសនាអសុរស និងជួរជាតិបំផុត។ ខ្ញុំសូមបញ្ជាក់ថា ទោះជាសំដីរបស់ខ្ញុំមិនពិរោះយ៉ាងណាក្តី ប៉ុន្តែ ហោចណាស់ ក៏គ្រាន់បើជាងការដែលពួកឯកឧត្តម ប្រធានឯកឧត្តម ជេរពួកខ្ញុំថា «អាក្បត់ជាតិ» នៅតាមចិញ្ចើមផ្លូវ នៅតាមទីផ្សារ និងនៅតាមទីកន្លែងដទៃទៀត។ ពេលនេះ (យើងកំពុងមាន) ការផ្សាយបន្តផ្ទាល់សម្រាប់ប្រទេសជាតិទាំងមូល ដូច្នេះខ្ញុំមានការចាំបាច់នឹងនិយាយឲ្យអស់។ ទោះបីថា ឯកឧត្តម ត្រៀមលើកពីបញ្ហាការបាត់បង់កោះត្រល់ ការបាត់កោះក្រចកសេះ ការបាត់បង់នេះ ឬនោះ ការបោះបង្គោល និងរឿងស្អី។ ទៀតក៏ដោយ វានៅជុំវិញតែរឿងតែមួយ ដែលវិលវល់តាមគំនិតស្នេហាជាតិរបស់ក្រុមខ្លួនតែប៉ុណ្ណឹង។*

ជាការពិត សំណួររបស់ឯកឧត្តម **សុន ឆ័យ** តំណាងរាស្ត្រមណ្ឌលភ្នំពេញ ពុំមានអ្វីប្លែកទេ។ គេធ្លាប់បានដឹង និង ឮដដែលៗ ច្រើនដងមកហើយ នូវអ្វីដែល ឯកឧត្តម **សុន ឆ័យ** និង សហសេវិករបស់ឯកឧត្តមនៅក្នុងគណបក្សសមរង្ស៊ី បានលើកឡើងជាញឹកញាប់មកនោះ។ ទោះបីជាពេលខ្លះ សំណួរ និង ការចោទប្រកាន់ទាំងនោះ ត្រូវបានតាក់តែងឡើងតាមរូបភាពខុសគ្នាបន្តិចបន្តួច ក៏ប៉ុន្តែ គំនិតដើមរបស់វានៅតែដដែល ហើយវាប្រែក្លាយទៅជាអ្វីមួយដែលពុំចាំបាច់រកខុសត្រូវទៀតទេ ព្រោះវាត្រូវតែអញ្ចឹង ពោលគឺវាជា "ឧបធារណ៍" (Postulat) ឬជាការពិតមួយដែលត្រូវបានកំណត់ជាអត្តនោមតិដោយឯកឧត្តម **សុន ឆ័យ** និង

សហសេរីករួចទៅហើយ ហើយគ្មាននរណាអាចកែប្រែបាននោះឡើយ។ ជារួម អ្វីដែលឯកឧត្តម **សុន ឆ័យ** បានលើកឡើងដដែលៗ ជារឿយៗនោះ នៅតែវិលវល់ជុំវិញគំនិតស្នេហាជាតិតាមរបៀបក្រុមខ្លួន ដែលថា រាជរដ្ឋាភិបាលៈ

- *ធ្វើកិច្ចការព្រំដែន ដោយពុំមានតម្លាភាព ពុំមានវត្តមាន ឬការចូលរួមពីអង្គការក្រៅរដ្ឋាភិបាល ឬពីគណបក្សប្រឆាំង ឬអ្នកសង្កេតការណ៍អន្តរជាតិជាដើម នៅក្នុងគណៈកម្មាធិការព្រំដែនជាតិ,*
- *ធ្វើតាមគំនាបរបស់វៀតណាម ដែលបង្គាប់ឲ្យធ្វើតែប៉ុណ្ណោះ,*

*ពួកឯកឧត្តមបានចោទពួកយើងខ្ញុំសុទ្ធតែជាអាយ៉ងរបស់វៀតណាម ប៉ុន្តែថ្ងៃនេះ យើងអាចដឹងខុសត្រូវជាមួយគ្នា អំពីអ្វីដែល (ពួកឯកឧត្តម) ហៅថាជាអាយ៉ងនោះ។ បើជាអាយ៉ង តើចាំបាច់អីទៅចរចា, នេះនិយាយតាមមួយបែប, គេប្រាប់ត្រង់ណា ក៏ទៅយកត្រង់ហ្នឹងទៅ។ ប៉ុន្តែ ដែលទៅធ្វើការចរចាតថ្ងៃមួយតឹកមួយផឹងនេះ តើជាទង្វើរបស់អាយ៉ង ឬយ៉ាងម៉េច?*

*ដោយសារសម័យប្រជុំ របស់ឯកឧត្តមកាលពីថ្ងៃទី ៣ សីហា ក៏ដូចជាថ្ងៃទី ៨ សីហា ពួកឯកឧត្តមបានត្រៀមជាស្រេចហើយ, សុំទោសបើខ្ញុំនិយាយទៅខុស, រង់ចាំមើលការផ្ដល់សញ្ញាពីឯកឧត្តម* ***សុន ឆ័យ*** *និងឯកឧត្តម* ***យឹម សុវណ្ណ*** *ដើម្បីធ្វើជាសញ្ញានៃការចាកចេញពីសភា, តើមែនទេ? រួចបន្ទាប់ពីហ្នឹងទៅប្រគល់ឲ្យមានការរៀបចំធ្វើសន្និសីទកាសែត នៅខាងក្រៅដោយ*

*ឯកឧត្តម* **សាំ សិទ្ធ** *ជាអ្នកទទួលខុសត្រូវ។ ដូចខ្ញុំបានបញ្ជាក់ពីខាងលើ ការបំភ្លឺរបស់ខ្ញុំនៅទីនេះ គឺវាមិនធ្ងន់ធ្ងរដូចអ្វីដែលពួកឯកឧត្តម បានជេរពួកយើងខ្ញុំថាជាជនក្បត់ជាតិនោះទេ អញ្ចឹងខ្ញុំសូមអំពាវនាវ(អោយនៅស្តាប់)។ ខ្ញុំសង្ឃឹមថា ពួកអ្នកស្នេហាជាតិនៅប្រទេសបារាំង ជាពិសេសក្រុមកាន់ផែនទីរត់ចោលស្រុកប្រហែលជាកំពុងបើកទូរទស្សន៍មើល នឹងមិនវាយទូរទស្សន៍ចោលទេ។*

*យ៉ាងណាក្តី ខ្ញុំបានប្រាប់តំរិះឯកឧត្តមពីម្សិលហើយថា បើសិនជាឯកឧត្តមចង់ចាកចេញ ក៏លើកនេះសុំមេត្តាធ្វើខុសពីលើកមុន។ លើកមុន ពេលឯកឧត្តមចាកចេញពីទីនេះ ឯកឧត្តមបានប្រើប្រាស់* mask *ដើម្បីបិទមាត់ ជាសញ្ញាបញ្ជាក់ថា ក្រុមឯកឧត្តមមិនមានសិទ្ធិបញ្ចេញមតិទេ។ លើកនេះ ពេលឯកឧត្តមដើរចេញ សុំមេត្តា ឯកឧត្តមបិទភ្នែកឲ្យជិត ឬយកកន្សែងខ្ទប់ភ្នែកឲ្យជិត ហើយយកដៃទាំងពីរខ្ទប់ត្រចៀកឲ្យជិត កុំឲ្យឃើញ និងកុំឲ្យឮតែម្តងទៅ។ យ៉ាងណាក៏ដោយ សង្ឃឹមថា ក្នុងឋានៈជាអ្នកនយោបាយហ៊ានស៊ីហ៊ានសងដូចគ្នា យើងត្រូវតែលេងឲ្យអស់និយាយឲ្យអស់ ដើម្បីស្តាប់ការពិត។ សូមបញ្ជាក់ជូនឯកឧត្តមថា បើគ្មានពួកឯកឧត្តមស្តាប់នៅកន្លែងនេះ ក៏មានប្រជាពលរដ្ឋរាប់លាននាក់(កំពុងស្តាប់ដែរ) ព្រោះកំពុងផ្សាយបន្តផ្ទាល់នៅទូទាំង*

*ប្រទេស គ្រប់ប៉ុស្តិ៍ទូរទស្សន៍ និងវិទ្យុ និងផ្សាយចេញទៅបរទេសទៀតផង។*

*ខ្ញុំសូមយកឱកាសនេះបញ្ជាក់ឡើងវិញថា នយោបាយនេះ គ្មានអ្វីខុសពីនយោបាយឆ្នាំ ១៩៧០ ទេ ដែលមូលហេតុមួយក្នុងចំណោមមូលហេតុទាំងឡាយ នៃរដ្ឋប្រហារទំលាក់សម្តេចព្រះ* ***នរោត្តម សីហនុ*** *នៅឆ្នាំ ១៩៧០ គឺការប្រើប្រាស់(លេសជា)មូលហេតុថា សម្តេចព្រះ* ***នរោត្តម សីហនុ*** *លក់ដីឲ្យវៀតណាម ឬដែលពេលនោះហៅថាលក់ដីឲ្យយៀកកុង ឬលក់ដីឲ្យយួន។ យុទ្ធសាស្ត្របែបនេះ កំពុងត្រូវបាន និងកំពុងធ្វើនៅពេលនេះដូចគ្នាទៀតហើយ ដើម្បីគាំទ្រភាពត្រឹមត្រូវនៃការធ្វើរដ្ឋប្រហារឆ្នាំ ១៩៧០ ដែលឥឡូវ ពួកកាកសំណល់នេះ កំពុងតែនៅសេសសល់នៅឡើយ ហើយដែលក៏ប្រហែលជា ត្រូវបានចម្លងចូលមកក្នុងក្រុមរបស់ឯកឧត្តមទៀតផង។ ដូចជា ការធ្វើមិនដឹងមិនឮ អំពី បញ្ហាទាក់ទងថា* ***តើមូលហេតុអ្វី បានជាកម្ពុជាបាត់បង់នូវសិទ្ធិទាមទារយកកោះត្រល់។*** *អស់លោកពិតជាមិនដឹងទេថា ការយកផែនទីទៅតម្កល់នៅអង្គការសហប្រជាជាតិ ធ្វើអោយ សិទ្ធិទាមទារដីពីដូនតានៅកម្ពុជាក្រោម សិទ្ធិទាមទារដីកោះពីដូនតាត្រូវបាត់បង់។ (សួរថា) តើអ្នកណាជាអ្នកយកទៅតម្កល់ គឺ សម្តេចព្រះ* ***នរោត្តម សីហនុ។*** *នៅឆ្នាំ ១៩៩៩*

*សម្តេចព្រះ* **នរោត្តម សីហនុ** *នៅបានសរសេរលិខិតទៅលោក* **ផាំ វ៉ាន់ដុង** *ដែលជាអតីតនាយករដ្ឋមន្ត្រី (វៀតណាម) ពេលនោះ បញ្ជាក់បន្ថែមស្តីពីការយក* ligne *ប្រេវីយ៉េ (ជាខ្សែព្រំដែនសមុទ្ររវាងប្រទេសទាំងពីរ)។ ពេលដែល អស់លោកនិយាយពីបញ្ហាកោះត្រល់ តើអស់លោកបានដឹងទេពីប្រវត្តិសាស្ត្រទាំងឡាយ ដែលបានបន្សល់ទុកឲ្យយើងជាក្មេងជំនាន់ក្រោយ។ អស់លោកមិនត្រឹមតែចង់វាយតែខ្ញុំទេ គឺអស់លោកចង់វាយទៅលើអតីតព្រះមហាក្សត្រ និងព្រះមហាក្សត្របច្ចុប្បន្ន ដើម្បីរក្សានូវភាពស្របច្បាប់ និងមូលហេតុសមស្របនៃរដ្ឋប្រហារឆ្នាំ ១៩៧០ ដែលពេលនោះ មានរហូតដល់ការតាក់តែងជាចម្រៀង និងច្រៀងបន្តុះបង្អាប់ ចំពោះសម្តេចព្រះ* **នរោត្តម សីហនុ** *ទៀតផង ។*

*ខ្ញុំសូមអាននូវចំណុចខ្លះ ដែលជារឿងមិនគួរឲ្យស្តាប់ តែប្រជាជនកម្ពុជាត្រូវតែស្តាប់ ដើម្បីយើងអាចបានដឹងថាតើគេប្រមាថសម្តេចឪ សម្តេចតា សម្តេចតាទួត របស់យើងប៉ុណ្ណា។ ឥឡូវរឿងដដែល (នេះ គេធ្វើឡើងវិញ) គ្រាន់តែគេផ្លាស់មកវាយ* **ហ៊ុន សែន** *វិញ ក៏ប៉ុន្តែ (តាមពិត) ប៉ះសម្តេច* **សីហនុ** *ប៉ះសម្តេចព្រះបរមនាថ ដែលជាព្រះរាជបុត្រ កំពុងស្នងរាជ្យនាពេលបច្ចុប្បន្ន។ ចម្រៀង «**ស្អែកលាម៉ែចូលធ្វើទាហាន**» ដែលនិពន្ធ និងច្រៀង*

*ដោយអធិរាជសម្ដេចមាសលោក ស៊ិន ស៊ីសាមុត មានពីរឃ្លាក្នុងបួនឃ្លានៃបទចម្រៀង ត្រូវបានរំលឹកដដែលៗ ដែលខ្ញុំសូមអានកថាខណ្ឌនេះ «ពេលល្ងាចវៃយំភ្នំពពាលខែ ស្រណោះដីខ្មែរកេរ្តិ៍ពីដូនតា ស្ដេចលក់ឲ្យយៀកកុងក្បត់ជាតិសាសនា កូនសូមប្ដេជ្ញាធ្វើសឹកជាញជ័យ។ លាម៉ែចេញច្បាំងតតាំងកាប់ចាក់ កូនពិតពុំស្ទាប់ទេអ្នកម្ដាយថ្លៃ ខ្មាំងត្រូវហូរឈាមដាបពោះដំរី រលាយផែនដីដោយច្បាំងនឹងខ្មែរ»។ ឃ្លានេះត្រូវបានរំលឹកពីរដង នៅចំណុចចុងក្រោយ។ មានមួយបទទៀត ខ្ញុំគ្រាន់តែបង្ហាញ៖ «សឹង្ហឯងសាសន៍អីបានជាឪឈ្មោះ* **ម៉ៅ សេទុង** *បងប្អូនសុផាន់ក្ដាន់វង្ស កំពូជកំពុងមេចោរកាស្ត្រូ។ សឹង្ហឯងសាសន៍អីហ៊ានឲ្យយួនមកបាញ់អង្គរ គេបាញ់ខ្មែរខ្លួនស្រែកជយោ តើអង្គរសត្រូវខ្លួនពីកាលណា»។*

*ទាំងនេះ ជាឧទាហរណ៍ខ្លះ ក្នុងចំណោមឧទាហរណ៍ជាច្រើន ដែលពួកសាធារណរដ្ឋជាអ្នកបញ្ឆេះភ្លើងសង្គ្រាមបានធ្វើ ហើយនៅសេសសល់កាកសំណល់មួយចំនួន ដែលឥឡូវកំពុងត្រូវបានបញ្ចូលមកក្នុងពួកឯកឧត្តមៗ ឯកឧត្តមបានវាយខ្ញុំ ក៏ប៉ុន្តែការពិត មិនវាយត្រឹមខ្ញុំទេ គឺវាយសម្ដេចព្រះ* **នរោត្តម សីហនុ** *(ផងដែរ) ព្រោះអ្វីដែលខ្ញុំបាន និងកំពុងធ្វើនេះ អត់មានអ្វីខុសសូម្បីតែបន្តិច (ពីអ្វី) ដែលបានបន្សល់ទុកដោយសម័យ*

សង្គមរាស្ត្រនិយម ទាំងផែនទីដីគោក និងផែនទីដីទឹក។ បន្តិចទៀតខ្ញុំ នឹងជំរាបប្រាប់ថា ហេតុអ្វីបានជាមិនលុបកិច្ចព្រមព្រៀង ឬសន្ធិសញ្ញាដែលផ្ទុយនឹងកិច្ចព្រមព្រៀងប៉ារីស ដែលខ្ញុំបាននាំមកជាមួយ ដូចដែលឯកឧត្តមបានចោទសួរ ដើម្បីខ្ញុំបញ្ជាក់ជូនអំពីបញ្ហាហ្នឹងឲ្យវាច្បាស់លាស់នៅថ្ងៃនេះជាមួយគ្នា។ ខ្ញុំជាហត្ថលេខីម្នាក់ក្នុងចំណោមហត្ថលេខី ដែលនៅទីនេះហោចបំផុតមានបីនាក់ដែរ គឺ ខ្ញុំ ឯកឧត្តម **ឡៅ ម៉ាញ់** ឯកឧត្តម **ហោ ណាំហុង** នៃកិច្ចព្រមព្រៀងក្រុងប៉ារីសកាលពីពេលនោះ។ ខ្ញុំក៏យល់អំពី កិច្ចព្រមព្រៀងក្រុងប៉ារីសដែរ (ដូចនេះ)ហើយយើងកុំបកស្រាយបំពានគ្នា។

អ្វីដែលបានកើតឡើងពីអតីតកាល (កំពុងត្រូវ)បានចម្លងចូលមកក្នុងបច្ចុប្បន្នកាល ប៉ុន្តែជាក័ព្វសំណាងត្រង់ថា ឯកឧត្តមបានប្រើប្រាស់វេទិកាសភា ដើម្បីឲ្យខ្ញុំមានឱកាសឆ្លើយ ប្រសើរជាងមេឯកឧត្តម ហើយក៏ប្រសើរជាងជនអគតិ ហើយក៏ប្រហែលជានៅក្នុងក្រុមតែមួយជាមួយគ្នា។ ខ្ញុំមិនចោទឯកឧត្តមទេ។ កាលពីថ្ងៃទី ៤ សីហា កន្លងទៅ មានការក្លែងបន្លំនូវឯកសារខ្ញុំមួយ ផ្ញើជូនជនរួមជាតិ។ សូមបញ្ជាក់ជូន ឯកសារ (ក្នុងដៃខ្ញុំ) នេះ (ឧបសម្ព័ន្ធទី ១/១) ពួកគេបានធ្វើដោយ scan ហត្ថលេខារបស់ខ្ញុំ (ដាក់ជាមួយ) ផ្ញើជូនជនរួមជាតិ។ នេះជាឯកសារដែល

*បានបញ្ចេញទន្ទឹមគ្នា និង (ព័ត៌មានផ្សព្វផ្សាយអំពី) មរណភាពរបស់សម្តេច **ជា ស៊ីម** ប្រមុខរដ្ឋស្តីទី និងជាប្រធានគណបក្សប្រជាជនកម្ពុជាបច្ចុប្បន្ន (ឧបសម្ព័ន្ធទី ១/២)។ បើសិនជាមានមរណភាពពិតប្រាកដមែន ពេលនេះ ប្រហែលជាយើងមិនបានមកឆ្លើយនៅសភាទេ យើងត្រូវតែធ្វើបុណ្យឲ្យប្រមុខរដ្ឋស្តីទី និងជាប្រធានព្រឹទ្ធសភា។ ហេតុអ្វីបានជាគេបញ្ចេញតាមវែបសាយត៍ដដែល បន្ទាប់ពីនៅថ្ងៃទី ៨ និងថ្ងៃទី ៩ សីហា នូវការក្លែងលិខិតមួយទៀតរបស់សម្តេច ហេង សំរិន ក្នុងឋានៈជាប្រធានរដ្ឋសភាផ្ញើជូនខ្ញុំវិញ ថាមិនអាចផ្សព្វផ្សាយលិខិតរបស់ខ្ញុំបានទេ? (ឧបសម្ព័ន្ធទី ១/៣)។*

*ខ្ញុំសុំជនរួមជាតិ មេត្តាធ្វើការវិនិច្ឆ័យ។ បើគេហ៊ានក្លែងបន្លំនូវលិខិតសាធារណៈយ៉ាងដូចនេះ តើគេខ្លាចអ្វីនឹងធ្វើការឃោសនាបំភាន់មតិប្រជាជន លើបញ្ហាការបាត់បង់ទឹកដី? សូមព្រះតេជគុណព្រះសង្ឃគ្រប់ព្រះអង្គ និងបងប្អូនជនរួមជាតិពិចារណាចុះ បើហ៊ានធ្វើដូច្នោះ តើពួកគេខ្លាចអ្វីនឹងទៅបោកប្រាស់ប្រជាពលរដ្ឋ ដូចដែលពួក ប៉ុល ពត ធ្លាប់បោកប្រាស់ប្រជាពលរដ្ឋកាលពីពេលមុន។ (គឺជាស្នាដៃរបស់) ក្រុមដដែល ឬក្រុមតែមួយ គ្រាន់តែនៅសាខាខុសគ្នា។ សូមយកឱកាសនេះ ក្នុងនាមរដ្ឋសភា ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់*

អំពាវនាវ ចំពោះអ្នកដែលចូលរួមធ្វើលិខិតនេះ សុំមេត្តាផ្តល់កស្តុតាង ដោយខ្ញុំនឹងផ្តល់រង្វាន់ចំនួន ៥ ម៉ឺនដុល្លារសហរដ្ឋអាមេរិក ចំពោះជនទាំងឡាយណា ដែលមកបំភ្លឺជូនការពិតដើម្បីស្វះស្វែងរកមេក្លោងយកមកផ្តន្ទាទោសតាមផ្លូវច្បាប់។

ការដកបង្គោលព្រំដែន ឬការក្លែងលិខិតសាធារណៈ គឺជាទោសដែលមិនអាចអត់ឱនឲ្យបានទេ។ នេះមិនមែនជាអ្នកទោសមនសិការទេ។ ថ្ងៃនេះ ទោះបីជាឯកឧត្តមជេរខ្ញុំនៅកណ្តាលទីហ្នឹង ក៏ឯកឧត្តមមិនត្រូវមានទោសទេ។ ក៏ប៉ុន្តែ ការក្លែងបន្លំនូវលិខិតបែបនេះ ទោសវាត្រូវតែមានហើយ បើទោះឯកឧត្តមមានអភ័យឯកសិទ្ធិសភា ៥០០ ដងទៀត ក៏ត្រូវតែមានទោសដូចគ្នាដែរ។ សូមជនរួមជាតិធ្វើការវិនិច្ឆ័យលើបញ្ហា (ដែលគេក្លែងលិខិតថា) សម្តេច **ជា ស៊ីម** ស្លាប់ **ហ៊ុន សែន** ធ្វើលិខិតផ្ញើជូនជនរួមជាតិ សម្តេច **ហេង សំរិន** ធ្វើលិខិតផ្ញើជូន **ហ៊ុន សែន** ថាលិខិតនេះផ្សាយមិនបានទេ។ (ក្នុងការជាក់ស្តែង) ក្នុងឋានៈជាប្រធាននៃអង្គនីតិប្រតិបត្តិ ខ្ញុំអត់មានការចាំបាច់ថាត្រូវសុំប្រធានសភា ដើម្បីផ្សាយអត្ថបទនេះអត្ថបទនោះទេ។ វិទ្យុមាន ទូរទស្សន៍មាន កុំថាឡើយខ្ញុំឲ្យគេថតទុក សូម្បីផ្សាយផ្ទាល់ចេញពីផ្ទះខ្ញុំ ក៏អាចផ្សាយបាន ដូចឥឡូវកំពុងផ្សាយចេញពីរដ្ឋសភា។ ខ្ញុំមិនបានយកឯកសារនេះចូលក្នុងសភាទេ ថ្ងៃនេះ តែខ្ញុំនឹងស្នើ

ឲ្យអ្នកទាំងឡាយទៅយកឯកសារនេះនៅឯក្រៅសភា (សម្តេចតេជោមានប្រសាសន៍អំពីឯកសារ ជាខ្លឹមសារស្រង់ចេញពីកិច្ចសន្ទនារបស់សម្តេចតេជោ ជាមួយលោក **សុន ឆ័យ**)។

មុននឹងបន្ត ខ្ញុំគួរតែនិយាយឲ្យហើយ ព្រោះខ្ញុំបារម្ភក្រែងឯកឧត្តម **សុន ឆ័យ** ចាកចេញពីអង្គប្រជុំ។ បើខ្ញុំនិយាយពីក្រោយខ្នងឯកឧត្តម **សុន ឆ័យ** គឺយើងពិតជាមានការលំបាក ហើយ ឯកឧត្តម **សុន ឆ័យ** នឹងអាចចោទប្រកាន់ខ្ញុំ។ ឥឡូវ តើឯកឧត្តម **សុន ឆ័យ** ជាអ្នកណា? ប្អូន **សុន ឆ័យ**, ប្អូនពិតជាស្គាល់បងច្បាស់ ព្រោះប្អូនជាប្អូនធម៌របស់បង។ បងពិតជាអរគុណប្អូនណាស់ ដែលបានធ្វើកិច្ចការដ៏ល្អសម្រាប់បងក្នុងរយៈកាលឆ្នាំ ១៩៩៥, ១៩៩៦ និង ១៩៩៧ ហើយបន្តមកទៀត។ (មានពេល) ប្អូនសួរបងថា តើឲ្យប្អូនទៅទីណា? បងបានប្រាប់ប្អូនថា ទៅគណបក្សណា ដែលអាចជាប់ឆ្នោតជាសមាជិកសភា។ ក្រៅពីប្អូននៅមានឯកឧត្តម **ឃី តាំងលឹម** មួយទៀត ដែលបានទៅសួរខ្ញុំដល់ផ្ទះ «តើឲ្យខ្ញុំទៅណា»។ ខ្ញុំថាទៅរកបក្សណាដែលអាចជាប់ ជាតំណាងរាស្ត្រទៅ។ ប៉ុន្តែខ្ញុំសូមបញ្ជាក់ចំណុចខ្លះៗ ជូនប្អូន **សុន ឆ័យ** ឲ្យបានជ្រាប។ ខ្ញុំគួរតែហៅឯកឧត្តម ថាជា ឯកឧត្តម តែខ្ញុំនិយាយក្នុងក្របខណ្ឌយើងជាបងប្អូនសិន។

*ប្អូនធ្វើការល្អណាស់ ការទប់ស្កាត់មិនឲ្យឆេះក្រុងភ្នំពេញអាចថាជាគុណសម្បត្តិរបស់ប្អូនដែរ ដោយពេលនោះ ប្អូនបានផ្តល់ព័ត៌មានឲ្យបងបីដង ដែលមានសារសំខាន់ខ្លាំងណាស់។ លើកទី ១ តើនៅចាំបានទេ នៅក្នុងពេលដែលចូលមើលសិល្បៈនៅក្នុងព្រះបរមរាជវាំង ហើយដែលកាលនោះ គឺអតីតព្រះមហាក្សត្រសម្តេចព្រះ* **នរោត្តម សីហនុ**។ *កាលពីពេលនោះយើងបានទៅជួបគ្នានៅខាងក្រោយ។ សូមកុំគ្រវីក្បាល ក្រែងលោព្រះបរមរាជវាំងកាច់។ យើងមើលសិល្បៈនៅខាងមុខ តែខ្ញុំបានបោះបង់ចោលព្រះករុណាបន្តិច (ដើម្បីជួបប្អូន)។ ប្អូនបានរាយការណ៍ឲ្យបងអំពីសភាពការណ៍នៅយោធភូមិភាគ ៤។ លើកទី ២ ប្អូនបាននាំប្រពន្ធ និងកូនពីរនាក់ផង ទៅផ្ទះបងនៅតាខ្មៅ។ ប្អូននៅចាំទេ ពេលនោះបងបានសុំឲ្យប្រពន្ធរបស់ប្អូនជួយសិក្សាដីអ្នកក្រាំងយ៉ូវផង ព្រោះបងកំពុងតែអនុវត្តផែនការអភិវឌ្ឍដីអ្នកក្រាំងយ៉ូវ។ ពេលនោះប្អូនបានរាយការណ៍មួយដំណាក់ទៀតនូវសភាពការណ៍យោធា ដែលពាក់ព័ន្ធនឹងការរៀបចំដោយឯកឧត្តម* **ញឹក ប៊ុនឆៃ**, **ខាន់ សាវឿន** *និង* **ហូ សុខ** *ជាដើម។ លើកទី ៣ ប្អូនបានទៅជួបបងម្តងទៀត។ ប្អូនស្គាល់ក្រឡុកក្រលៀតផ្ទះបងច្បាស់ណាស់។ ប្អូនបានរាយការណ៍ដ៏ល្អ (ប្រាប់បង) នៅ kiosk ក្នុងស្រះចិញ្ចឹមត្រីខាងក្រោយផ្ទះ។ រឿងរ៉ាវទាំងអស់នោះ ធ្វើឲ្យបងបានត្រៀមលក្ខណៈទប់ទល់សភាពការណ៍*

*បានជាមុន។ អ្វីដែលប្អូនបានធ្វើនោះ បងមិនចាត់ទុកប្អូនជាចារកម្មទេ ក៏ប៉ុន្តែ ទង្វើបែបនេះ គេចង់ថាអ្វីក៏បានដែរ។ ប្អូនមានឆន្ទៈល្អចំពោះបង ឬឯកឧត្តមមានឆន្ទៈល្អ ចំពោះរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ខ្មែរក្រហមចូលក្រុង។ នេះជាសម្រង់ខ្សែអាត់ដែលខ្ញុំសូមផ្សាយជូន ដើម្បីចៀសវាង(ការច្រានចោល) ព្រោះអម្បាញ់មិញ ឯកឧត្តមបានគ្រវីក្បាលទៅហើយ។ ខ្ញុំមិនអាចទុកឲ្យឯកឧត្តមគ្រវីក្បាលបានទេ។*

*ថ្ងៃនេះយើងត្រូវនិយាយគ្នាឲ្យច្បាស់។ បន្ទាប់ពីការផ្ទុះអាវុធ ថ្ងៃទី ៥ ទី ៦ ខែ កក្កដា ពេលនោះ តំណាងពិសេសអគ្គលេខាធិការអង្គការសហប្រជាជាតិ បានប្រមូលបងប្អូនអ្នកតំណាងរាស្ត្ររបស់ ហ៊ុនស៊ិនប៉ិច និងអ្នកតំណាងរាស្ត្ររបស់គណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា មួយចំនួនមកកាន់សណ្ឋាគារ។ ខ្ញុំមិនច្បាស់ថា សណ្ឋាគារណាទេ ប៉ុន្តែប្រហែលជាកាំបូឌីយ៉ាណាហើយ។ នៅយប់មួយ ប្រហែលជាម៉ោង ១០ កន្លះ ប្អូនបានទូរស័ព្ទទៅសួរបង, សូមកុំគ្រវីក្បាល, ចាំយកឯកសារនេះទៅមើលទៅមានទាំងខ្សែអាត់ផង។ ឯនេះ គឺ* disk។ *ប្អូនបានសួរបងថា តើឲ្យខ្ញុំទៅជាមួយគេឬយ៉ាងណា ហើយប្អូនថែមទាំងផ្តល់យោបល់ឲ្យបងទៀតថា បើសិនជាទៅជាមួយគេ យើងអាចដឹងរឿងរបស់គេ។*

*នៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ ១៩៩៧ វេលាម៉ោង ៧ និង ៣០ នាទីយប់ ប្អូនបានទៅជួបបង នៅផ្ទះឯតាខ្មៅ។ (ឯកឧត្តម* **សុន ឆ័យ** *ឆ្លើយពីអាសនៈ «ត្រឹមត្រូវមែន សម្តេច») បើអញ្ចឹង យកអាហ្នឹងទៅមើលខ្លួនឯងទៅដើម្បីឲ្យឃើញ។ ខ្ញុំនឹងនិយាយពីបញ្ហាមួយចំនួន ដើម្បីឲ្យដឹងថា យើងជាបងប្អូននឹងគ្នា។ តែឥឡូវជេរអីក៏អាក្រក់ម្ល៉េះ។ ជួនកាលបងគិតថា ប្អូនឯងជេរបងនេះ ដើម្បីបិទបាំងទំនាក់ទំនងអតីតកាលរបស់យើង។ ពេលខ្លះបងសួរ ឯកឧត្តម* **នៅ សំ** *ថា «សួរ (***សុន***)* **ឆ័យ** *មើល ថាជេរខ្ញុំមែនទែន ឬជេរលេងៗ។ (ឯកឧត្តម នៅ) សំ បានប្រាប់, តែមិនដឹងថាសួរ* **សុន ឆ័យ** *ពិតប្រាកដ ឬមិនពិតទេ, (សូមទោសឯកឧត្តម* **នៅ សំ***) ថា «សួរ អា* **ឆ័យ** *ហើយ ហើយ វាថា បើអញមិននិយាយ តើអាណាគេស្គាល់អញ»។ នៅពេលដែល ឯកឧត្តមប្អូនឯងមកដល់ភ្នំពេញ ប្អូនឯងបានប្រកាសឲ្យបងលាលែងពីតំណែងជាផ្លូវខាងក្រៅ តែផ្លូវខាងក្នុង ប្អូនបានទៅជួបបង ហើយយើងសន្ទនាជាមួយគ្នាចុងក្រោយ។*

*អ្នកអានទាំងឡាយ សូមកត់សំគាល់ ពាក្យថា «បើអញ្ចឹង យកអានេះទៅ» នោះគឺ លុយមួយម៉ឺនដុល្លារ គឺបងឲ្យប្អូនមួយម៉ឺនយកទៅធ្វើការ។ ការផ្ទេរសំខាន់ចុងក្រោយពេលដែលបងប្រគល់ឲ្យប្អូនឯង ក្នុងពេលដែលបងបានជូនដំណើរប្អូនឯងចុះ*

មកក្រោម មានតែពីរទេ **ការងារទី ១៖** តាមមើលទំនាក់ទំនង **សម រង្ស៊ី** ជាមួយ **តា ម៉ុក** ដូចម្តេចៗ ប្អូនបានប្រាប់បងថា "មិនហ៊ានចូលទៅកន្ទែង **ញឹក ប៊ុនឆៃ** ទេ ព្រោះខ្លាច **ញឹក ប៊ុនឆៃ** ដឹងថាខ្ញុំជាប្អូនធម៌របស់បងឯង"។ និយាយមិននិយាយ គឺប្អូនអាចយកឯកសារទៅមើលបានហើយ មិនចាំបាច់ចោទឆ្លើយទេ ហើយខ្ញុំឲ្យបង្ហោះតាមវ៉ិបសាយត៍ទាំងអស់។ ឥឡូវនេះ មាននៅខាងក្រៅ ១៥០ ច្បាប់ អ្នកណាចង់យកទៅមើលក៏យកទៅមើលទៅ។ ខ្ញុំមិនចង់វាយប្រហារប្អូនទេ រឿងសំខាន់ គឺទាក់ទងនឹងព្រឹត្តិការណ៍ ថ្ងៃទី ៥ ថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ១៩៩៧ ដែលជារឿងរាល់ឆ្នាំ គណបក្សសមរង្ស៊ី ធ្វើខួបរដ្ឋប្រហារឯណោះទេ។

មើលក្នុង(ឯកសារ)នេះ យើងនឹងរំលឹកពីអ្នកទាំងឡាយដែលយើងធ្លាប់ស្គាល់កាលពីពេលមុន ហើយដែលបានបែកស្គានទៅ តែអ្នកខ្លះក៏មិនទាន់បែកស្គានដែរ ដូចជា ឯកឧត្តម **ស៊ុត ប៉េងគុណា** ឯកឧត្តម **ស្វ ឌី** ដូចជាបែកឋានទៅហើយ ឯកឧត្តម **ឡាយ ខែក** និងអ្នកដទៃទៀត មានឈ្មោះនៅក្នុងនេះច្រើនណាស់។ **ការងារ ទី២៖** គឺ ប្រមែប្រមូលសមាជិកសភា និងអ្នកដឹកនាំដទៃទៀតរបស់គណបក្ស ហ៊្វុនស៊ិនប៉ិច និងគណបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា។

ពេលប្អូនចេញពីបង ប្អូនកុំភ្លេចណ៎ា បងមិនឲ្យប្អូនវាយ

*ការណ៍ឲ្យទេ។ ប្អូនបានទៅសៀមរាប គាល់ សម្ដេចព្រះ* **នរោត្តម សីហនុ**។ *ប្អូនទូរស័ព្ទមកបងទាំងយប់ រាយការណ៍អំពីជំនួបរបស់ប្អូនជាមួយនឹង សម្ដេចព្រះ* **នរោត្តម សីហនុ**។ *បើសិនជាមិនច្បាស់ប្អូន អាចទៅស្រាវជ្រាវអតីតក្រុមហ៊ុនទូរស័ព្ទសាម៉ាត ០១៥ ក្នុងនេះមានលេខទូរស័ព្ទដែលបានប្រើប្រាស់ ហើយបញ្ហានេះ គឺខ្ញុំសូមបញ្ជាក់ថា ដើម្បីទប់ទល់ជាមួយមនុស្សដូចឯកឧត្តម ខ្ញុំត្រូវតែមានវិធីនេះ ។ ឯកសារនេះគ្រាន់តែជាផ្នែកមួយរបស់ឯកឧត្តមទេ ប៉ុន្តែឯកឧត្តម* **សម រង្ស៊ី** *ក៏មានដែរ តែខ្ញុំមិនផ្សាយរបស់ឯកឧត្តម* **សម រង្ស៊ី** *ទេ។ ឯកឧត្តម មានត្រឹមតែ ២០ ទំព័រទេ តែរបស់ឯកឧត្តម* **សម រង្ស៊ី** *មានដល់ទៅ ៥៤ ទំព័រ ក្នុងការជួបគ្នាបីម៉ោង។ ពេលណាគ្មានតម្រូវការ ខ្ញុំមិនផ្សព្វផ្សាយទេ ហើយខ្ញុំសង្ឃឹមថា ឯកឧត្តម* **សម រង្ស៊ី** *អាចមានដូចគ្នា ព្រោះឯកឧត្តម* **សម រង្ស៊ី** *តែមួយម៉ោង គាត់សុំខ្ញុំចូលបន្ទប់ទឹកម្ដងដែលខ្ញុំសន្និដ្ឋានបានថា មួយម៉ោងនោះ គឺពេលដែលគាត់ចូលទៅដើម្បីដូរខ្សែអាត់ ក្នុងជំនួបពីរលើក រវាងឯកឧត្តម* **សម រង្ស៊ី** *និងខ្ញុំ ម្ដងនៅឆ្នាំ ១៩៩៧ និង ម្ដងទៀតនៅឆ្នាំ២០០៦។ បើសិនជាចង់បានឯកសារនេះ អស់លោកអាចទៅទាក់ទងជាមួយនិងឯកឧត្តម* **យូ ស៊ុនឡុង**។ *សូមកុំយកចូលក្នុងសភាអី ហើយវ៉ែបសាយត៍នានា បើចង់បង្ហោះក៏បង្ហោះទៅ ដើម្បីឲ្យយើងបានដឹង ហើយប្រជាពលរដ្ឋគាត់អាចធ្វើការវិនិច្ឆ័យបានថា អ្នកណាយ៉ាង*

*ម៉េច សភាពការណ៍វាយ៉ាងម៉េច។*

*ដោយហេតុថា ដើម្បីឲ្យស្គាល់ប្អូន* **សុន ឆ័យ** *ឲ្យបានច្បាស់, បងសុំទោស ដោយបងមានការចាំបាច់ដើម្បីបញ្ចេញនូវឯកសារនេះ។ មិនមែនដោយសារតែប្អូនសួរបង បានបងបញ្ចេញឯកសារនេះទេ។ ទោះបីប្អូនមិនសួរបង ក៏បងត្រូវតែផ្សព្វផ្សាយឯកសារនេះដែរ ព្រោះបងមានតម្រូវការចាំបាច់ដើម្បីជួសជុលនូវការខូចខាត បណ្តាលមកពីនយោបាយអសុរសនយោបាយអាក្រក់របស់គណបក្សប្អូន ដែលចោទបងថាធ្វើរដ្ឋប្រហារ ឆ្នាំ ១៩៩៧។ អញ្ចឹងយើងបានស្គាល់មួយគន្ទាក់ហើយ អំពីសារបាន រហូតដល់បញ្ហាពិត, បញ្ហាការក្លែងបន្លំនៃឯកសារមុននឹងការមកឆ្លើយ នូវសំណួរនៅទីនេះ។ ឯកឧត្តមទ្រាំស្តាប់បន្តិចទៅ ដើម្បីយើងអាចយល់ទាំងអស់គ្នា ហើយ (ក្នុងឋានៈ) ជាជាតិសាសន៍ដូចគ្នា យើងគួរតែស្តាប់គ្នាបាន។*

- *ហាក់ដូចជាមានការបិទបាំង មិនឲ្យសាធារណជនបានដឹងឮ ដោយធ្វើការរារាំង មិនឲ្យបក្សប្រឆាំងបានចូលទៅមើលទីតាំងបង្គោលតម្រុយព្រំដែន ដោយប្រើកម្លាំងរារាំងគ្រប់បែបយ៉ាង រួមទាំងការចាប់ចង និងដាក់គុកច្រវាក់ទៀតផង,*
- *ធ្វើកិច្ចការព្រំដែនពុំស្មើភាពគ្នា ដោយទុកឲ្យប្រទេសជិតខាងជាអ្នកធ្វើ, ឲ្យគេចូលមកបោះបង្គោលស្រេចតែចិត្ត លើដីស្រែចំការរបស់ប្រជាពលរដ្ឋខ្មែរ និង ខ្វះធនធានមនុស្ស ខ្វះឧបករណ៍ប្រើប្រាស់ ដែលជា*

*ប្រការធ្វើឲ្យកម្ពុជាបាត់បង់ទឹកដីជាច្រើនសន្ធឹកសន្ធាប់ទាំង១០ ខេត្តគឺតាំងពីខេត្តរតនគិរីដល់ខេត្តកំពត គិតជាផ្ទៃដីរាប់ពាន់គីឡូម៉ែត្រក្រឡា និងបាត់ដែនសមុទ្រខ្មែរទៅឲ្យប្រទេសជិតខាងក្នុងទំហំដ៏ធំ ដែលជាអំពើក្បត់ជាតិ ពុំអាចអត់អោនឲ្យបាន ហើយដែលគណបក្សរបស់ឯកឧត្តមសន្យាថា នឹងសើរើកិច្ចព្រមព្រៀងព្រំដែន ដែលបានសម្រេចរួចមកហើយ ដោយទាមទារយកមកវិញនូវទឹកដី ដែលបាត់ទៅនោះ ខណៈដែលខ្លួនបានឡើងកាន់អំណាច ជាដើម។ល។*

អង្គរដ្ឋសភាទាំងមូលពិតជានៅចាំបានថា នេះមិនមែនជាលើកទីមួយទេ ដែលរាជរដ្ឋាភិបាលបាន ផ្តល់ការបំភ្លឺជាលាយល័ក្ខអក្សរ ឬ ចាត់តំណាងចូលមកផ្តល់ការបំភ្លឺជូនដល់អង្គរដ្ឋសភា អំពីកិច្ចការដ៏មានសារសំខាន់ជាអាយុជីវិតប្រទេសជាតិនេះ។ នៅពេលនេះ ខ្ញុំក៏ប្រមូលចងក្រងយកមកជាមួយ នូវការបំភ្លឺជាលាយល័ក្ខអក្សរទាំងនោះផងដែរ។ យ៉ាងណាក៏ដោយ ការឃោសនា និង សំណួរចោទប្រកាន់ជាអកុសល នៅតែបន្តកើតមានឡើង ហើយមានលក្ខណៈកាន់តែស្រួចស្រាវឡើងថែមទៀត ដោយសារអ្នកចោទសួរទាំងនោះ ធ្វើជាមិនយល់អំពីការខិតខំបំភ្លឺ និង ធ្វើជាមើលមិនឃើញអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល នៅក្នុងការដោះស្រាយបញ្ហាដ៏មានសារសំខាន់នេះឡើយ។

ខ្ញុំពិតជាយល់ច្បាស់ដោយគ្មានការស្រមើស្រមៃទេថា ឯកឧត្តម **សុន ឆ័យ** និង សហសេរីករបស់ខ្លួន មានបំណងចង់យកបញ្ហាព្រំដែនដែលជាបញ្ហារសើបបំផុតសម្រាប់ប្រទេសជាតិ មកធ្វើអាជីវកម្មនយោបាយ ក្នុងគោលដៅវាយប្រហារមកលើគណបក្សប្រជាជនកម្ពុជា ពិសេសមកលើរូបខ្ញុំផ្ទាល់ ដើម្បីផលប្រយោជន៍នយោបាយរបស់ខ្លួន។ នេះមិនមែនជារឿងប្លែក និង ថ្មីសម្រាប់កម្ពុជានោះទេ។ យុទ្ធសាស្ត្របែបនេះ ធ្លាប់បានគេ

យកមកប្រើរួចមកហើយ នៅក្នុងប្រវត្តិសាស្ត្រនយោបាយរបស់កម្ពុជា។ យើងទាំងអស់គ្នានៅចាំបានថា នៅដើមទសវត្សឆ្នាំ ១៩៧០ ចរន្តនយោបាយសាធារណរដ្ឋដឹកនាំដោយលោកសេនាប្រមុខ **លន់ នល់** បានប្រើប្រាស់ការចោទប្រកាន់លើ ព្រះករុណា សម្តេចព្រះ **នរោត្តម សីហនុ** ដែលជាព្រះប្រមុខរដ្ឋនៅពេលនោះថា *"លក់ទឹកដីឲ្យយួន"* ជាលេសមួយដ៏សំខាន់ សម្រាប់ការធ្វើរដ្ឋប្រហារទម្លាក់ព្រះអង្គនាពេលនោះ រហូតដល់មានការតែងជាចម្រៀងចាក់ផ្សាយជាសាធារណៈថែមទៀតផង។

នៅពេលនេះ ឯកឧត្តម **សុន ឆ័យ** និង សហសេវិក អាចចង់ប្រើប្រាស់យុទ្ធសាស្ត្រនៃការឃោសនានយោបាយដដែលនេះ ដើម្បីផ្តួលគណបក្សប្រជាជនកម្ពុជា ពិសេសគឺផ្តួលរូបខ្ញុំផ្ទាល់ ដែលជាមេដឹកនាំសំខាន់មួយរូប នៅក្នុងគណបក្សប្រជាជនកម្ពុជានេះ។ ដូច្នេះ បើទោះបីជាខ្ញុំ, ក្នុងឋានៈជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, មកបំភ្លឺដោយផ្ទាល់លើសំណួររបស់ឯកឧត្តម **សុន ឆ័យ** នៅពេលនេះទៀត ក៏ប្រហែលជាឯកឧត្តម **សុន ឆ័យ** និង សហសេវិករបស់ខ្លួន នៅតែធ្វើជាមិនយល់ដដែលដដែរ។ លើសពីនេះទៀត ឯកឧត្តម **សុន ឆ័យ** និង សហសេវិក អាចនឹងមិនចង់ស្តាប់ការពន្យល់នេះទេហើយអាចនាំគ្នាដើរចេញពីការប្រជុំនេះថែមទៀតផង។ ខ្ញុំសូមអំពាវនាវដល់ឯកឧត្តម **សុន ឆ័យ** និង សហសេវិក សូមមេត្តាអត់ធ្មត់ ទ្រាំនៅស្តាប់ការពន្យល់បំភ្លឺរបស់រាជរដ្ឋាភិបាលទៅលើសំណួររបស់ឯកឧត្តម ឲ្យបានដល់ចប់ ទោះបីជាការពន្យល់បង្ហាញអំពីការពិតនេះ អាចមិនពិរោះសម្រាប់ឯកឧត្តម និងសហសេវិក ឬក៏ ឯកឧត្តម និង សហសេវិក អាចមិនចង់ស្តាប់ មិនចង់ទទួលយកក៏ដោយ។

យ៉ាងណាមិញ ខ្ញុំសូមអនុញ្ញាតគូសបញ្ជាក់ថា កិច្ចការការពារអធិបតេយ្យ និង បូរណភាពទឹកដីរបស់ជាតិ គឺជាភារកិច្ច និង កាតព្វកិច្ច

សំខាន់ជាងគេ និង មុនគេបង្អស់ របស់រាជរដ្ឋាភិបាល ហើយក៏ជាសិទ្ធិ និង ករណីយកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបផងដែរ។ ការស្នេហាជាតិ និង ទឹកដីនេះ គឺពុំមែនជាសិទ្ធិផ្តាច់មុខរបស់បុគ្គល ឬ គណបក្សនយោបាយណាមួយតែម្នាក់ឯងនោះទេ។ ក៏ប៉ុន្តែ ផ្ទុយទៅវិញ ការលើកយកបញ្ហានេះមកធ្វើអាជីវកម្មកេងចំណេញខាងនយោបាយ ដោយគ្មានការទទួលខុសត្រូវ ដើម្បីបម្រើផលប្រយោជន៍របស់បុគ្គល ក្រុម ឬ គណបក្សរបស់ខ្លួន តាមរយៈមធ្យោបាយប្រជាភិថុត, ការញុះញង់, ការបំផ្លើស និង ការបង្កើតឲ្យមានការភាន់ច្រឡំលើបញ្ហាព្រំដែននេះ នៅក្នុងចំណោមសាធារណមតិជាតិ និង អន្តរជាតិ អាចនឹងនាំមកនូវគ្រោះថ្នាក់ដ៏ធំធេងសម្រាប់ប្រទេសជាតិ និង ប្រជាជនទៅវិញទេ។ បទពិសោធន៍របស់កម្ពុជាខ្លួនឯងផ្ទាល់ និង របស់បណ្តាប្រទេសផ្សេងទៀតជាច្រើន បានបង្ហាញឲ្យឃើញថា ទង្វើដោយគ្មានការទទួលខុសត្រូវបែបនេះ អាចនាំមកនូវអរិភាពជាតិសាសន៍, បង្ករការខូចខាតដល់ទំនាក់ទំនង មិត្តភាព, សហប្រតិបត្តិការ និង អ្នកជិតខាងល្អរវាងប្រទេសជាប់ព្រំដែនគ្នា ហើយជារឿយៗ អាចនាំទៅដល់ការកើតឡើងនូវជម្លោះរវាងប្រទេស និង ប្រទេស, អស្ថិរភាពផ្ទៃក្នុង និង ការបាត់បង់នូវផលប្រយោជន៍ សង្គម-សេដ្ឋកិច្ចជាច្រើនផ្សេងទៀតរបស់ជាតិ និង ប្រជាជន។

ខាងលើនេះ គឺជាមូលហេតុចម្បង និងសំខាន់ជាងគេ ដែលជម្រុញឲ្យខ្ញុំសម្រេចចិត្តថា ត្រូវតែមកផ្តល់ការបំភ្លឺដោយផ្ទាល់ នៅក្នុងសម័យប្រជុំរដ្ឋសភាលើកនេះ ទៅលើសំណួររបស់ឯកឧត្តម **សុន ឆ័យ** ទោះបីជាបានដឹងមុនថា ឯកឧត្តមមិនមានចេតនាចង់ស្តាប់ការពន្យល់បំភ្លឺនេះក៏ដោយ។ គោលដៅចម្បងនៅទីនេះ គឺការផ្តល់នូវការពន្យល់បូកសរុបគ្រប់ជ្រុងជ្រោយមួយអំពីគោលនយោបាយ និង កិច្ចខិតខំប្រឹងប្រែង ប្រកបដោយឆន្ទៈមោះមុត និង ក្នុងស្មារតីប្តូរប្តេជ្ញឥតងាករេ, របស់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយ

បញ្ហាព្រំដែនរវាងកម្ពុជា និង វៀតណាម ជូនដល់អង្គរដ្ឋសភាទាំងមូលជ្រាប, និង តាមរយៈអង្គរដ្ឋសភាដ៏ឧត្តុងឧត្តមនៃយើងនេះ ជូនដល់ប្រជាជនកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់ ទាំងនៅក្នុង និងក្រៅប្រទេសជ្រាប សំដៅជម្រះនូវភាពមិនច្បាស់លាស់ទាំងឡាយ នៅក្នុងកិច្ចការដ៏មានសារសំខាន់នេះ ក៏ដូចជារំលេចឲ្យឃើញផងដែរនូវគោលបំណង និងផលប្រយោជន៍នយោបាយនានា ដែលលាក់បង្កប់នៅពីក្រោយការចោទប្រកាន់ និងការឃោសនាញុះញង់ដដែលៗ ឥតឈប់ឈរ ពាក់ព័ន្ធនិងបញ្ហានេះ។

*សម្តេចចក្រី ប្រធានរដ្ឋសភា*
*ឯកឧត្តម លោកជំទាវ លោក លោកស្រី*

តទៅទៀតនេះ ដើម្បីអង្គរដ្ឋសភាទាំងមូល និងជនរួមជាតិគ្រប់រូបបានជ្រាបច្បាស់អំពីការពិត ខ្ញុំសូមអនុញ្ញាតធ្វើបទបង្ហាញ ស្តីពី **ការបោះបង្គោលខណ្ឌសីមាព្រំដែនគោក និងការកំណត់ព្រំដែនសមុទ្រ រវាងកម្ពុជា និង វៀតណាម** ដែលមានតាមលំដាប់លំដោយ ដូចខាងក្រោម៖

## I. អំពី ព្រំដែនគោក

## ទី១ - ទិដ្ឋភាពទូទៅ

យើងទាំងអស់គ្នាបានដឹង និង ចាំរត់មាត់គ្រប់គ្នាហើយថា ប្រទេសកម្ពុជាមានផ្ទៃដី ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា និងមានព្រំប្រទល់ជាប់ជាមួយនិងប្រទេសជិតខាងបី គឺប្រទេសឡាវ ប្រទេស វៀតណាម និង ប្រទេសថៃ។ ចំនួនផ្ទៃដីនេះ បើសិក្សាឲ្យល្អិតល្អន់ទៅ យើងនៅពុំទាន់ដឹងច្បាស់ថា តើគេគណនាតួលេខនេះ ឡើងតាមរបៀបណាទេ។ តាមការប៉ាន់ស្មាន ប្រហែលជាគេយកផ្ទៃក្រឡាដីនៃខេត្តទាំងអស់មកបូកបញ្ចូលគ្នាបានទៅជាផ្ទៃក្រឡាដីមួយ ដែលយើងដឹង និង ចេះចាំមាត់សព្វថ្ងៃនេះ។

ការគណនាកាលនោះ ប្រហែលជា ត្រូវបានធ្វើឡើងលើមូលដ្ឋានខ្សែព្រំដែនបន្សល់ទុកដោយអាណាព្យាបាលបារាំង ដែលបច្ចេកវិទ្យានៃការផលិតផែនទីព្រំដែននាពេលនោះ នៅមានកម្រិតអន់ថយនៅឡើយ ជាប្រភេទផែនទីចាស់យូរឆ្នាំ ហើយហានលេខា ក៏មានការប្រែប្រួលជាបន្តបន្ទាប់ ដែលបង្ករឲ្យមានភាពខុសគ្នារវាងផែនទី និង ដីជាក់ស្តែង។

ជាការពិត ជាមួយនិងភាពជឿនលឿននៃបច្ចេកវិទ្យា ការគណនាដោយប្រើកម្មវិធីកុំព្យូទ័រ លើមូលដ្ឋាននៃផែនទីដែលមានស្រាប់ បានផ្តល់ជាតួលេខទំហំផ្ទៃក្រឡានៃព្រះរាជាណាចក្រកម្ពុជាមួយចំនួនផ្សេងទៀត ដែលធំជាងតួលេខ ១៨១ ០៣៥ គីឡូម៉ែត្រក្រឡានេះទៅទៀត។ ខ្ញុំនឹងធ្វើការឆ្លុះបញ្ចាំងថែម ទៀតអំពីបញ្ហាតួលេខនេះ នៅក្នុងផ្នែកខាងក្រោម។

*នេះជាចំណោទមួយ នៃចំណោទនានាជាច្រើន សំរាប់ការដោះស្រាយទៅថ្ងៃក្រោយ។ ការបង្ហោះតាមវ៉ែបសាយត៍នៅក្នុងក្របខណ្ឌពិភពលោក ជាអង្គការសហប្រជាជាតិក្តី ឬអាស៊ានក្តី ផ្ទៃដីរបស់យើងមានកំណត់ត្រឹមតែ ១៨១.០៣៥ គីឡូម៉ែត្រការ៉េ ចំនួនប្រជាជន ១៤ ៤៧៨ ០០០ នាក់ GDP ក្នុងមួយនាក់ ៩៣១ ដុល្លារ។ ប៉ុន្តែ ឥឡូវនេះ តើយើងដោះស្រាយយ៉ាងម៉េច បើដីយើងវាលើសពីទំហំហ្នឹង។ ខ្ញុំនឹងប្រាប់តួលេខជាក្រោយ តែ បើតិចបំផុតក៏លើសជាង ៣០០ គីឡូម៉ែត្រការ៉េដែរ ដោយមិនទាន់គិតដីកោះ។ តើខ្មែរបាត់ដី ឬខ្មែរមានដីធំជាងដែលបានបង្ហោះជាព័ត៌មាន ទៅក្រៅប្រទេស និងកូនក្មេងកំពុងរៀន។ (រាប់ថាជា) សំណាង ដែលយើងមិនបានដាក់នៅក្នុងរដ្ឋ*

*ធម្មនុញ្ញរបស់យើង។*

*(ក្នុងសភាពដូចនេះ តើយើងគួរ) កាត់ផ្ទៃដីខ្លះគ្រវាត់ចោលឬ? ត្រង់នេះហើយ ដែលខ្ញុំព្រះករុណាខ្ញុំ សុំការយោគយល់ពីប្រជាពលរដ្ឋ រឿងដែលមិនគួរនិយាយ បែរជាមកនិយាយ។ ថ្ងៃក្រោយ យើងត្រូវសុំធ្វើការកែសម្រួលបញ្ហានេះ ទៅ អង្គការសហប្រជាជាតិ និងទៅកន្លែងដទៃទៀត បន្ទាប់ពីយើងធ្វើការវាស់វែងព្រំដែនរួច។ តើអ្នកណាលក់ដី អ្នកណាធ្វើឲ្យបាត់ដី បើដីវានៅច្រើនជាងអ្វីដែលយើងមាននៅក្នុងឯកសារ ដែលអស់លោកទន្ទេញទៅទៀតនោះ។ នេះជាចំណោទបញ្ហារបស់យើង។ រឿងនេះ ខ្ញុំមិនបន្ទោសអ្នកណានោះទេ ដោយសារយើងទាំងអស់គ្នាដឹងថាវាអីចឹងតាំងពីកើតមក ហើយរឿងនេះក៏យើងមិនអាចទៅបន្ទោសអ្នកនេះអ្នកនោះទេ គ្រាន់តែបញ្ជាក់ថា ពួកអគតិទាំងឡាយ ដែលចោទប្រកាន់ថាកម្ពុជាបាត់ដីរាប់រយរាប់ពាន់គីឡូម៉ែត្រការ៉េនោះ ឥឡូវម៉េចក៏ដីខ្មែរមានទំហំច្រើនជាង ដែលគេបានដឹង និងទន្ទេញចាំមាត់? តើវាជាការពិតទេ?*

## ទី២ - និដ្ឋភាពច្បាប់ និង ប្រវត្តិសាស្ត្រ

ជារួម បារាំង ក្នុងឋានៈជាអាណាព្យាបាលលើកម្ពុជាអស់រយៈពេល ៩០ ឆ្នាំ (**១៨៦៣-១៩៥៣**) បានបន្សល់ទុកឱ្យកម្ពុជានូវព្រំដែនមួយដែលមិនទាន់ច្បាស់លាស់នៅឡើយ ទាំងព្រំដែនគោក ទាំងព្រំដែន សមុទ្រ។ នៅក្នុងសម័យកាលនោះ ព្រំដែនរវាងកម្ពុជា-ថៃ ត្រូវបានទទួលស្គាល់ជាព្រំ

ដែនអន្តរជាតិ ដែល មានទាំងបង្គោលព្រំដែន ចំនួន ៧៣ ត្រូវបានបោះរួច នៅលើដី ដោយគណៈកម្មការចម្រុះកំណត់ព្រំដែន រវាងឥណ្ឌូចិន និង សៀម។ រីឯព្រំដែនកម្ពុជា-ឡាវ គឺជាព្រំដែនរដ្ឋបាលសុទ្ធសាធ ដែលត្រូវ បានកំណត់ ឡើងដោយសេចក្តីសម្រេចរបស់អគ្គទេសាភិបាលបារាំង នៅ ហាណូយ។

ចំពោះដែនដីកូសាំងស៊ីន គឺជាទឹកដីរបស់អាណានិគមបារាំង ហើយរដ្ឋបាលអាណាព្យាបាលបារាំងនៅកម្ពុជា គ្រាន់តែជារដ្ឋបាល ចំណុះឱ្យទេសាភិបាលបារាំងនៅកូសាំងស៊ីនតែប៉ុណ្ណោះ។ ព្រំដែនរវាង កម្ពុជា និង កូសាំងស៊ីន ត្រូវបានកំណត់ឡើងតាមសេចក្តីសម្រេចស្តីពីការ កំណត់ព្រំដែន ឆ្នាំ ១៨៧០ និង អនុសញ្ញាកំណត់ព្រំដែនឆ្នាំ ១៨៧៣ រវាង ព្រះមហាក្សត្រ ព្រះបាទ **នរោត្តម** ជាមួយនិងទេសាភិបាលកូសាំងស៊ីន ហើយថែមទាំងបានបោះបង្គោលព្រំដែននៅលើដី បានចំនួន ១២៤ បង្គោលទៀតផង **(បង្ហាញផែនទី)**។ ហេតុដូច្នេះហើយ យើងអាចចាត់ទុក បានថា ព្រំដែនកម្ពុជា-កូសាំងស៊ីន គឺជាព្រំដែនអន្តរជាតិ។ រីឯព្រំដែន កម្ពុជា-អាណ្ណាមវិញ ត្រូវបានធ្វើឡើងតាមសេចក្តីសម្រេចឯកតោភាគី ដោយមិនមានការឯកភាពពីកម្ពុជាទេ។ បន្ថែមពីលើនេះទៀត ក៏នៅពុំទាន់ មានបង្គោលព្រំដែនណាមួយ ត្រូវបានបោះនៅលើដីជាក់ស្តែងនៅឡើយ ដែរ។ ដូច្នេះ យើងអាចចាត់ទុកបានថា ព្រំដែនកម្ពុជា-អាណ្ណាម គឺជាព្រំ ដែនរដ្ឋបាល ប៉ុណ្ណោះ។

*ដោយហេតុនេះ កំណាត់ផែនទីរដ្ឋបាល តែនិញ បង្ហាញ ពីព្រំដែនទី ១ (៣៣) បានសេចក្តីថា ដែនដីកូសាំងស៊ីន ដែលរត់ នៅខាងដីកម្ពុជា គឺតំបន់កំពង់ចាម តភ្ជាប់ទៅកំពត ឯខាងវៀត*

*ណាម ចាប់ពីតៃនិញចុះទៅ ហាទៀង។ ឯចាប់ពី តៃនិញ ឡើងទៅ ដែនដីរបស់វៀតណាមខ្ញុំមិនស្គាល់ទេ តែខាងកម្ពុជា ពីខេត្តកំពង់ចាម ឡើងទៅដល់មុំបី ព្រំប្រទល់បីប្រទេស ដែលហៅថាតំបន់ត្រីកោណមាន កម្ពុជា ឡាវ និងវៀតណាម គឺរវាង កម្ពុជានិងអាណ្ណាម មានពីរផ្នែកខុសគ្នា។ ដូច្នេះ ម្ខាងរវាងកម្ពុជា និងកូសាំងស៊ីន អាចចាត់ទុកជាព្រំដែនអន្តរជាតិ ឯ កម្ពុជា និងអាណ្ណាម ពីតំបន់កំពង់ចាម ឡើងទៅ មុំបី ទៅក្រចេះ ទៅមណ្ឌលគីរី និងរតនគីរី គឺផ្នែកកម្ពុជា និងអាណ្ណាម គឺជាតំបន់ដែនដីរដ្ឋបាល។ សូម្បីតែផ្លូវជាតិលេខ ៧ ដែលឡាវ តវ៉ាមិនឲ្យធ្វើកន្ទុងទៅ គឺមានសេចក្តីបញ្ជាក់របស់អគ្គទេសាភិបាលឥណ្ឌូចិនអំពីបញ្ហាព្រំដែនហ្នឹង។ កាលហ្នឹងយើងអត់បានស្រាវជ្រាវ ឡាវក៏សុខចិត្តឲ្យយើងធ្វើផ្លូវទៅ ដោយយើងសុខចិត្តបន្ទូរបន្ថយស្អី។ ជាមួយគ្នា។*

*សូមមើលផែនទី បង្ហាញអំពីរដ្ឋបាល ចូរដុក។ គ្រឹះបង្គោល ១២៤ ដែលនៅសល់ខ្ទះ ហើយនៅផ្នែកខាងលើ រវាងអាណ្ណាម ជាមួយនិង តៃនិញ កំពង់ចាម និងឡើងដល់មុំបី។ តំបន់នេះ គឺជាតំបន់ ដែលហៅថា តំបន់រដ្ឋបាល មិនមែនជាព្រំដែនទេ។*

ដូច្នេះ អ្វីដែលកម្ពុជាទទួលបាននៅពេលដែលអាណាព្យាបាលរបស់បារាំង <u>ត្រូវបានបញ្ចប់នៅឆ្នាំ ១៩៥៣ គឺខ្សែបន្ទាត់ព្រំដែនមួយដែល</u>

មិនច្បាស់លាស់ និង ពុំទាន់មានការបោះបង្គោលព្រំដែនឱ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់ ក៏ដូចជាតាមបែបបទបច្ចេកទេសនៅឡើយ ក្រៅពីបង្គោលព្រំដែនចំនួន ១២៤ ដែល អាណាព្យាបាលបារាំងបានបោះរវាងកម្ពុជា និងកូសាំងស៊ីន នាសតវត្សរ៍ទី ១៩ និង ដើមសតវត្សរ៍ទី២០។ បន្ថែមទៅលើនេះទៀត អាណាព្យាបាលបារាំងបានធ្វើការផ្លាស់ប្តូរទីតាំងបង្គោលព្រំដែនមួយចំនួន និង កែខ្សែព្រំដែនជាច្រើនលើកច្រើនសារ ដោយពុំបានធ្វើការពិគ្រោះយោបល់ និងបានការឯកភាពពីប្រទេសដែលខ្លួនគ្រប់គ្រងនោះឡើយ។ ការពុំបានដឹង ឬស្គាល់ច្បាស់ពីព្រំដែនរបស់ខ្លួននេះ បានក្លាយទៅជាមូលហេតុចម្បងមួយ ដែលនាំឱ្យមានជម្លោះព្រំដែនមិនចេះចប់មិនចេះហើយ រវាងអាជ្ញាធរមូលដ្ឋាននៃប្រទេសទាំងពីរ ក៏ដូចជារវាងប្រជាជនកម្ពុជា និង ប្រជាជនវៀតណាម ដែលពុំបានដឹងពីការកែសម្រួលផ្លាស់ប្តូរខ្សែព្រំដែន នេះ ហើយនៅតែបន្តការគ្រប់គ្រងកាន់កាប់ប្រើប្រាស់ដីធ្លីរៀងៗ ខ្លួន តាមទំនៀមទម្លាប់ដែលមានពីមុនៗ មកនោះ។

*អ្វីជាទម្លាប់គ្រប់គ្រងពីមុន នៅតែគ្រប់គ្រងអញ្ចឹងទៅ។ បារាំងគូសដោយបារាំងទៅ ហើយ បារាំងក៏មិនបានពិគ្រោះជាមួយខ្មែរ។ មានមហាក្សត្រខ្មែរណាចង់ឲ្យបាត់បង់ទឹកដី លើកលែងតែមួយជំនាន់ ដែលគេថា* ***ព្រះជ័យជេដ្ឋាទី ២*** *។ គ្មានអ្នកណាមួយចង់ឲ្យបាត់បង់ទឹកដីទេ តែធ្វើម៉េចបើនៅក្រោមអំណាចគេ ហើយម្យ៉ាងទៀត បើទោះបីគេមកពិគ្រោះ ក៏បានត្រឹមតែពិគ្រោះជាមួយនិងរដ្ឋបាលនៅខាងលើ គឺព្រះមហាក្សត្រ ឬព្រះរាជា ឧបរាជអីពេលនោះ ប៉ុន្តែសួរថា តើប្រជាពលរដ្ឋនៅឯមូលដ្ឋានបានដឹងទេ? ខ្សែព្រំដែនពិតប្រាកដនៅឯណា រវាងខ្សែព្រំ*

*ដែនដែលមាននៅលើផែនទី និងការរស់នៅជាក់ស្តែងរបស់ប្រជាពលរដ្ឋ? នោះជាបញ្ហាដែលកើតមិនចេះចប់មិនចេះហើយ។*

*វាជាមរតកប្រវត្តិសាស្ត្រ ដែលកម្ពុជាបានទទួលពីអាណាព្យាបាលបារាំង ហើយត្រូវទទួលបន្ទុកដោះស្រាយដោយខ្លួនឯងជាបន្តទៅទៀត បន្ទាប់ពីបារាំងចាកចេញពីឥណ្ឌូចិន។ ឥឡូវយើងចោទជាសំណួរថា បន្ទាប់ពីបានឯករាជ្យហើយ តើសម្តេចព្រះ* **នរោត្តម សីហនុ** *ព្រះអង្គមានព្រះរាជតំរិះយ៉ាងម៉េច ឬបើយើងជាព្រះអង្គនៅពេលនោះ តើត្រូវចាប់ផ្តើមពីកន្លែងណា ត្រូវឈរលើមូលដ្ឋានអ្វី? ចាប់ផ្តើមពីការចំណាំរបស់ប្រជាពលរដ្ឋហើយដើរចង្អុល ឬចាប់ផ្តើមពីផែនទី និងសេចក្តីសម្រេចនានាដែលអគ្គទេសាភិបាលបារាំងបានបន្សល់ទុក? តើចាប់ផ្តើមពីអ្វី? ករណីនេះដូចជា សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ដូច្នេះដែរ តើត្រូវចាប់ផ្តើមពីអ្វី ចាប់ផ្តើមពីមរតកដែលបន្សល់ទុកដោយច្បាប់ ឬប្រើកម្លាំង ដើម្បីសើរើទល់ដែន? វាគឺជាបញ្ហាប្រឈមសម្រាប់មេដឹកនាំប្រទេស មិនថាប្រទេសណា ឬប្រទេសណាទេ នៅលើពិភពលោកនេះ រាប់ទាំងស៊ូដង់ខាងជើង និងស៊ូដង់ខាងត្បូង ដែលទើបតែបំបែកចេញពីគ្នា ក៏ចាប់ផ្តើមទាស់គ្នាតាមទល់ដែនទៀតហើយ កុំថាឡើយតែយើង ដែលបានស្ថិតក្រោមសហព័ន្ធឥណ្ឌូចិនរបស់បារាំង។*

*អស់លោកសុទ្ធតែចោទបក្សកុំមុយនីស្តឥណ្ឌូចិន ចង់បង្កើតសហព័ន្ធឥណ្ឌូចិន តែ តើអ្នកណាជាអ្នកធ្វើសហព័ន្ធឥណ្ឌូចិន? (មិន)គឺបារាំង។ អគ្គទេសាភិបាលបារាំងនៅហាណូយ គ្រប់គ្រងប្រទេសដល់ទៅបី។ កម្ពុជាគ្រាន់តែជាសួនច្បារក្រោយផ្ទះរបស់វៀតណាមទេ។ នៅភ្នំពេញ វត្តភ្នំគេដាក់ត្រឹមទេសាភិបាលទេ គឺស្មើនឹងខេត្តមួយរបស់វៀតណាមតែប៉ុណ្ណោះ។ បើសិនយើងជាមនុស្ស និងមិនមែនជាសត្វ ត្រូវតែដឹងពីប្រវត្តិសាស្ត្រខ្លួនឯង។ និយាយដូច្នេះ មិនមែនខ្ញុំចោទអស់លោកថាជាសត្វទេ តែការសរសេរ (របៀបក្លែងបន្លំ) អញ្ចឹងៗ នេះ សមជាសត្វ។ ប៉ុន្តែប្រសិនជាអស់លោកស្ថិតនៅក្នុងក្រុមហ្នឹងដែរ ក៏ប្រហែលជាត្រូវដែរ។ តិរច្ឆាន មិនដូចមនុស្សទេ។*

នេះគឺជាមរតកប្រវត្តិសាស្ត្រ ដែលកម្ពុជាទទួលបានពីអាណាព្យាបាលបារាំង ហើយត្រូវទទួលបន្ទុកដោះស្រាយដោយខ្លួនឯងបន្តទៅទៀត បន្ទាប់ពីបារាំងបានចាកចេញពីឥណ្ឌូចិនទៅ។

ក្រោយពីកម្ពុជាទទួលបានឯករាជ្យភ្លាម ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** បាន ដឹកនាំចលនាជាតិដ៏ខ្លាំងក្លាមួយ ដើម្បីអំពាវនាវឱ្យសហគមន៍អន្តរជាតិទទួលស្គាល់ព្រំដែនកម្ពុជា ដោយឈរលើគោលការណ៍ ***"ខ្សែព្រំដែនមិនកែប្រែ"*** (Uti Possidetis)។ ជាការពិត គោលការណ៍ខ្សែព្រំដែនមិនកែប្រែនេះ មានសារសំខាន់ខ្លាំងណាស់ សម្រាប់ការបន្តដោះស្រាយបញ្ហាព្រំដែនដ៏ស្មុគស្មាញរវាង បណ្តាប្រទេសនៅក្នុងអតីតឥណ្ឌូចិន ពីព្រោះវាជួយបញ្ចៀស បាននូវសង្គ្រាមដែលអាចកើត

ឡើងដោយ បញ្ហាទំនាស់ព្រំដែននេះ បើទោះជាមានមតិខ្លះមិនទទួលយកគោលការណ៍នេះក៏ដោយ។ ជាទូទៅ ប្រទេសជាច្រើនដែលបានរួចផុតពីរបបអាណានិគម ហើយត្រូវជួបប្រឈមនិងបញ្ហាព្រំដែនដូចនេះ តែងតែទទួលយកគោលការណ៍ដ៏មានសារសំខាន់នេះមកអនុវត្ត ដើម្បីបន្តដោះស្រាយបញ្ហាព្រំដែនជាមួយគ្នា ដោយរក្សាបាននូវសុខសន្តិភាព និងទំនាក់ទំនងជាអ្នកជិតខាងល្អជាមួយគ្នា។

ជាលទ្ធផល ជម្លោះលើការជ្រើសរើសយកគោលការណ៍ខ្សែព្រំដែនមិនកែប្រែរវាងកម្ពុជា និង វៀតណាម ត្រូវបានបញ្ចប់នៅឆ្នាំ ១៩៦៤ នៅពេលដែលសម្តេចព្រះ **នរោត្តម សីហនុ** ព្រះប្រមុខរដ្ឋនាពេលនោះ បានយកផែនទីបោន (Bonne) ខ្នាត ១/១០០ 000 បោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន ទៅ តម្កល់ទុកនៅអង្គការសហប្រជាជាតិ ហើយតាមរយៈនេះ ព្រះអង្គបានអំពាវនាវឱ្យមានការធានារ៉ាប់រងពីសំណាក់មហាអំណាចនានា ក្នុងការគោរពបូរណភាពទឹកដីកម្ពុជាតាមផ្លូវច្បាប់អន្តរជាតិ និងឱ្យទទួលស្គាល់ ព្រមទាំងគោរពឯករាជ្យ, អព្យាក្រឹត្យភាព, បូរណភាពទឹកដីកម្ពុជា ក្នុងរង្វង់ខ្សែព្រំដែនបច្ចុប្បន្ន ដោយបានប្រកាសដាច់ខាតថាមិនអាចរុះរើ និង កែប្រែបានឡើយ។ ក្រោមការអំពាវនាវនេះ ប្រទេសជាច្រើន ជាពិសេសគឺប្រទេសសាមីដែលមានការពាក់ពន្ធ័ បានប្រកាសទទួលស្គាល់ និង សន្យាគោរពបូរណភាពទឹកដីកម្ពុជាក្នុងរង្វង់ខ្សែព្រំដែនបច្ចុប្បន្ន **(បង្ហាញផែនទី)**។

*នេះហើយគឺជាខ្សែព្រំដែនមិនកែប្រែ ហើយដែលតម្កល់ទុកនៅអង្គការសហប្រជាជាតិ ឆ្នាំ ១៩៦៤។ វាជាជម្រើសមួយដែលបន្សល់ទុកឲ្យយើងមកដល់ថ្ងៃនេះ។ សូមបញ្ជាក់ថា តើ*

*មានអ្នកណាស្នេហាជាតិជាងសម្តេចព្រះ* **នរោត្តម សីហនុ** *ទៀត? ហេតុអ្វី បានជាព្រះអង្គ ដោយមាន ឯកឧត្តម* **ទ៉ា គីម ហុង** *ពេលនោះ ជាមនុស្សម្នាក់ ក្នុងចំណោមមនុស្សដែលនៅសល់ ត្រូវបង្ខំចិត្តរៀបចំឯកសារផែនទីទាំងយប់ឲ្យ* **ហួត សម្បត្តិ** *ចុះហត្ថលេខា ដើម្បីយកទៅតម្កល់នៅអង្គការសហប្រជាជាតិ។ ផែនទីដែលយើងប្រើបច្ចុប្បន្ន ជាមួយព្រំដែនវៀតណាម គឺផែនទីហ្នឹងឯង តើមានអ្វីខុសទៅ។ អញ្ចឹងអស់លោកវាយខ្ញុំ មានតម្លៃស្មើនឹងវាយ សម្តេចព្រះ* **នរោត្តម សីហនុ** *ទេ ឬក៏ជំងឺឆ្នាំ ១៩៧០ វាកើតឡើងវិញ ដើម្បីផ្តួលរំលំរាជបល្ល័ង្កតែម្តង? ប៉ុន្តែអស់លោកត្រូវកន្ធងសពរបស់ខ្ញុំសិន ទើបអាចឈានដល់រាជបល្ល័ង្កបាន។*

ទន្ទឹមនឹងនេះ ក៏គួរកត់សម្គាល់ផងដែរថា បន្ទាប់ពីកម្ពុជាប្រកាសទទួលយកគោលការណ៍ "***ខ្សែព្រំដែនមិនកែប្រែ***" នៅពេលដែលកម្ពុជាបានឯករាជ្យនាឆ្នាំ ១៩៥៣ និងបន្ទាប់ពីកម្ពុជាបានយកផែនទីទៅ តម្កល់នៅអង្គការសហប្រជាជាតិ និង ប្រកាសឱ្យអន្តរជាតិទទួលស្គាល់នោះមក សិទ្ធិទាមទារទឹកដីដូនតា នៅកម្ពុជាក្រោមនោះ ក៏ត្រូវបានផុតរលត់ទៅដែរ ដោយសារថា កូសាំងស៊ីន (ទឹកដីកម្ពុជាក្រោម) ត្រូវបាន កំណត់ថាជាទឹកដីរបស់វៀតណាមរួចអស់ទៅហើយ តាមរយៈសេចក្តីសម្រេចស្តីពីការកំណត់ព្រំដែនឆ្នាំ ១៨៧០ និង អនុសញ្ញាកំណត់ព្រំដែនឆ្នាំ ១៨៧៣ ហើយថែមទាំងបានបោះបង្គោលព្រំដែននៅលើដី បានចំនួន ១២៤ បង្គោលទៀតផង ដូចបានជម្រាបជូនពីខាងលើ។

ត្រង់កន្លែងនេះខ្ញុំសូមបញ្ជាក់ ហើយខ្ញុំនឹងបញ្ជាក់នៅពេលជាបន្តទៅទៀតថា នៅពេលដែលយើងបានយកផែនទីទៅតម្កល់នៅអង្គការសហប្រជាជាតិ លើបញ្ហាទាក់ទងនិងខ្សែព្រំដែនមិនកែប្រែ សិទ្ធិទាមទារទឹកដីពីដូនតានៅកម្ពុជាក្រោមត្រូវបានផុតរលត់ទៅហើយ ព្រោះយើងបានអំពាវនាវឲ្យទទួលស្គាល់ព្រំដែនបច្ចុប្បន្ន។ នៅពេលដែលយើងយកផែនទីទៅតម្កល់នៅអង្គការសហប្រជាជាតិ ដោយសុំយក ligne ប្រេវីយ៉េ ធ្វើជាព្រំដែនសមុទ្រ សិទ្ធិទាមទារយកកោះត្រល់ និងកោះដទៃទៀតក៏ផុតរលត់ទៅដែរ។ ដោយហេតុនេះ អ្វីដែលឯកឧត្តមគ្រោងនឹងសួរខ្ញុំនោះ ហាក់ដូចជាត្រូវបានគ្របដណ្តប់រួចហើយ ហើយអាចថែមទាំងលើសពីអ្វីដែលឯកឧត្តមចង់សួរទៅទៀត ពេលខ្ញុំថែមអត្ថាធិប្បាយនៅខាងក្រោម។ ប៉ុន្តែចំណុចនេះ ខ្ញុំសូមបញ្ជាក់ យើងអត់អាចដាក់កំហុសទៅសម្តេចព្រះ **នរោត្តម សីហនុ** ថាព្រះអង្គបានធ្វើឲ្យបាត់បង់ទឹកដី បាត់បង់នូវសិទ្ធិទាមទារយកកោះ និងបាត់បង់សិទ្ធិទាមទារយកដីកម្ពុជាក្រោមទេ។ គ្មានជម្រើសណាឲ្យល្អជាងជម្រើស ដែលសម្តេចព្រះ **នរោត្តម សីហនុ** បានបូជាធ្វើព្រះរាជបូជនីយ៍កិច្ចទាមទារយកឯករាជ្យ ហើយបន្តការតស៊ូដើម្បីការពារទឹកដីដែលបន្សល់ទុកនោះទេ។ (ការធ្វើ) បានប៉ុណ្ណឹងវាជាការល្អណាស់ទៅហើយ។ ទាំងអស់គ្នា ហៅព្រះអង្គថា ព្រះបិតាឯករាជ្យជាតិ។ មានតែពួក **លន់ នល់** ទេ ដែលតាំងខ្លួនជា

*អ្នកស្នេហាជាតិ ហើយបន្តិចទៀតខ្ញុំនឹងនិយាយពីពួក* ***លន់ នល់*** *ដែលធ្វើឲ្យបាត់បង់កោះត្រល់។*

*ពួកអ្នកកាន់ផែនទីរត់ ថ្ងៃមុនបានបញ្ជាក់មកថាកោះត្រល់មិនដែលបាត់។ ចាំមើលផែនទីទាក់ទងនឹងសមុទ្ររបស់ពួក ធីវគីយ៉ាងម៉េច ហើយហេតុអ្វីបានជាចាំបាច់មានតំបន់ទឹកប្រវត្តិសាស្ត្រ។ ខ្ញុំនឹងពន្យល់ឲ្យក្មួយក្មេកទាំងអស់គ្នានៅថ្ងៃនេះ។ ពិតមែនថាសិទ្ធិទាមទារ ត្រូវបានបាត់បង់ហើយ តែយើងមិនត្រូវបន្ទោសចំពោះសម្តេចព្រះ* ***នរោត្តម សីហនុ*** *ទេ ព្រោះមានមូលហេតុនៅក្នុងនោះ។ ណាមួយសេចក្តីសម្រេចរបស់បារាំង ណាមួយបោះផែនទី ហើយក៏មានការប្រជុំសការរបស់បារាំងទៅទៀត។ ដែល កូសាំងស៊ីន បានបាត់បង់ទាំងស្រុងនៅឆ្នាំ ១៩៤៩, ឯខ្ញុំកើតនៅឆ្នាំ ១៩៥២, ខ្ញុំកោតតែអស់លោកហាមាត់ជេរខ្ញុំទៅរួច។ បើលោកមិនខ្មាសគេ លោកគួរខ្មាសខ្លួនឯងខ្លះផង ព្រោះយើងជាក្មេង(ជំនាន់ក្រោយ)ដូចគ្នាទេតើ។*

ចំណេរតមកទៀត រដ្ឋាភិបាលក្នុងរបបជាបន្តបន្ទាប់ដែលគ្រប់គ្រងកម្ពុជា បានបន្តទទួលយកគោលការណ៍ ***"ខ្សែព្រំដែនមិនកែប្រែនៅពេលដែលកម្ពុជាបានឯករាជ្យ"*** មកអនុវត្តក្នុងការរកដំណោះស្រាយព្រំដែនរវាងកម្ពុជា ជាមួយនិងប្រទេសជិតខាងទាំងបី លើកលែងតែរបបសាធារណរដ្ឋខ្មែរ ដឹកនាំដោយលោកសេនាប្រមុខ **លន់ នល់** មួយប៉ុណ្ណោះ ដែលបានបន្តយកគោលការណ៍ខ្សែព្រំដែនមិនកែប្រែនេះ មកអនុវត្តន៍ចំពោះតែព្រំដែន

គោក រីឯព្រំដែនសមុទ្រវិញ សាធារណរដ្ឋខ្មែរបានគូសខ្សែថ្មីមួយ ដោយព័ទ្ធយកទាំងកោះត្រល់ និង កោះថូជូ ព្រមទាំងទឹកសមុទ្រមួយចំនួនទៀតបន្ថែមក្នុងទឹកដីកម្ពុជា ដែលយើងហៅខ្សែនោះថា ***«ខ្សែឆ្នាំ ១៩៧២»***។ ដូចយើងបានឃើញស្រាប់ ការញុះញង់បង្កើតស្មារតីជាតិនិយមជ្រុល និងបំណងសើរើព្រំដែនដែលជាមរតកប្រវត្តិសាស្ត្រ ដោយគ្មានការទទួលខុសត្រូវ ដែលក្រុមអ្នកនយោបាយសាធារណរដ្ឋ ដឹកនាំដោយសេនាប្រមុខ **លន់ នល់** បានបំផុសឡើងនោះ មិនបានផ្តល់ផលល្អអ្វីដល់ប្រទេសជាតិ និង ប្រជាជនកម្ពុជា ក្រៅពីភ្នក់ភ្លើងសង្គ្រាម និង ការវិនាសហិនហោចនោះទេ។ នេះគឺជាមេរៀនប្រវត្តិសាស្ត្រដ៏សំខាន់មួយ ដែលអ្នកនយោបាយជំនាន់ក្រោយ, រួមបញ្ចូលទាំង ឯកឧត្តម **សុន ឆ័យ** និង សហសេរីក ព្រមទាំងមជ្ឈដ្ឋានមួយចំនួនទៀតផងដែរ ដែលមិនទាន់បានបោះបង់ចោលនូវគំនិតនេះ, ត្រូវដកស្រង់យកមកធ្វើជាបទពិសោធន៍ ប្រសិនបើគេចង់ចូលរួមក្នុងកិច្ចដំណើរការនយោបាយក្នុងប្រទេស ប្រកបដោយការទទួលខុសត្រូវខ្ពស់ និង ក្នុងស្មារតីស្ថាបនា និង ស្នេហាជាតិពិតប្រាកដ។

*ខ្ញុំសូមនិយាយពីខ្សែព្រំដែនរបស់ពួក ធីវគី វិញ (ឬខ្សែ ៧១) រួចហើយពេលក្រោយយើងនឹងបង្ហាញទៀត។ ខ្សែពណ៌ខៀវ (លើផែនទី បង្ហាញថា) គេយកកោះវៃបាត់ទៅហើយ។ (សូមជំរាប) លោក* ***ស៊ាង ម៉េងសេ*** *ថា ខ្ញុំអាចគូសបានជំជាងលោក ប៉ុន្តែលើការជាក់ស្តែង ធីវគី បានគូស និងមកយកទាំងកោះហ្នឹងទៅទៀត។ ម៉េចលោកឯងមិនយក (ពេលនោះ) ហេតុអ្វីលោកឯងចាំបាច់រត់។ តើលោកដឹងទេ ខ្សែបន្ទាត់ ៧១ របស់ធីវគី ហើយលោកឯងដឹងទេច្បាប់ប្រេងកាតឆ្នាំ ១៩៧០ របស់ពួក*

*ធីវគី? តើលោកដឹងទេ ដែលពួក ធីវគី ដាក់ទ័ពបណ្តេញក្រុមហ៊ុន ELF ចេញ ក្នុង រយៈពេល ១៤ ថ្ងៃ ឬលោករវល់ឈ្លក់វង្វេងនិងស្រីក្មេងៗ ខ្សែពណ៌លឿង គឺផែនទីដែលត្រូវបានគូសឲ្យតែខាងធំ (ដោយរបប* **លន់ នល់**)*។ សំរាប់កោះវ៉ៃ យើងបានត្រឹមតែគូសផែនទីនៅភ្នំពេញ តែពួកគេបានបញ្ជូនកប៉ាល់ និងទ័ពចូលមក។ ឯចំពោះខ្សែពណ៌ក្រហមនេះ គឺជាតំបន់ទឹកប្រវត្តិសាស្ត្រ ដែលខ្ញុំនឹងបញ្ជាក់ជូនអំពីមូលហេតុនៅផ្នែកខាងក្រោម ហើយខ្ញុំសង្ឃឹមថា នឹងមានការព្យាយាមស្តាប់ទាំងអស់គ្នា ដោយយោគយល់។*

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំទៅនាខែ មករា ឆ្នាំ ១៩៧៩ និង ដោយផ្អែកលើបទពិសោធន៍ នៃការឆ្លងកាត់របបនយោបាយជាច្រើន នៅក្នុងរយៈពេលចុងក្រោយនេះនៃប្រវត្តិសាស្ត្ររបស់ប្រទេសជាតិ កម្ពុជាពិតជាគ្មានជម្រើសអ្វីល្អប្រសើរជាងការទទួលយក ***«គោលការណ៍ខ្សែព្រំដែនមិនកែប្រែនៅពេល កម្ពុជាបានឯករាជ្យ»*** នេះ មកអនុវត្តនោះទេ។ គឺមានតែគោលការណ៍នេះមួយគត់ ដែលអាចជួយឱ្យ កម្ពុជាអាចធានាបាននូវបូរណភាពទឹកដីរបស់ខ្លួនដែលបានរង្គោះរង្គើដោយសារសង្គ្រាមស៊ីវិលរ៉ាំរ៉ៃកន្លងមក។

*ខ្ញុំសូមបញ្ជាក់ថា ទាំងផែនទីសមុទ្រទាំងផែនទីគោក យើងបាន និងកំពុងបន្តធ្វើទៅមុខតាមមរតក ដែល សម្តេចព្រះ* **នរោត្តម សីហនុ** *បានបន្សល់ទុកតែប៉ុណ្ណោះ គឺគោលការណ៍ព្រំដែនមិនកែប្រែនៅពេលបានឯករាជ្យ ដែលតម្កល់នៅអង្គការសហប្រជាជាតិ ហើយដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ដែលខ្ញុំនឹងបក*

*ស្រាយបន្តិចទៀត។ តើយើងត្រូវយកផែនទីមួយណា(មកកំណត់)ព្រំដែនសមុទ្រ? អ្វីដែលល្អវិសេសនោះ គឺសម្តេចព្រះ* **នរោត្តម សីហនុ** *បានយកទៅតម្កល់ទុកនៅអង្គការសហប្រជាជាតិ នូវផែនទីព្រំដែនទាំងគោកទាំងទឹក ជាមួយថៃ និង ជាមួយវៀតណាម។*

លើមូលដ្ឋាននៃមរតកប្រវត្តិសាស្ត្រដ៏លំបាកស្មុគស្មាញនេះ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជានាពេលនោះ បានចុះកិច្ចព្រមព្រៀង និង សន្ធិសញ្ញាដែលទាក់ទងទៅនឹងព្រំដែនគោកចំនួន ៣ ជាមួយនិងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលខ្ញុំសូមធ្វើការពន្យល់ជូនដោយសង្ខេបនាពេលនេះ គឺ៖

**- សន្ធិសញ្ញាស្តីពីគោលការណ៍ដើម្បីដោះស្រាយព្រំដែនគោក និងលក្ខន្តិកៈព្រំដែន ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៨៣៖**

ស្របតាមឯកសារទាំងពីរនេះ ភាគីទាំងសងខាងបានចាត់ទុកព្រំដែនមានរួចមកហើយ ដែលគូសនៅ លើផែនទីខ្នាត ១/១០០ ០០០ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន ដាក់ឱ្យប្រើប្រាស់មុនឆ្នាំ ១៩៥៤ ឬនៅកាលបរិច្ឆេទកៀកបំផុតទៅនឹងឆ្នាំ ១៩៥៤ ថាជាព្រំដែនរដ្ឋរវាងប្រទេសទាំងពីរ។ ការកំណត់យកនេះ ស្របទៅនិងគោលការណ៍ច្បាប់អន្តរជាតិស្តីពី ***«ខ្សែព្រំដែនមិនកែប្រែ»*** ហើយវាស្របទៅនិងផែនទីដែលសម្តេច ព្រះ **នរោត្តម សីហនុ** បានតម្កល់ទុកនៅអង្គការសហប្រជាជាតិ នាឆ្នាំ ១៩៦៤។

*ខ្ញុំសូមបញ្ជាក់ជូនបន្តិចថា ដោយសារតែយើងមានចំណុចខ្សោយក្នុងរដ្ឋធម្មនុញ្ញខ្លួនឯង, យើងកំពុងប្រើប្រាស់នូវ*

សន្ធិសញ្ញាជាមួយវៀតណាម ដើម្បីចរចាជាមួយវៀតណាមឡើងវិញ។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានចំណុចខ្សោយនៅកន្លែងណាខ្លះ? **មាត្រា ទី ២** ចែងថា "បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានជាដាច់ខាត ក្នុងព្រំដែនរបស់ខ្លួន ដែលមានកំណត់ក្នុងផែនទីខ្នាត ១/១០០ ០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៥៣ ហើយត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះឆ្នាំ ១៩៦៣-១៩៦៩"។ សូមបញ្ជាក់ថា ខ្ញុំមិនទាន់និយាយពីការធ្វើរបងតែម្ខាងទេនៅទីនេះ។ យើងនឹងមានការបកស្រាយនៅផ្នែកខាងក្រោម។ ប៉ុន្តែ ដើម្បីចរចាជាមួយវៀតណាមបន្ត ហើយកុំឲ្យមានចំណុចខ្សោយ យើងប្រើប្រាស់សន្ធិសញ្ញាព្រំដែនគោកជាមួយនិងវៀតណាម ព្រោះបានដាក់កាលបរិច្ឆេទថា បោះពុម្ពនៅមុនឆ្នាំ ១៩៥៤ ឬកាលបរិច្ឆេទកៀកបំផុតនឹងឆ្នាំ ១៩៥៤។ ឯនៅក្នុងរដ្ឋធម្មនុញ្ញរបស់យើងបានកំណត់ត្រឹមតែឆ្នាំ ១៩៣៣ ទេ។ បើពេលនោះ យើងសរសេរថាបោះពុម្ពមុនឆ្នាំ ១៩៥៣ និងកុំដាក់ឆ្នាំ ១៩៣៣ (ប្រហែលមិន) ចងដៃខ្លួនឯងទេ។ សាធារណរដ្ឋប្រជាមានិតកម្ពុជា ទោះបីលោកឯងចោទជាអាយ៉ង ក៏នៅក្នុងកិច្ចព្រមព្រៀងយើងខ្ញុំបាននិយាយយ៉ាងច្បាស់ថា ផែនទីខ្នាត ១/១០០.០០០ បោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន មុនឆ្នាំ ១៩៥៤ ដូចក្នុងរដ្ឋធម្មនុញ្ញអញ្ចឹង។ បើមុនឆ្នាំ ១៩៥៤ ទាញទៅដល់ឆ្នាំ ១៨០០

*ក៏បានដែរ។ មានកន្លែងខ្លះយើងទាមទារឲ្យវៀតណាមធ្វើការកែប្រែ មានដូចជា ដាក់ដាង ដាក់ហ៊ូត តាំងពីឆ្នាំ ១៩១៤។ ឥឡូវយើងមិនអាចប្រើរដ្ឋធម្មនុញ្ញ(ក្នុងការចរចា)បានទេ ហើយ ខាងភាគីវៀតណាម ក៏មិនត្រូវយល់ថា (ប្រើ)រដ្ឋធម្មនុញ្ញនេះចង់ដែកម្ពុជា មិនឲ្យនិយាយមុនឆ្នាំ ១៩៣៣ ដែរ។ កិច្ចព្រមព្រៀងរវាងកម្ពុជា-វៀតណាម ដាក់ការបោះពុម្ពមុនឆ្នាំ ១៩៥៤ ឬកាលបរិច្ឆេទកៀកបំផុតមុនឆ្នាំ ១៨៧០ ក៏បានដែរ ខ្ញុំជូនសារទុកឲ្យ។*

*ការពិតគួរតែត្រូវបានបិទបាំង ប៉ុន្តែអស់លោកបានបង្ខំឲ្យខ្ញុំនិយាយ ព្រោះលោកតាំងខ្លួនជាអ្នកស្នេហាជាតិ។ បើខ្ញុំមិននិយាយឲ្យអស់ទេ អស់លោកនឹងនៅតែមិនយល់, ហើយសង្ឃឹមថា អស់លោកនៅតែបន្តមិនយល់ទៀតថ្ងៃនេះ។ សង្ឃឹមថា វៀតណាម នឹងគោរពនូវការសន្យារបស់ខ្លួនដែលចុះហត្ថលេខាដាក់កាលបរិច្ឆេទមុនឆ្នាំ ១៩៥៤ ដោយមិនមានកំណត់ថាត្រឹមឆ្នាំ ១៩៣៣ ទេ។ បានសេចក្តីថា អ្វីយើងអាចរកឃើញទាក់ទង ដាក់ដាង ដាក់ហ៊ូត ឆ្នាំ ១៩១៤ គឺកិច្ចព្រមព្រៀងនោះអាចយកមកប្រើបាន។ ដូច្នេះ កិច្ចព្រមព្រៀងនេះ បំពេញឲ្យរដ្ឋធម្មនុញ្ញទៅវិញទេ ដែលវាមិនដូចអស់លោកចោទយើងខ្ញុំថាជាអាយ៉ងនោះឯណា។*

**សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ ១៩៨៥៖**

សន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ ១៩៨៥ នេះ បានយកគោល

ការណ៍ដូចដែលបានកំណត់ក្នុងសន្ធិសញ្ញា ឆ្នាំ ១៩៨៣ ខាងលើ ដោយយកផែនទីខ្នាត ១/១០០ ០០០ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន និង ផែនទី UTM ខ្នាត ១/៥០ ០០០ ដែលគូសខ្សែព្រំដែនចេញពីផែនទី Bonne ខ្នាត ១/១០០ ០០០ SGI ធ្វើជាមូលដ្ឋានក្នុងការកំណត់ខ្សែព្រំដែនដីគោករវាងប្រទេសទាំងពីរ។ សន្ធិសញ្ញានេះ គឺជាការបន្តអនុវត្តដោយឥតងាករេ តាមគោលការណ៍ច្បាប់អន្តរជាតិស្តីពី ***«ខ្សែព្រំដែនមិនកែប្រែ»*** និង តាមបណ្តាផែនទី ដែលត្រូវបានប្រកាន់យកដោយសម្តេចព្រះ **នរោត្តម សីហនុ** ក្រោយពេលដែលកម្ពុជាបានចាកផុតពីអាណាព្យាបាលបារាំងមក។

យ៉ាងណាក៏ដោយ កិច្ចព្រមព្រៀង និងសន្ធិសញ្ញាព្រំដែនទាំងអស់ខាងលើនេះ នៅតែត្រូវបានក្លាយ ទៅជាកម្មវត្ថុនៃការចោទប្រកាន់ពីសំណាក់ ក្រុមអ្នកនយោបាយដែលបានប្រកាសខ្លួនជា «**អ្នកស្នេហាជាតិ**» ពិតប្រាកដនោះ ថាបានធ្វើឱ្យកម្ពុជាបាត់បង់ទឹកដី ទាំងព្រំដែនគោក និង ព្រំដែនសមុទ្រ ហើយ សំអាងលើមូលហេតុនេះ គេបានស្នើឱ្យរាជរដ្ឋាភិបាលបច្ចុប្បន្ន លុបចោលសុពលភាពនៃកិច្ចព្រមព្រៀង និង សន្ធិសញ្ញាព្រំដែនទាំងអស់នោះ។ ចំណុចនេះ បើក្រឡេកមើលភ្លាមទៅឃើញថា អ្នកដែលបានលើកសំណើនេះ មានគំនិតចង់វាយប្រហារខាងនយោបាយ ទៅលើរដ្ឋាភិបាលអតីតសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលជាអ្នកចុះហត្ថលេខាលើកិច្ចព្រមព្រៀង និង សន្ធិសញ្ញាព្រំដែនទាំងអស់នេះ។ ក៏ប៉ុន្តែ បើពិនិត្យមើលឱ្យស៊ីជម្រៅខាងខ្លឹមសារវិញឃើញថា គេហាក់ដូចជាមានបំណង វាយប្រហារទៅលើព្រះមហាវីរក្សត្រសម្តេចព្រះ **នរោត្តម សីហនុ** ទៅវិញទេ ពីព្រោះ ព្រះអង្គគឺជាវីរជនស្នេហាជាតិដ៏កំពូលរបស់កម្ពុជា ដែលបានប្រកាន់យកគោលការណ៍ ***«ខ្សែព្រំដែនមិនកែប្រែ»*** មកប្រើប្រាស់តាំងពីដើមទី និង បានកំណត់ យកផែនទីដូចបានបញ្ជាក់ជូនខាងលើ ទៅដាក់តម្កល់នៅអង្គការសហប្រជាជាតិថែមទៀតផង។

*(នេះហើយដែលថា) វាយ* **ហ៊ុន សែន** *ត្រូវ* **សីហនុ** *ឬនិយាយតាមមួយបែបទៀតព្រួញមួយបាញ់បានសត្វពីរ។ តើមានន័យថាដូចម្ដេចទៅ? ខ្ញុំដឹងដែរអស់លោក (ចង់លើកពី) បឹងជ្រាង, ច័ន្ទមូល។ល។ ខ្ញុំនឹងបង្ហាញផែនទីជូនអស់លោក។ ការប្រជុំរបស់អស់លោក, ខ្ញុំបានដឹង, ហើយមានទាំងខ្សែអាត់ប្រុងចែកផ្សាយអីទៀតផង (តែ ខ្ញុំសូមក្រើនរំលឹកអោយ) អស់លោកមើលព្រៃទាំងមូល កុំមើលឈើមួយដើមៗ ក្នុងរឿងទល់ដែន។ យើងមិនអាចភ្លេចដើមឈើណាមួយ ក្នុងចំណោមព្រៃទាំងមូលនោះបានទេ។ អស់លោកកំពុងធ្វើកិច្ចការនេះ ដោយមិនមែនមើលព្រៃទាំងមូលទេ គឺអស់លោកកាត់ដើមឈើមួយកំណាត់ហើយ យកខាងចុងមកផ្គុំជាមួយខាងគល់។ ពាក្យនេះ មិនធ្ងន់ដូចសំដីមេបក្សអស់លោកជេរខ្ញុំតាម* Video Conference *ល្ងាចថ្ងៃបញ្ចប់យុទ្ធនាការបោះឆ្នោតឃុំ-សង្កាត់ទេ។*

*សង្ឃឹមថា មេបក្សអស់លោកក៏កំពុងមើលដែរ ហើយក៏សុំប្រាប់ទៅមេបក្សរបស់អស់លោកទៅ មិនបាច់សរសេរសំបុត្រសរសើរខ្ញុំទេ។ វាលំបាកណាស់ ខែធ្នូ សរសេរសំបុត្រសរសើរខ្ញុំដល់ខែ មករា ឆ្នាំ ២០១២ ជេរខ្ញុំថាក្បត់ជាតិ។ ដូចនេះ មិនបាច់សរសេរសំបុត្រ ដើម្បីអបអរសាទរខ្ញុំឡើងឆ្លើយនៅរដ្ឋសភាជាលើកដំបូងទេ។ មិនបាច់ផ្ញើមកទេ ព្រោះខ្ញុំគ្មានពេលឆ្លើយជា*

*មួយពួកទណ្ឌិតទេ សូមកុំតែថា (ខ្លួន)ជាទណ្ឌិតមនសិការទៅ ក៏បានហើយ។ កុំថាដល់ដកតម្រុយព្រំដែន សូម្បីតែដកតម្រុយបង្គោលព្រំដី ក៏គេវាយ ឬប្តឹងឡើងតុលាការដែរ។ នៅទីនេះ បើយើងចាប់ឯកឧត្តម* **សុន ឆ័យ** *ទៅផ្តន្ទាទោស ទើបបានគេហៅថា បិទសិទ្ធិហើយជាអ្នកទោសមនសិការ ដោយសារតែសំនួរ។*

## ទី៣ - ការបន្តដោះស្រាយបញ្ហាព្រំដែនគោក ជាមួយវៀតណាម ដោយរាជរដ្ឋាភិបាល

បន្ទាប់ពីរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិមួយត្រូវបានបង្កើតឡើងក្រោយឆ្នាំ ១៩៩៣ ដោយមានកិច្ចសហការលើផ្នែកបច្ចេកទេសពីបរទេសរួមជាមួយនិងអ្នកជំនាញខាងព្រំដែនរបស់រាជរដ្ឋាភិបាល យើងបានធ្វើការសិក្សាលម្អិតលើឯកសារទាំងឡាយ ដែលពាក់ពន្ធ័ដល់ការងារព្រំដែនកម្ពុជា ជាមួយប្រទេសជិតខាងទាំងបី, ទាំងព្រំដែនគោក ទាំងព្រំដែនសមុទ្រ, ដែលពេលនេះ ខ្ញុំសូមលើកឡើងតែករណីជាមួយប្រទេសវៀតណាមមួយប៉ុណ្ណោះ។ ផ្អែកលើការសិក្សាលម្អិតនេះ កម្ពុជាបានពិនិត្យឃើញនូវការចាំបាច់ ត្រូវស្នើទៅរដ្ឋា ភិបាលវៀតណាម សុំធ្វើការកែសម្រួល និង បំពេញបន្ថែមនូវចំណុចមួយចំនួនលើកិច្ចព្រមព្រៀង និងសន្ធិសញ្ញា ដែលមានរួចហើយ ដើម្បីឲ្យស្របទៅតាមគោលការណ៍ច្បាប់ជាតិ និងច្បាប់អន្តរជាតិព្រម ទាំងស្របតាមការអនុវត្តជាអន្តរជាតិ។

ជារួម ការសិក្សាលម្អិតបានបង្ហាញឲ្យឃើញថា ផែនទីដែលតម្កល់នៅអង្គការសហប្រជាជាតិនាឆ្នាំ ១៩៦៤ គឺជាផែនទីចាស់ ដែលឋានលេខានៅលើផែនទីនោះ មានការប្រែប្រួលអស់មួយភាគធំទៅហើយ

ដោយសារតែការប្រែប្រួលនៃធម្មជាតិ និង ការអភិវឌ្ឍរបស់ប្រជាជនទាំងសងខាងខ្សែព្រំដែន។ ប្រការនេះ គឺជាហេតុដែលនាំឲ្យផែនទី និងស្ថានភាពដីជាក់ស្តែងមានលក្ខណៈមិនដូចគ្នា។ ដូច្នេះ វាជាការចាំបាច់ណាស់ដែលត្រូវមានការកែសម្រួល សំដៅធានានូវភាពស៊ីគ្នារវាងផែនទី និងស្ថានភាពដីជាក់ស្តែង ឲ្យទៅជារូបភាពតែមួយ។ លើសពីនេះទៀត ការដែលមានតែផែនទីតែមួយមុខ មិនអាចធ្វើឲ្យយើងបានដឹងច្បាស់ថា ខ្សែព្រំដែនពិតប្រាកដរបស់ខ្លួននៅត្រឹមណា និងនៅកន្លែងណា នៅលើដីជាក់ស្តែងនោះទេ។ មានផែនទីហើយក៏ដោយ ក៏នៅតែជាការចាំបាច់មិនអាចខ្វះបានដែលយើងត្រូវមានបង្គោលព្រំដែន និង របងព្រំដីនៅលើដីជាក់ស្តែង នោះទើបខ្សែព្រំដែននេះ ក្លាយទៅជាព្រំដែនអន្តរជាតិត្រឹមត្រូវ ស្របតាមលក្ខណៈបច្ចេកទេស និងច្បាប់ ដែលអាចងាយស្រួលក្នុងការការពារ និងសម្រាប់ចំណាំរបស់ប្រជាពលរដ្ឋក្នុងការកាន់កាប់ ប្រើប្រាស់ ធ្វើអាជីវកម្ម និងបង្កបង្កើនផលដោយគ្មានផលរមាស់។

*ចំណុចនេះ អស់លោកមួយចំនួន បានបារម្ភថា ខ្លាចបាត់បង់ទឹកដី ប៉ុន្តែបែរជាមិនហ៊ានបោះបង្គោល ឬប្រឆាំងនឹងការបោះបង្គោល។ ខ្ញុំយល់ហេតុផលរបស់អស់លោក ដែលថាផែនទីនេះមិនត្រឹមត្រូវ ចុះតើផែនទីត្រឹមត្រូវវានៅឯណា? ម៉េចក៏មិនឲ្យមក? ហើយតើយើងត្រូវធ្វើតែឯង ឬធ្វើជាមួយអ្នកដទៃ ឬស្រេចតែអស់លោកចង្អុលនៅកន្លែងនេះនៅកន្លែងនោះ? (យើងមិនអាច) ដោយសារតែមានផែនទី អត់ទៅពិនិត្យតំបន់ជាក់ស្តែង ដើម្បីវាស់វែង និងកំណត់ព្រំប្រទល់ឲ្យបានច្បាស់លាស់បានទេ ហើយ សូម្បីតែដីស្រែចំការក៏គេធ្វើព្រំដីដែរ។ ហេតុអ្វី*

*បានជាមកធ្វើការប្រឆាំង នឹងការធ្វើរបងព្រំដែនរបស់ប្រទេស? ការមានតែផែនទីវាអត់ប្រយោជន៍ទេ ដូច ឯកឧត្តមមួយយកផែនទីរត់លឿនណាស់ ព្រោះបើមិនលឿនងាប់។*

*មានផែនទីហើយតើធ្វើម៉េចទៀត។ តម្រូវឲ្យចុះវាស់វែង។ ការចុះវាស់វែង មិនមែនធ្វើជាឯកតោភាគីសម្រាប់តែកម្ពុជាទេ ត្រូវមានការព្រមព្រៀងទាំងសងខាង យើងជាមួយវៀតណាម ជាមួយឡាវ ជាមួយថៃ។ អស់លោកចោទឡើងសុទ្ធតែទុកឲ្យវៀតណាមចូលបោះ។ អស់លោកប្រមាថមាក់ងាយចំពោះរាជរដ្ឋាភិបាល ចំពោះអ្នកបច្ចេកទេស ចំពោះវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ទៅ។ បន្ទាប់ពីការប្រជុំថ្ងៃម្សិល ក្នុងសំណួរដែលគ្រោងសួរខ្ញុំ អស់លោកលើកឡើងពីការធ្វើមិនយល់ មិនដឹងអំពីបញ្ហាផ្តល់និងអនុញ្ញាតឲ្យគេចូលមកបោះស្រេចតែចិត្ត។ តើអស់លោកមើលមកពួកខ្ញុំជាសត្វ ឬអ្វី រហូតដល់ប្រមាថកាតទាន(ថាអោយគេ) ចូលបោះស្រេចតែចិត្ត។ ហើយបើនិយាយពីរំកិលព្រំដែនវិញ តាំងពីឆ្នាំ ១៩៧៩ រហូតមកដល់ឥឡូវរំកិលដល់ណាហើយ? មួយថ្ងៃរំកិល ១០ ម៉ែត្រ មួយថ្ងៃរំកិល ១០០ ម៉ែត្រ ពេលខ្លះថាមួយថ្ងៃរំកិលរាប់រយម៉ែត្រ ឬមួយគីឡូម៉ែត្រឯណោះ។ ប៉ុន្តែតាំងពីឆ្នាំ ១៩៧៩ មកដល់ឥឡូវ ជ្រៃធំ នៅតែ ជ្រៃធំ ក្អមសំណរ នៅតែ ក្អមសំណរ បាវិត នៅតែ បាវិត។ បើយោងតាមអស់លោក*

*និយាយ ភ្នំពេញ ចូលទៅជាទឹកដីវៀតណាមបាត់ហើយ។ (កោតតែ) អស់លោកអាចនិយាយទៅរួច។ តើធ្វើជាមេដឹកនាំប្រទេសទៅរួចទេ ដែលនិយាយមួលបង្កាច់គេយ៉ាងដូចនេះ? គេក៏ជាមនុស្សមានកិត្តិយសដែរ។ ការដែលប្រជាជនមិនព្រមបោះឆ្នោតឲ្យ ថាគេល្ងង់ ថាគេបន្ទំ ដល់គេឈ្នះទៅបន្ទោស* Arbitre*។ គួរឲ្យអៀនខ្មាសណាស់សំរាប់ជនជាតិខ្មែរដូចគ្នា ដែលមានមនុស្សធុនអន់ដូចនេះ។*

ឈរលើមូលដ្ឋាននេះ ភាគីទាំងពីរបានចាប់ផ្តើមធ្វើការជាមួយគ្នានៅក្នុងស្មារតីយោគយល់ និង ប្រកបដោយការទទួលខុសត្រូវខ្ពស់បំផុតរហូតដល់សម្រេចបាន នូវសន្ធិសញ្ញាបំពេញបន្ថែមនៅលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ ១៩៨៥ រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលត្រូវបានចុះហត្ថលេខានាថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០០៥។ កម្មវត្ថុនៃសន្ធិសញ្ញាបំពេញបន្ថែមនេះ គឺសំដៅកែសម្រួលទិសដើរនៃខ្សែព្រំដែនគោកដើរតាមទន្លេ ឬ ផ្លូវទឹក ដើម្បីកំណត់ខ្សែព្រំដែនដើរតាមទន្លេ ឬផ្លូវទឹកស្របតាមគោលការណ៍ និងការអនុវត្តអន្តរជាតិ ពោលគឺ៖

- ចំពោះកំណាត់ព្រំដែនទឹកដើរតាមព្រែក-ស្ទឹង មិនអាចធ្វើចរាចរណ៍បាន ខ្សែព្រំដែនត្រូវដើរតាមបន្ទាត់ទ្រូងនៃផ្លូវទឹកនោះ។
- ចំពោះកំណាត់ព្រំដែនទឹកតាមព្រែក-ស្ទឹង អាចធ្វើចរាចរណ៍បាន ខ្សែព្រំដែនត្រូវដើរតាមបន្ទាត់ទ្រូងនៃជ្រលងទឹកជ្រៅ។

*សូមបញ្ជាក់លើចំណុចនេះបន្តិច ព្រែកពីររបៀបនេះ ព្រែកមួយដែលមិនអាចធ្វើចរាចរបាន យើងត្រូវពុះទ្រូងព្រែកហ្នឹងចំពាក់កណ្តាលជាខ្សែព្រំដែនតែម្តង ឯព្រែក ឬស្ទឹង អាចធ្វើចរាចរបានយើងយកជ្រលងទឹកជ្រៅធ្វើជាខ្សែព្រំដែន។*

ត្រង់នេះ យើងគួរធ្វើការកត់សំគាល់ថា ស្របតាមគំនូសខ្សែព្រំដែនដើរតាមផ្លូវទឹក នៃផែនទីដែល អាណាព្យាបាលបារាំងបានបន្សល់ទុកឲ្យនោះ គឺមិនមានការយកចិត្តទុកដាក់ដល់ការបែងចែកទឹកសម្រាប់ ប្រជាពលរដ្ឋនៃភាគីទាំងសងខាង នៅតាមបណ្តោយព្រំដែនដែលមានព្រែក ឬស្ទឹងនោះទេ។ បានន័យថា នៅតាមទីតាំងមួយចំនួន ដែលមានភាគីណាម្ខាងទទួលបានតែមាត់ច្រាំង ភាគីនោះនឹងមិនអាចប្រើប្រាស់ទឹកបានឡើយ។ ជារួម ករណីនេះ ភាគច្រើនមាននៅខាងកម្ពុជាយើង។ ខ្ញុំសូមបញ្ជាក់ថា ខ្សែព្រំដែនដើរតាមផ្លូវទឹកនៃព្រំដែនគោករវាងកម្ពុជា-វៀតណាមមានប្រវែងសរុបប្រមាណជា ៣៨៣,៥ គីឡូម៉ែត្រ ក្នុងនោះ រដ្ឋបាលអាណាព្យាបាលបារាំងបានគូសដាក់ទឹកនៅខាងកម្ពុជាប្រវែង ១៩១ គីឡូម៉ែត្រ ដែលសុទ្ធសឹងជាតំបន់ព្រៃស្រោង មានប្រជាជនរស់នៅតិចតួច ដូចជា នៅខេត្តរតនគិរី ខេត្តមណ្ឌលគិរី និង ខេត្តក្រចេះ ជាដើម។ ចំណែកឯខ្សែព្រំដែនដើរតាមផ្លូវទឹកដែលបារាំងគូសឲ្យទៅខាងភាគីវៀតណាមវិញ មានប្រវែងសរុប ១៩២,៥ គីឡូម៉ែត្រ តែសុទ្ធសឹងជាតំបន់ដែលមានប្រជាជនរស់នៅច្រើនកុះករ ដូចជា នៅខេត្តកំពង់ចាម, ខេត្តស្វាយរៀង, ខេត្តព្រៃវែង, ខេត្តកណ្តាល និងខេត្តតាកែវ ជាដើម។ ក៏ប៉ុន្តែតាមរយៈ សន្ធិសញ្ញាបំពេញបន្ថែមថ្មីនេះ ភាគីទាំងពីរបានឯកភាពគ្នាចែកទឹកពាក់កណ្តាលម្នាក់។ ចំណុចនេះពិតជាមានសារសំខាន់ណាស់ សម្រាប់ប្រជាពលរដ្ឋនៃប្រទេសទាំងសងខាង ពិសេសសម្រាប់ប្រជាពលរដ្ឋកម្ពុជា ពីព្រោះក្នុងការអនុវត្ត

ជាក់ស្តែងទៅថ្ងៃក្រោយ ប្រជាពលរដ្ឋកម្ពុជាដែលរស់នៅតាមបណ្តោយខ្សែព្រំដែនទឹក នឹងមានសិទ្ធិប្រើប្រាស់ទឹកទន្លេ ព្រែកស្ទឹងទាំងនោះ ដោយមិនចាំបាច់សុំការអនុញ្ញាតពីភាគីវៀតណាមនោះទេ ឯភាគីវៀតណាម ក៏មិនបាច់សុំការអនុញ្ញាតពីភាគីកម្ពុជាដែរ។

*ខ្ញុំសូមបញ្ជាក់កន្លែងនេះបន្តិច។ បើអស់លោកពិតជាបានគិតគូរផលប្រយោជន៍ប្រជាជន អស់លោកត្រូវផ្តល់សារសំខាន់លើចំណុចនេះ។ សន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ ២០០៥ បានអនុញ្ញាតឲ្យយើងទម្លាក់ព្រំដែន ដែលនៅតាមមាត់ព្រែកឲ្យមកនៅកណ្តាលព្រែក និងនៅតាមជ្រលងទឹកជ្រៅ។ ពេលបារាំងកាន់កាប់ បារាំងមិនបានយកចិត្តទុកដាក់ពីការប្រើប្រាស់ទឹកទាំងសងខាង។ គូស ១៩១ គីឡូម៉ែត្រឲ្យមកខាងកម្ពុជា ជាព្រំដែនទៅជាប់និងច្រាំងវៀតណាម។ អញ្ចឹងវៀតណាមអត់មានទឹកដែរ ប៉ុន្តែកុំភ្លេចថាតំបន់ទាំងនោះអត់មានប្រជាជនរស់នៅ ហើយមិនសូវមានព្រែកធំទៅទៀត។ យើងបាន ១៩១ គីឡូម៉ែត្រភាគច្រើននៅឯ រតនគីរី មណ្ឌលគីរី និងក្រចេះ ហើយច្រើនតែព្រែកគោកពក់។ ដល់គូស ដាក់ខាងទឹកទៅឲ្យខាងវៀតណាមវិញ មានដល់ទៅ ១៩២,៥ គីឡូម៉ែត្រ ហើយសុទ្ធតែជាខេត្តដែលប្រជាជនរស់នៅច្រើនដូចជាកំពង់ចាម ស្វាយរៀង ព្រៃវែង កណ្តាល តាកែវ។ ដោយហេតុនេះ ពេលប្រជាជនចុះទៅដងទឹក ត្រូវសុំច្បាប់វៀតណាម។ ពិតមែនហើយនៅភាគខាងលើ ក៏យើងឲ្យដូចគ្នាក្នុង*

ករណី ដែលប្រជាជនវៀតណាមនៅជាប់ព្រែក។

ប៉ុន្តែភាគច្រើននៅខាងលើនេះ មានមនុស្សឯណានៅ។ ចំណុចនេះ បារាំងលំអៀង។ ប្រហែលគេគិតថា ខាងណោះកូសាំងស៊ីន ខាងនេះអាណ្ណាម។ ឥឡូវបើយើងទាញទំលាក់បានពាក់កណ្ដាលទឹកយ៉ាងដូច្នេះហើយ តើយើងប្រើប្រាស់ទឹកវាមិនស្រួលទេអី? រាប់ទាំងការធ្វើចរាចរ ការប្រើប្រាស់ទឹក និងការនេសាទ។ តើនេះជាទង្វើក្បត់ជាតិឬអី? សុំប្រជាជនតាមព្រំដែនដែលនៅជាប់មាត់ព្រែកទាំងឡាយមេត្តាជ្រាបថា ពួកប្រឆាំងបានប្រឆាំងទៅនឹងអ្វីដែលរាជរដ្ឋាភិបាល កំពុងដោះស្រាយទឹកឲ្យប្រជាពលរដ្ឋ។ តើបងប្អូនខ្មែរដែលរស់នៅតាមព្រំដែន ចង់ពេលចុះទឹកត្រូវសុំច្បាប់វៀតណាមទេ? ពេលអុំទូកត្រូវសុំច្បាប់វៀតណាមទេ? ពេលទៅបង់សំណាញ់ត្រូវសុំច្បាប់វៀតណាមទេ? ខ្ញុំកំពុងសុំ (អោយមានដំណោះស្រាយដូចគ្នា) នេះពីឡាវ ដែលដំបូងយើងស្នើសុំថា តាមដងទន្លេទាំងអស់ ទាំងគូសមកច្រាំងទន្លេកម្ពុជា ទាំងគូសទៅលើច្រាំងឡាវ អោយទំលាក់ទៅកណ្ដាលទន្លេ។

ក៏ប៉ុន្តែ ប្រជាជនទាំងសងខាង ភាគច្រើនកម្ពុជាមិនដឹងថាយ៉ាងម៉េចបារាំងគូសទឹកឲ្យ ទៅ វៀតណាម និង ឡាវ ឯខ្មែរអត់មានទឹក បានត្រឹមតែមាត់ច្រាំង។ ខ្ញុំបានសុំពី ឡាវ នូវ ទី១ សិទ្ធិប្រើប្រាស់ទឹក ទី២ សិទ្ធិធ្វើចរាចរផ្លូវទឹក និង ទី៣ សិទ្ធិធ្វើ

*នេសាទ តែឡាវមិនទាន់ឆ្លើយទេ។ ឯវៀតណាមគេសុខចិត្តធ្វើជាមួយយើង។ ពិតមែនហើយ សម្តីខ្ញុំមិនពិរោះស្តាប់ តែបើខ្ញុំបំពេរអស់លោក ក៏អស់លោកនៅតែមិនពិរោះដែរ ព្រោះអស់លោកស្អប់ខ្ញុំតែរហូត ហើយជាងនេះទៅទៀត ខ្ញុំជាឧបសគ្គរាំងការឡើងធ្វើនាយករដ្ឋមន្ត្រីរបស់មេបក្សអស់លោក។ បញ្ហានៅទីនេះ សារប្រយោជន៍របស់វាធំណាស់ សម្រាប់ជីវភាពប្រជាជននៅតាមតំបន់ព្រំដែន។ ហេតុអ្វីបានជាយើង ចង់ផ្តាច់សិទ្ធិហ្នឹងទៅវិញ? (មិនដឹងថាហេតុអ្វីបារាំង) ឲ្យទៅខាងវៀតណាមសុទ្ធតែជាព្រែកធំៗ ហើយខ្លះមានទាំងបង្កងទៀតផង។ តែឥឡូវបានសិទ្ធិចុះចាប់បង្កងជាមួយគេហើយ ម៉េចក៏មិនព្រម?*

ក្រៅពីនេះ នៅក្នុងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ ២០០៥ នេះ ភាគីទាំងពីរបានឯកភាពគ្នា កែសម្រួលខ្សែព្រំដែន ៦ កន្លែង **(បង្ហាញផែនទី)** ដោយយកតាមគោលការណ៍ធំៗ ៤ ជាមូលដ្ឋានគឺ៖

ទី១ - មូលដ្ឋានច្បាប់ដែលរដ្ឋបាលអាណានិគមបានប្រើប្រាស់

ទី២ - ការគ្រប់គ្រងពិតប្រាកដ និងការកាន់កាប់ជាក់ស្តែងរបស់ប្រជាជនជាច្រើនជំនាន់

ទី៣ - ស្ថានភាពភូមិសាស្ត្រ និងឋានលេខាស្របទៅនឹងបណ្តាគោលការណ៍ច្បាប់ និង

ទី៤ - ការអនុវត្តអន្តរជាតិ សំរាប់ការអនុវត្តក្នុងការកំណត់ទិសដើរនៃខ្សែព្រំដែនទៅតាមសណ្ឋានដី ដូចជា ខ្សែបែងចែកទឹក ខ្សែជួរកំពូល

ភ្នំ ខ្សែរយៈកំពស់។ល។

ក្រៅពីនេះ ក៏នៅមានចំណុចមិនទាន់ឯកភាពមួយចំនួនផងដែរ នោះគឺ កំណាត់ព្រំដែននៅតំបន់ជាប់នឹងឃុំដាក់ដាង, ស្រុកអូររាំង, ខេត្តមណ្ឌលគិរី (ខាងកម្ពុជា) និងឃុំខ្វាងជិក, ស្រុកដាក់ឡឹប, ខេត្តដាក់ណុង (ខាងវៀតណាម) ដែលមានផ្ទៃក្រឡាដីប្រមាណជា ៥០ គីឡូម៉ែត្រក្រឡា ហើយភាគី ទាំងពីរបានឯកភាពគ្នាបន្តការពិភាក្សា។ មូលហេតុដែលមិនទាន់មានការឯកភាពគ្នានេះគឺ ខាងភាគី កម្ពុជាទាមទារយកខ្សែព្រំដែននៅកំណាត់នេះ តាមសេចក្តីសម្រេចរបស់អគ្គទេសាភិបាលបារាំង ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩១៤ ដែលបានបញ្ជាក់ថា «ខ្សែព្រំដែននៅតំបន់នេះដើរតាមព្រែកដាក់ហ៊្វូត រហូតដល់ប្រភពនៃព្រែកនោះ»។ ឯខាងភាគីវៀតណាមទាមទារយកខ្សែព្រំដែននៅកំណាត់នេះ ដើរតាមព្រែកដាក់ដាង តាមផែនទីរបស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន SGI ខ្នាត ១/១០០ ០០០ និងតាមការកាន់កាប់ជាក់ស្តែងរបស់ប្រជាជនគេ ដែលមានជាយូរមកហើយ **(បង្ហាញផែនទី)**។

*ខ្ញុំសូមបញ្ជាក់ចំណុចនេះបន្តិច។ រឿងដែលនៅមិនទាន់ឯកភាពគ្នាក្នុងរឿងនេះ អាចថាចេញមកពីរឿងបារាំងខ្ជិល នេះម្យ៉ាងទៅ។ ថាបារាំងអីចឹងទៅ នៅព្រំដែនខាងកើត តែឯព្រំដែនខាងលិចក៏ខ្ជិលដែរ។ នៅព្រំដែនខាងលិច កន្លែងខ្លះយើងពិនិត្យមើលទៅ បង្គោលខ្លះវានៅអត់ចំចំណុច។ (ឃើញថាចំណុចស្ថិតលើ)ផែនទី តែបង្គោលអត់បានយកទៅបោះនៅចំណុចនោះទេ។ នៅទីនេះ សេចក្តីសម្រេចរបស់អគ្គទេសាភិបាលឲ្យទៅតាមផ្លូវនេះ បានសេចក្តីថា ទៅតាមព្រែក ដាក់ហ៊្វូត រហូតដល់ប្រភព*

*របស់ព្រែកនេះ។ សេចក្តីសម្រេចថ្ងៃទី ៣១ កក្កដា ១៩១៤ គឺឲ្យដើរតាមអាហ្នឹង ដល់បារាំងខ្ជិល ក៏គូរផែនទីតាមឯណោះវិញ (បង្ហាញផែនទី)។*

*ខ្ញុំសូមសួរអស់លោក តើនេះជាចរិតអាយ៉ងឬក៏ស្អី បានជាទាមទាររហូតទៅដល់ សើរើតាំងពីឆ្នាំ ១៩១៤ យកមកផ្ទៀងផ្ទាត់រវាងផែនទី និងសេចក្តីសម្រេចរបស់អគ្គទេសាភិបាល។ (ការប្រើពាក្យថា) អាយ៉ង ក្បត់ជាតិ វាធ្ងន់ធ្ងរណាស់ ហើយវាក៏ល្មមគ្រប់គ្រាន់ហើយ ក្នុងឋានៈជាជាតិសាសន៍ដូចគ្នា។ តែបើអស់លោកហៅបន្ត ខ្ញុំក៏មិនអាចបិទមាត់លោកជិតដែរ តែសុំប្រជាពលរដ្ឋវិនិច្ឆ័យ តើចរិតអាយ៉ងទាមទារបែបហ្នឹងទេ? រឿងបារាំងខ្ជិលបានធ្លាក់មកដល់ ហ៊ុន សែន ដែលកើតមុនបារាំងចេញមួយឆ្នាំ គឺ ១៩៥២។ បើយើងមិនច្រឡំទេ ប្រហែលជាក្នុងជំនាន់ព្រះបាទ ស៊ីសុវត្ថិ អគ្គទេសាភិបាលចេញសេចក្តីសម្រេចឲ្យដើរតាមព្រែកនោះ តែនេះបែរជាគូសតាមព្រែកឯនេះទៅវិញ។*

*ដែលយើងបានតស៊ូ (ហូរហែមកនេះ) តើ ជាចរិតអាយ៉ងឬជាអ្នកការពារជាតិ ការពារទឹកដី គឺប្រជាជនអាចវិនិច្ឆ័យបានហើយពេលនេះ។ ខ្ញុំគិតថា វិទ្យុមួយចំនួនរាប់ទាំងកម្មវិធីពន្លឺភ្លើងទៀនរបស់អស់លោកពុំហ៊ានផ្សាយទេ តែមានប្រព័ន្ធផ្សព្វផ្សាយ*

*គ្រប់គ្រាន់ហើយគឺ កំពុងផ្សាយមាន វិទ្យុ ១០១ ស្ថានីយ៍ និង ទូរទស្សន៍ ១៣ ស្ថានីយ៍។*

បន្ថែមលើនេះ តាមរយៈសន្ធិសញ្ញាបំពេញបន្ថែមនេះ ភាគីទាំងពីរ ក៏បានឯកភាពលើចំណុច សំខាន់មួយចំនួនទៀត រួមមាន៖

**ទីមួយ** ធ្វើការគូសចម្លងឡើងវិញនូវខ្សែព្រំដែនពីផែនទីបោន (Bonne) ខ្នាត ១/១០០ 000 របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិនអមសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ ឆ្នាំ ១៩៨៥ មកលើផែនទី UTM ខ្នាត ១/៥0000 អមសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ ១៩៨៥។ ចំណុចនេះ មានសារសំខាន់ណាស់។ វាមានន័យច្បាស់ថា ភាគីទាំងពីរឯកភាពគ្នាធ្វើសវនកម្ម (Audit) ខ្សែព្រំដែនឆ្នាំ ១៩៨៥ ទូទាំងខ្សែព្រំដែនទាំងមូលឡើងវិញ ដើម្បីឲ្យក្រុមបច្ចេកទេសចំរុះទាំងពីរ យកទៅអនុវត្តន៍ នៅលើដីជាក់ស្តែង។

*យើងត្រូវដឹងខ្នាតផែនទីឲ្យច្បាស់។ ផែនទីខ្នាត ១/១០០ ០០០ វាធំណាស់ដែលចាំបាច់ត្រូវតែចម្លងចេញ តែប្រភពចម្លងចេញ គឺមិនត្រូវឲ្យខុសពីផែនទីដើមខ្នាត ១/១០០ ០០០ ដែលតម្កល់នៅអង្គការសហប្រជាជាតិទេ។*

**ទីពីរ** ចំពោះបណ្តាតំបន់ដែលភាគីទាំងពីរមិនទាន់ឯកភាពគ្នា ទៅលើលទ្ធផលនៃការធ្វើសវនកម្ម ភាគីទាំងពីរនឹងយកផែនទីបោន (Bonne) ខ្នាត ១/១០0 000 ជាមូលដ្ឋាន ។

**ទីបី** នៅពេលការងារខណ្ឌសីមា និង បោះបង្គោលព្រំដែនមិនទាន់ត្រូវបានបញ្ចប់ទេនោះ ការគ្រប់គ្រងខ្សែបន្ទាត់ព្រំដែន នឹងត្រូវបន្តអនុវត្តតាមសេចក្តីប្រកាសព័ត៌មានរួម ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៥។

ចំណុចនេះមានសារសំខាន់ណាស់។ ព្រឹកមិញបានឃើញតាមទូរទស្សន៍មួយចំនួន ដែលគេទៅសម្ភាសន៍ប្រជាជនតាមទល់ដែន រាប់ទាំងជំទប់របស់គណបក្សសមរង្ស៊ី នៅទល់ដែនបាននិយាយថា៖ ដីហ្នឹងនៅធ្វើជម្លូតាតើ ឥឡូវគ្រាន់តែខ្វះទឹកអត់ទាន់បានធ្វើ។ ក្នុងសេចក្តីប្រកាសថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៥ ដែលពេលនោះសម្តេចក្រុមព្រះជានាយករដ្ឋមន្ត្រីទី ១ ខ្ញុំជានាយករដ្ឋមន្ត្រីទី ២ ក្នុងឱកាសទៅទស្សនកិច្ចនៅវៀតណាម សូមបញ្ជាក់ត្រង់ចំណុចទី ៨ ភាគីទាំង ២ បញ្ជាក់សាជាថ្មីពីឆន្ទៈរបស់ខ្លួន ក្នុងការកសាង ព្រំដែនរវាងប្រទេសទាំង ២ ឲ្យក្លាយទៅជាព្រំដែនសន្តិភាព មិត្តភាព និងស្ថេរភាព ដើម្បីរួមចំណែកដល់ការអភិវឌ្ឍន៍ទំនាក់ទំនង សហប្រតិបត្តិការ ក្នុងភាពជាអ្នកជិតខាងល្អរវាងប្រទេសទាំង ២ ក្នុងពេលរង់ចាំដំណោះស្រាយលើបញ្ហាព្រំដែន។ បើមិនទាន់មានការដោះស្រាយជាក់លាក់ប្រជាជននៅត្រង់ណានៅត្រង់ហ្នឹង ហាមមិនឲ្យពង្រីកថែមពីខាងណោះក៏មិនមកខាងនេះ ឬក៏ពីខាងនេះទៅខាងណោះ។

ភាគីទាំង ២ ឯកភាពរក្សាស្ថានភាពនៃការគ្រប់គ្រងបច្ចុប្បន្ន ដោយមិនឲ្យមានការផ្លាស់ប្តូរ ឬរំកិលបង្គោលព្រំដែន ហើយអប់រំប្រជាជន និងហាមប្រាមពួកគាត់មិនឲ្យធ្វើស្រែចំការតាំងទីលំនៅឆ្លងកាត់ព្រំដែន និងសហការគ្នារក្សាសន្តិសុខ និង

*សណ្តាប់ធ្នាប់តាមព្រំដែន។ ចំណុចនេះមានន័យថា អ្នកណាកាន់កាប់ត្រង់ណា នៅកាន់កាប់ត្រង់ហ្នឹង បើមិនទាន់បានដោះស្រាយទេ។ ការហាមឃាត់ធ្វើឡើង តែក្នុងខណៈដែលខាងណោះធ្វើធ្ងន់មកខាងណេះ ខាងនេះធ្វើធ្ងន់ទៅខាងណោះ។ តើឥឡូវនេះ អ្នកណាបាត់ដី? បើយោងទៅលើអ្វីដែលអស់លោកនិយាយថាបាត់រាប់រយរាប់ពាន់គីឡូម៉ែត្រការ៉េនោះ។ តើនេះជាភាសាបោកប្រាស់ ឬជាការប្រមាថមាក់ងាយដល់ប្រជាជន ដែលកំពុងរស់នៅទល់ដែន និងជាការប្រមាថមាក់ងាយចំពោះកងកម្លាំងប្រដាប់អាវុធ ដែលកំពុងការពារទល់ដែនឬទេ? អស់លោកប្រើការប្រឆាំងផ្កាប់មុខ ដោយគ្មានគិតគូរពីផលប្រយោជន៍ជាតិ។*

**ទីបួន** ភាគីទាំងពីរនឹងផលិតផែនទីព្រំដែនរដ្ឋរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គម និយមវៀតណាម។ ផែនទីព្រំដែននេះនឹងប្តូរជំនួសពីផែនទីបោន (Bonne) ខ្នាត ១/១០០ ០០០ ចំនួន ២៦ ផ្ទាំង និងផែនទី UTM ខ្នាត ១/៥០ ០០០ ចំនួន ៤០ ផ្ទាំង អមសន្ធិសញ្ញាកំណត់ព្រំដែនឆ្នាំ ១៩៨៥ និងប្លង់ទាំង ៤ អមសន្ធិសញ្ញាបំពេញបន្ថែម។ គួរគូសបញ្ជាក់បន្ថែមទៀតថា ផែនទីនេះនឹងផ្អែកលើឋានលេខាព្រំដែនថ្មីមួយ ដែលមានខ្នាត ១/២៥ ០០០ និងមានបង្ហាញទីតាំងបង្គោលព្រំដែន និងមានខ្សែខណ្ឌសីមារវាងប្រទេសទាំងពីរ ដើម្បីយកទៅតម្កល់ទៅអង្គការសហប្រជាជាតិ និង ទុកជាផែនទីផ្លូវការ និង ជាអចិន្ត្រៃយ៍តរៀងទៅ។

ជារួម សន្ធិសញ្ញាបំពេញបន្ថែមនេះ ពិតជាមានអត្ថប្រយោជន៍ជាប្រវត្តិសាស្ត្រសំរាប់ប្រទេសកម្ពុជា ក្នុងការកសាងព្រំដែនអចិន្ត្រៃយ៍ជាមួយ

នឹងប្រទេសវៀតណាម។ សន្ធិសញ្ញាបំពេញបន្ថែមនេះបានជួយជួសជុល កែលម្អ និងបំពេញបន្ថែម ទាំងខាងគោលការណ៍ច្បាប់ ទាំងខាងបច្ចេកទេសទៅលើ ចំណុចខ្វះខាតទាំងឡាយនៃសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋឆ្នាំ ១៩៨៥។ ក្នុងន័យនេះ សន្ធិសញ្ញាបំពេញបន្ថែមនេះ នឹងនាំមកជូនភាគីទាំងសងខាងនូវទំនាក់ទំនងជាអ្នកជិតខាងកាន់តែល្អប្រសើរ, សុខសន្តិភាព និង ភាពរីកចំរើនរុងរឿង ទាំងខាងសង្គមកិច្ច សេដ្ឋកិច្ច ពាណិជ្ជកម្ម ការវិនិយោគ និង ការផ្លាស់ប្តូរទេសចរណ៍។

*ចំណុចនៅទីនេះ យើងនឹងផ្ទេរផែនទីបោន* (Bonne) *ទៅជាផែនទី* UTM *ខ្នាត ១/៥០ ០០០ ហើយបន្តផ្ទេរទៅផែនទីខ្នាត ១/២៥ ០០០។ ប៉ុន្តែផែនទីខ្នាត ១/២៥ ០០០ ទាល់តែយើងបោះបង្គោលហើយសិន។ (សូមជំរាបជូនថា) បង្គោលបច្ចុប្បន្ន មានប្រដាប់សំរាប់ចាប់ដោយផ្កាយរណប ហើយមិនមែនវៀតណាមឬកម្ពុជាជាអ្នកធ្វើទេ គឺក្រុមហ៊ុនដាណឺម៉ាក់ ជាអ្នកដេញថ្លៃបានហើយកំពុងរង់ចាំទិន្នន័យ។ ខ្ញុំនឹងពន្យល់នៅផ្នែកខាងក្រោម ពីការកែសំរួល តាមការកាន់កាប់ជាក់ស្តែងរបស់ប្រជាពលរដ្ឋដែលមាននៅក្នុងសំណួររបស់ ឯកឧត្តម* **សុន ឆ័យ** *អំពីអនុស្សរណៈ ២៣ មេសា ២០១១។*

សំខាន់ជាងនេះទៀត សន្ធិសញ្ញានេះ បានបញ្ជាក់យ៉ាងច្បាស់សាជាថ្មី អំពីការជ្រើសរើសរបស់ កម្ពុជា នូវ គោលការណ៍ច្បាប់អន្តរជាតិដែលហៅថា «***គោលការណ៍ខ្សែព្រំដែនមិនកែប្រែ***» (Uti Possidetis) នៅពេលកម្ពុជាបានឯករាជ្យ មកបន្តអនុវត្ត នៅក្នុងការរកដំណោះស្រាយបញ្ហា

ព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង។ ដូចនេះសន្ធិសញ្ញាបំពេញបន្ថែមនេះ បន្តកិច្ចការដែលរាជរដ្ឋាភិបាលសម័យសង្គមរាស្ត្រនិយម បានធ្វើកន្លងមក ដើម្បីនាំទៅរកការបញ្ចប់បានទាំងស្រុង នូវខ្សែព្រំដែនមួយច្បាស់លាស់ ទាំងលើផែនទី ទាំងលើដី ជាក់ស្តែង ដើម្បីធានាបាននូវបូរណភាពទឹកដីកម្ពុជា និង ដើម្បីឲ្យប្រជាជនកម្ពុជាលែងមានការស្រពិចស្រពិល ស្គាល់ច្បាស់នូវព្រំដែនពិតប្រាកដរបស់ខ្លួន តាមរយៈបង្គោលព្រំដែន ដែលស្តែងឡើងនៅលើដីជាក់ស្តែង ងាយស្រួលក្នុងការចំណាំ ការគ្រប់គ្រង ការការពារ និង ការអភិវឌ្ឍនៅតំបន់ព្រំដែន។

និយាយជារួម តាំងពីចាប់ផ្តើមកំណើតរបស់ខ្លួនមក រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទី២ នេះបានប្រកាន់យ៉ាងខ្ជាប់ខ្ជួន និងប្រកបដោយសង្គតិភាពនូវគោលការណ៍យុទ្ធសាស្ត្រមួយចំនួន នៅក្នុងការខិតខំដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងរួមមាន៖

**ទីមួយ** ធានាការពារឲ្យបានដាច់ខាតនូវអធិបតេយ្យភាព និងបូរណភាពទឹកដី ដោយឈរលើគោលការណ៍ជាមូលដ្ឋាននៃ ***«ខ្សែព្រំដែនមិនកែប្រែនៅពេលដែលកម្ពុជាបានឯករាជ្យ»*** ដូចមានកំនត់ក្នុង មាត្រា ២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងស្របតាមចំនុច ॥ មាត្រាទី ១ ឃ នៃកិច្ចព្រមព្រៀងប៉ារីស ចុះថ្ងៃទី២៣ ខែ តុលា ឆ្នាំ ១៩៩១ ក៏ដូចជាស្របតាមព្រះរាជតម្រិះដ៏ភ្លឺស្វាងបំផុតរបស់ព្រះមហាវិរក្សត្រ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះវររាជបិតាជាតិខ្មែរ ដែលព្រះអង្គបានយកផែនទីកម្ពុជា-វៀតណាម ទាំងព្រំដែនគោក ទាំងព្រំដែនសមុទ្រ ទៅតម្កល់នៅអង្គការសហប្រជាជាតិ នាឆ្នាំ ១៩៦៤។

*(ក្រុម)ឯកឧត្តម (នៅទីនេះ) ក៏ប្រុងស្សួរហើយ ហើយ ឯក*

ឧត្តម (មួយដែល)រត់ចោលស្រុក ក៏បានសួរតាមវិទ្យុមកដែរ ថា **ហេតុអ្វីមិនបញ្ចប់នូវសន្ធិសញ្ញាតាមកិច្ចព្រមព្រៀងក្រុងប៉ារីស?**

ខ្ញុំសូមអានឲ្យស្តាប់នូវមាត្រាទី ១ ចំណុច **ឃ** ដែលចែងក្នុងចំណុចទីពីរ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស៖ "បញ្ចប់សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយដែល មិនសមស្របទៅនឹងអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹត្យភាព និងឯកភាពជាតិរបស់ខ្លួន"។ យើងយល់ទាំងអស់គ្នាហើយតើ កិច្ចព្រមព្រៀង (និយាយអំពីកិច្ចព្រមព្រៀង ឬសន្ធិសញ្ញា) ទាំងឡាយដែលមិនស្របនឹងអធិបតេយ្យភាព ឯករាជ្យ និងបូរណភាពទឹកដី។ ឯកិច្ចព្រមព្រៀងជាមួយវៀតណាមនេះ (ឃើញថា) មិនផ្ទុយទេ។ ខ្ញុំសូមជំរាប (ឯកឧត្តម អស់លោក ថា) រាជរដ្ឋាភិបាលអាណត្តិទី ១ ជា រាជរដ្ឋាភិបាលចំរុះបក្ស។

ហេតុអ្វីបានរាជរដ្ឋាភិបាលជំនាន់នោះ ទាំងហ៊ុនស៊ុនប៉ិច ទាំងគណបក្សប្រជាជន ទាំងគណៈបក្សសេរីនិយមព្រះពុទ្ធសាសនា រាប់ទាំងឯកឧត្តម **សុន ឆ័យ** ក៏នៅក្នុងហ្នឹង គ្រាន់តែបែកជាពីរ គឺម្ខាង **សឺន សាន** ម្ខាង **អៀង ម៉ូលី** និងមានទាំងម៉ូលីណាកាផង់ រក្សាទុកនូវកិច្ចព្រមព្រៀងនេះ មិនមែនគណបក្សប្រជាជនម្នាក់ឯងទេ។ រដ្ឋមន្ត្រីការបរទេសជាន់នោះ គឺព្រះ

*អង្គម្ចាស់* **នរោត្តម សិរីវុឌ្ឍ** *ដែលមុនពេលលាចេញពីតំណែង បានទៅទស្សនកិច្ចនៅហាណូយ ខែមករា ឆ្នាំ ១៩៩៥។ តើ (បានសេចក្តីថា) អ្នកទាំងនោះក្បត់ជាតិឬ? កិច្ចព្រមព្រៀងនេះ មិនមានប៉ះពាល់ដល់អធិបតេយ្យភាព ឯករាជ្យភាព និងបូរណភាពទឹកដីរបស់កម្ពុជាទេ (ដូចនេះយើង) ចាំបាច់លុបវាធ្វើអី? តើលុបហើយ យកផែនទីណាទៅចុះហត្ថលេខា? មិន(ប្រើ)ផែនទីដដែល? បើផែនទីដដែល (ហេតុអ្វីក៏មិន) បេញដំណើរពីត្រឹមនេះតែម្តងទៅ។*

*(ម្យ៉ាងវិញទៀត) រឿងនេះមិនមែន ធ្វើដោយគណបក្សប្រជាជនតែម្នាក់ឯងទេ។ បន្ទាប់មក (មានការ) ចុះហត្ថលេខាអោយសច្ចាប័នត្រឹមត្រូវ។ តើអ្នកណាទៅលុបវាកើតឥឡូវ។ ពិតមែនតែគណបក្សអស់លោកមិនបានគាំទ្រក្នុងសភា ក៏ប៉ុន្តែខ្ញុំសួរអស់លោកមួយម៉ាត់ តើអស់លោកមានសិទ្ធិវេតូទេ? ដំណើរការក្នុងសភា គឺមតិភាគតិចគោរពតាមមតិភាគច្រើន ហើយបានដំណើរការជាហូរហែរ រហូតបានជាសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ ២០០៥។ (នាសម័យ)ប្រជុំសភាឆ្នាំ ២០០៥ សម្តេចក្រុមព្រះដឹកនាំការប្រជុំសភា និងបានផ្តល់សច្ចាប័ន ហើយបន្ទាប់ពី ព្រឹទ្ធសភា (បានធ្វើដូចគ្នា) ព្រះមហាក្សត្រឡាយព្រះហស្ថលេខា។*

*តើឲ្យភាគច្រើនទៅគោរពភាគតិចរបស់អស់លោក ឬ*

*យ៉ាងណា? លោកចង់បានសង្គ្រាម លោកក៏លមើលទៅ។ លោកឯងប្រើមធ្យោបាយបែបណាប្រសើរជាងនេះ លោកឯងធ្វើទៅ។ ដោយហេតុនេះ ខ្ញុំបានឆ្លើយហើយ (អំពីករណី) បញ្ចប់សន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយណាដែលមិនស្រប នឹងឯករាជ្យអធិបតេយ្យភាពជាតិ។ ពីមុន ផ្ដល់សច្ចាប័នដោយរដ្ឋសភានៃអតីតសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសច្ចាប័នដោយរដ្ឋកម្ពុជាតែប៉ុណ្ណោះ តែលើកនេះ សច្ចាប័នដោយរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាទី ២ និងមានព្រះមហាក្សត្រ* **នរោត្តម សីហមុនី** *ឡាយព្រះហស្តលេខា។*

*អស់លោកតាំងខ្លួនជា បក្សប្រឆាំងមានសារសំខាន់។ (ខ្ញុំ) ទទួលស្គាល់ ប៉ុន្តែ(ការ)ប្រឆាំងដូចអស់លោកនេះ ដូចរកស្ដាបនាមិនកើតទេ។ ខ្ញុំចូលចិត្តស្ដាប់ណាស់ ពេលដែល (ឯកឧត្តម)* **សុន ឆ័យ** *ផ្ដល់យោបល់ឲ្យខ្ញុំ ដូចដែលមាននៅក្នុងកំណត់ហេតុ។ ... (មានការជូនដំណឹងមកថា) បងប្អូនខ្មែរពីសហរដ្ឋអាមេរិក បានទូរស័ព្ទមកថា កំពុងមើល (ការបំភ្លឺ) នៅសហរដ្ឋអាមេរិក ហើយអរគុណ សម្ដេច ដែលបានពន្យល់ក្បោះក្បាយនូវរឿងដែលគេមិនបានដឹង។ ខ្ញុំសូមអរគុណផង ចំពោះបងប្អូនដែលរស់នៅក្រៅប្រទេស។ ខ្ញុំនិយាយពីការរត់ចោលស្រុក គឺខ្ញុំចង់និយាយសំដៅតែមនុស្សម្នាក់ទេ តាមពិតពេលខ្ញុំបានជួបបង*

*ប្អូនខ្ញុំ ខ្ញុំនិយាយថាសំណាងហើយដែលបានរត់ទាន់ បើកុំអី* **ប៉ុល ពត** *ខ្វៃហើយ។ នៅក្នុងនេះ មួយចំនួនត្រូវបានអតីតរដ្ឋកម្ពុជាបញ្ជូនទៅរៀននៅបរទេសទេ, ហេតុអ្វីបានជាធ្វើដូចជាមិនស្គាល់គ្នាឯង។ ឯកឧត្តម* **យឹម សុវណ្ណ** *រៀនចប់មហាវិទ្យាល័យនៅស្រុកខ្មែរទេ មានតែ* **សុន ឆ័យ** *ទេ ដែលរត់ទៅអូស្ត្រាលី។ ក្រៅពីនេះ សុទ្ធជាអ្នករៀននៅហ្នឹង តែដូចជាមើលមិនឃើញកាលពីយើងនៅក្មេង។ អតីតរដ្ឋកម្ពុជាបានបញ្ជូនជំទាវ* **លី ស្រីវណា** *ឲ្យទៅរៀននៅប៉ូឡូញ។ រៀនជាមួយគ្នា ស៊ីអត់ស៊ីឃ្លានជាមួយគ្នាសោះ។ ... យើងមិនចង់ឲ្យដឹងគុណអីទេ គ្រាន់ឲ្យស្គាល់ថា ចេញពីត្រង់ណាទៅត្រង់ណា តែប៉ុណ្ណោះ។*

**ទីពីរ** ដោយឈរលើមូលដ្ឋាននៃគោលការណ៍ទីមួយខាងលើ ធានាឲ្យកម្ពុជាមានខ្សែព្រំដែនមួយច្បាស់លាស់ ដោយប្រែក្លាយព្រំដែនពាក់កណ្តាលរដ្ឋបាល និង ពាក់កណ្តាលអន្តរជាតិ ឲ្យទៅជាព្រំដែន អន្តរជាតិពិតប្រាកដ ព្រមជាមួយនេះដែរ ប្រែក្លាយខ្សែព្រំដែន ដែលមានតែលើផែនទីឲ្យទៅជាបង្គោល ព្រំដែននៅលើដីជាក់ស្តែង ហើយខ្សែព្រំដែននេះទៀតសោត នៅពេលណាដែលភាគីទាំងពីរបញ្ចប់ការងារបោះបង្គោល និងខណ្ឌសីមាព្រំដែនរួចរាល់ហើយ គឺត្រូវស្របគ្នាទៅនឹងការកាន់កាប់ជាក់ស្តែងរបស់ប្រជាពលរដ្ឋ ដែលរស់នៅតាមបណ្តោយព្រំដែនទាំងសងខាង។

*ចំណុចនេះមានសារសំខាន់ណាស់ ដើម្បីចៀសវាងការរើភូមិ ការចាកចោលលំនៅដ្ឋាន ការកាត់ដីស្អី។ ដូចលោកចោទ*

*ប្រកាន់ៗ (នេះបើនិយាយទៅ វា) តាមរបៀបដែលថា ឆ្កែចេះតែព្រួស មនុស្សចេះតែដើរ។*

**ទីបី** អនុវត្តការងារនៅក្នុងចំណុចទីពីរខាងលើ ក្នុងស្មារតីសន្តិភាព មិត្តភាព សហប្រតិបត្តិការ និង ការសម្រុះសម្រួល ក្នុងឋានៈជារដ្ឋអធិបតេយ្យដែលជាដៃគូស្មើភាព និង ស្មើសិទ្ធិជាមួយគ្នា ដោយ ឈរលើមូលដ្ឋាននៃច្បាប់ជាតិ និង អន្តរជាតិ។

**ទីបួន** កសាងព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង ឱ្យទៅជាព្រំដែនសន្តិភាព, មិត្តភាព, សហប្រតិបត្តិការ និង ការអភិវឌ្ឍ ដែលនឹងផ្តល់ផលប្រយោជន៍ដ៏ពិតប្រាកដដល់ប្រទេស និង ប្រជាជន ដែល ចូលរួមពាក់ព័ន្ធទាំងអស់ ពិសេសគឺប្រជាពលរដ្ឋដែលរស់នៅតាមបណ្តោយព្រំដែន។

គឺជាប្រការដ៏គួរឱ្យសោកស្តាយណាស់ ដែលកិច្ចខិតខំប្រឹងប្រែងដ៏ខ្លាំងក្លា ប្រកបដោយឆន្ទៈមោះមុតឥតរាថយរបស់រាជរដ្ឋាភិបាល សំដៅដោះស្រាយបញ្ហាព្រំដែន ដែលជាមរតកប្រវត្តិសាស្ត្រដ៏លំបាកស្មុគស្មាញនៅក្នុងក្របខ័ណ្ឌនៃគោលការណ៍ជាយុទ្ធសាស្ត្រ ដូចបានគូសបញ្ជាក់ពីខាងលើនេះ មិនត្រូវបានមើលឃើញ ឬក៏ត្រូវបានធ្វើជាមើលមិនឃើញដោយមជ្ឈដ្ឋានមួយចំនួនទៅវិញ។ មិនត្រឹមតែប៉ុណ្ណោះ កិច្ចការដ៏រសើប និង មានសារសំខាន់ជាអាយុជីវិតរបស់ប្រទេសជាតិនេះ ត្រូវបានគេយកមកធ្វើកម្មវត្ថុ នៃការធ្វើអាជីវកម្មជាប់ជាប្រចាំប្រកបដោយគ្រោះថ្នាក់ ក្នុងទិសដៅកេងយកផលចំណេញខាងនយោបាយ សម្រាប់បម្រើឱ្យផលប្រយោជន៍បុគ្គល ឬ ក្រុមមនុស្សមួយចំនួនតូចថែមទៀតផង។

ដូចខ្ញុំបានលើកឡើងពីខាងដើម ជារឿយៗ រាជរដ្ឋាភិបាលតែងបានទទួលរងនូវការចោទប្រកាន់ថា បានធ្វើការចរចាបញ្ហាព្រំដែន ឬបាន

ធ្វើការបោះបង្គោលព្រំដែន ដោយមិនមានតម្លាភាព និង គណនេយ្យភាព, មិនត្រឹមត្រូវច្បាស់លាស់, មិនអនុញ្ញាតឱ្យមានគណបក្សប្រឆាំង ឬអង្គការមិនមែនរដ្ឋាភិបាល ឬអ្នកសង្កេតការណ៍បរទេសចូលរួម។ល។

ខ្ញុំមានជំនឿថា អ្នកដែលលើកឡើងនូវមតិប្លែកៗទាំងនេះ ពិតជាដឹងច្បាស់ណាស់ថា ការចរចាបញ្ហាព្រំដែន គឺជាកិច្ចការមួយដែលមានលក្ខណៈរសើបបំផុត ហើយវាគឺជាសមត្ថកិច្ចការងាររវាងរដ្ឋអធិបតេយ្យមួយ ជាមួយនិងរដ្ឋអធិបតេយ្យមួយទៀត ដែលក្នុងនេះ រដ្ឋាភិបាលនៃប្រទេសនីមួយៗ គឺជាអ្នកទទួលខុសត្រូវ។ ការចរចានេះ មិនអាចយកមកបើកកកាយជាសាធារណៈ មុននឹងសម្រេចបានជាលទ្ធផលណាមួយនោះទេ។ បើពុំនោះសោត ផលប្រយោជន៍នៃប្រទេសជាតិ អាចនឹងត្រូវបាត់បង់។ ផ្ទុយទៅវិញ នៅពេលដែលសម្រេចបានជាលទ្ធផលការងារ ដូចជាការសម្រេចបាននូវកិច្ចព្រមព្រៀង ឬការបោះបង្គោលកំណត់ព្រំដែនរួចហើយនោះ រាជរដ្ឋាភិបាលមិនដែលបានលាក់បិទបាំង នូវសមិទ្ធផលការងារ ដែលមានសារសំខាន់ជាអាយុជីវិត និង ជាមោទនភាពរបស់ជាតិនោះឡើយ។ យើងតែងតែបានផ្តល់របាយការណ៍ដល់រដ្ឋសភា ដែលជាស្ថាប័នតំណាងឱ្យឆន្ទៈប្រជាជនដ៏ពិតប្រាកដ និង ចាត់ចែងធ្វើការផ្សព្វផ្សាយយ៉ាងទូលំទូលាយ ជូនដល់សាធារណជនគ្រប់ស្រទាប់ជាន់ថ្នាក់ឱ្យបានជ្រួតជ្រាបអំពីសមិទ្ធផលដ៏មានសារសំខាន់ និង គួរជាទីមោទនៈទាំងនេះ រហូតដល់រៀបចំឱ្យទៅជាទីកន្លែងសម្រាប់ទេសចរមកទស្សនាទៀតផង។ លើសពីនេះ បង្គោលព្រំដែននៅក្នុងសម័យបច្ចេកវិទ្យាទំនើបនាពេលបច្ចុប្បន្ននេះ ត្រូវបានរៀបចំដោយរឹងមាំ និង ងាយមើលឃើញ រហូតដល់មានបង្កប់មីក្រូឈីប (Microchip) ដើម្បីអាចងាយរកឃើញពីផ្កាយរណបផងដែរ។

សូមបញ្ជាក់ចំណុចនេះ។ អស់លោកចោទម្តងហើយម្តងទៀតថាគ្មានតម្លាភាព។ អស់លោកមានគោលបំណងបែបណា នៅពេលដែលកម្ពុជាប្រឈម នឹងការឈ្លានពាននៅទិសខាងលិច អស់លោកទាញកំលាំងមកទិសខាងកើត, អស់លោកនៅចាំបាន, ឯកឧត្តម **សុន ឆ័យ** ខ្លួនឯងនៅចាំបានទេ ក្នុងយុទ្ធនាការបោះឆ្នោតឆ្នាំ ២០០៨ នៅពេលដែលប្រជាពលរដ្ឋ កំពុងតែចូលរួម (ក្នុងវិស័យការពារជាតិ) ឯកឧត្តមផ្ទាល់បានរារាំងទៅវិញ។ ឯកឧត្តមខាតសម្លេងមួយចំនួននៅទីក្រុងភ្នំពេញ មកពីសំដីរបស់ឯកឧត្តម ព្រោះគេកំពុងបរិច្ចាគធនធាន ដើម្បីសមរភូមិមុខ។ វាគួរឲ្យស្តាយណាស់ នៅពេលដែលទិសខាងលិចកំពុងមានការឈ្លានពាន បែរជាធ្វើអោយមានការប្រឈមមុខក្នុងទិសខាងកើត ដែល ក្នុងយុទ្ធសាស្ត្រយោធា មិនត្រូវមានសមរភូមិច្រើនក្នុងពេលតែមួយទេ។

ដោយមិនបាននិយាយអ្វី ពីការលេបត្របាក់ទឹកដីនៅទិសខាងលិច ហើយមិនត្រឹមតែបន្ទុះបង្អាប់កងទ័ព អស់លោកថែមទាំងបង្វែទិសមកខាងកើត បំបែកកម្លាំងជាតិជាពីរ។ កន្លែងគ្រោះថ្នាក់ គឺគេចូលកាន់កាប់វត្ត កែវសិក្ខាគិរីស្វារៈ និងដណ្តើមចំណុចមួយចំនួនដូចជាភ្នំទ្រព្យ, វាលឥន្ទ្រី, ក្រោយមក តាមាន់, តាក្របី ឯណោះទេ។ អស់លោកបង្វិលទិសមកខាងកើត សំដៅ

*(ចង់ធ្វើ)អី? តើអស់លោកចង់បើកទ្វាឲ្យគេចូលទិសខាងលិច ក្នុងពេលអស់លោករំខានទិសខាងកើតឬ? តើអស់លោកជាអ្នកនយោបាយហ្នឹងមានគិតគ្រប់គ្រាន់ហើយ ឬនៅ? ខាងកើតវាបាត់ទៅណា? អស់លោកអាចទៅសួរខ្លួនឯងចុះ។ ព្រឹកមិញ គេសម្ភាសន៍ប្រជាជន រាប់ទាំងជំទប់នៃក្រុមប្រឹក្សាឃុំគណបក្សសមរង្ស៊ីផង (ដែលខ្ញុំនិយាយដូចនេះ) តែមិនស្រួលដកជំទប់នោះចោលបាត់ ព្រោះបង្ហាញមុខតាមទូរទស្សន៍។ បើគេដកក៏ដកទៅ ខ្ញុំជួយចិញ្ចឹមមិនអីទេ សូមអោយនិយាយតែការពិតចុះ។ (តែ សូមអស់លោកដឹងផងចុះថា) នៅក្នុង (ក្រុមតំណាងរាស្ត្រអស់លោក)ហ្នឹង ក៏មានសមាជិកគណបក្សប្រជាជនដែរ គ្រាន់តែខ្ញុំមិនចង្អុលមុខ។*

*ឯកឧត្តម* **ជា ប៉ូច** *ប្រហែលជាមិនទាន់ភ្លេចទេ នៅពេលសង្គ្រាមផ្ទុះនៅទិសខាងលិច ឯកឧត្តមផ្ទាល់បាននិយាយជាមួយអ្នកផ្សេងថា "ព្រះអង្គម្ចាស់ក្សត្រិយ៍* **សុរិន្ទថន** *ឡើងលើយន្តហោះបញ្ជាផ្ទាល់ ដើម្បីចាប់* **ហ៊ុន សែន** *ឲ្យបាន"។* **ហ៊ុន សែន** *មិនមែនជាក្មេងបៀមដៃ ហើយព្រះអង្គម្ចាស់ក្សត្រិយ៍* **សុរិន្ទថន** *ក៏មិនធ្វើដល់កំរិត ឡើងឧទ្ធម្ភាគចក្របញ្ជាទ័ពខ្លួនឯងនោះទេ។ ឯកឧត្តមនិយាយ ហើយខ្ញុំបានឮ។ ចុះម៉េចក៏ដល់ម្លឹង។* **ហ៊ុន សែន** *ជាអ្នកដឹកនាំនៃរដ្ឋអធិបតេយ្យ ទោះបីជាអស់លោកមិន*

ទទួលស្គាល់ មិនដឹងឮក៏ដោយ តែខ្ញុំជានាយករដ្ឋមន្ត្រីរបស់ប្រទេស (សមណាស់តែ) លោកជួយឈឺឆ្អាលជាមួយនឹងការខិតខំការពារទឹកដី។ គេវាយនៅទិសខាងលិច លោកឯងទាញហែកកម្លាំងមកទិសខាងកើត បន្ថែមដោយការបង្កើតចលនាខាងស្មារតី រហូតថាព្រះអង្គម្ចាស់ថៃចេញបញ្ជាទ័ពឲ្យចាប់ **ហ៊ុន សែន** ឲ្យបាន។ **ហ៊ុន សែន** មិនមែនជាទន្សាយបាក់ជើងទេសុំទោស។ សង្គ្រាមមួយរយម៉ោងឆ្នាំទៅ ប្រហែលជាអាចស្គាល់យុទ្ធសាស្ត្ររបស់ **ហ៊ុន សែន** បានហើយ។ អត់ធ្មត់ ១០០ ម៉ោងឲ្យវាយមុន បន្ទាប់ទៅសុំវាយវិញតែ ១៧ នាទីទេ។ ខ្ញុំមិនចង់ធ្វើសង្គ្រាមទេ តែជាការសោកស្តាយ ដែលអស់លោកមិនបានជួយលើកទឹកចិត្តចំពោះកិច្ចខិតខំទាំងការទូតទាំងផ្លូវច្បាប់ (ការពារទឹកដី)។

ឯកឧត្តម **សុន ឆ័យ** ទៅជួបជាមួយ **អភិសិទ្ធ** ហើយសប្បាយជាមួយគ្នា។ ថ្ងៃដែលខ្ញុំទៅប្រជុំនៅ ហួហ៊ិន (ឯកឧត្តម **សុន**) **ឆ័យ** ឯងនៅសណ្ឋាគារទីនោះ។ (**អភិសិទ្ធ**) ហៅ **សម រង្ស៊ី** អោយមកជេរខ្ញុំ នៅបាងកក, បន្ទាប់ទៅហៅ **សុន ឆ័យ** ឲ្យទៅនៅសណ្ឋាគារ ដែលខ្ញុំទៅប្រជុំអាស៊ាន។ ទទួលបានដំណឹងហ្នឹង ខ្ញុំថាទេ មួយកំភ្លៀងមក ត្រូវតែមួយកំភ្លៀងទៅ។ ខ្ញុំបានប្រកាសអោយ **ថាក់ស៊ីន** ធ្វើជាទីប្រឹក្សា ដែលនេះគេហៅថាតាម

*វាយដល់ផ្ទះ។ ខ្ញុំទៅប្រកាសនៅកណ្តាល(ក្រុងបាងកក)តែម្តងតែងតាំង* ***ចាក់ស៊ីន*** *ឲ្យធ្វើទីប្រឹក្សា។ អ្នកឯងមានសិទ្ធិទាក់ទងបក្សប្រឆាំង ខ្ញុំក៏មានសិទ្ធិដែរ ហើយ* ***ចាក់ស៊ីន*** *ក៏ជាមនុស្សរងគ្រោះដោយគេធ្វើរដ្ឋប្រហារដែរ។ នយោបាយគឺវាដូច្នោះហើយ។*

លើសពីនេះទៀត ខ្ញុំយល់ថា ការចោទប្រកាន់ដោយគ្មានភស្តុតាងត្រឹមត្រូវថា ប្រទេសជិតខាងរបស់កម្ពុជា បានលួចរំកិលបង្គោលព្រំដែន ឬរំលោភចូលមកយកដីកម្ពុជា រាប់រយរាប់ពាន់គីឡូម៉ែត្រក្រឡានោះ វាគឺជាការញុះញង់ បំភាន់ឱ្យមានការយល់ច្រឡំ ប្រកបដោយគ្រោះថ្នាក់ និង ដោយគ្មានការទទួលខុសត្រូវ។ ប្រការនេះ អាចនឹងដុតកម្តៅឱ្យពុះកញ្ជ្រោលឡើងនូវស្មារតីជាតិនិយមជ្រុល, បង្កឱ្យមានអរិភាពជាតិសាសន៍, ធ្វើអោយខូចខាតយ៉ាងធ្ងន់ធ្ងរដល់ទំនាក់ទំនងអ្នកជិតខាងល្អ មិត្តភាព និង កិច្ចសហប្រតិបត្តិការរវាងប្រទេស និង ប្រជាជនទាំងសងខាង។ លើសពីនេះទៅទៀត ទង្វើបែបនេះថែម ទាំងអាចបង្កឱ្យមានអស្ថិរភាពផ្ទៃក្នុងប្រទេសថែមទៀតផង។ ក្នុងន័យនេះ ការញុះញង់ប្រជាពលរដ្ឋដែលមានចំណេះដឹងតិចតួច ឱ្យចូលរួមបង្កើតបញ្ហាជាមួយនិងខ្លួន ដូចជា ការដើរដកបង្គោលតម្រុយព្រំដែន ដែលបានកំណត់ហើយយកទៅបោះចោលជាដើម គឺមិនមែនជាទង្វើដែលគួរឱ្យលើកសរសើរនោះទេ។ ផ្ទុយទៅវិញ អ្នកប្រព្រឹត្តិល្មើស គប្បីត្រូវតែបានទទួលទោសតឹងរឹងស្របទៅតាមបទបញ្ញត្តិច្បាប់កំណត់។

*ចំណុចនេះ បើរំកិលដូចអស់លោកថានោះ វាចូលរាប់រយរាប់ពាន់គីឡូម៉ែត្រការ៉េ។ ឥឡូវដីយើងធំរាប់រយគីឡូម៉ែត្រការ៉េ។ អ្នកដើរដកតម្រុយបង្គោលព្រំដែនហ្នឹង កុំថាខ្លួនជាអ្នក*

*ទោសមនសិការ ហើយសូមអញ្ជើញទៅរកអន្តរាគមន៍ចុះៗ មិនទាន់ស្តាប់ពួ អ្នកណាមួយនិយាយនិងខ្ញុំលើបញ្ហានេះទេ តែបើអន្តរាគមន៍ក៏អត់បានដែរៗ (តើបង្កើត)ច្បាប់យកមកធ្វើអីៗ សំណាងហើយដែលគ្មានសង្គ្រាមនៅទិសខាងកើត, ពេលហ្នឹងបើទោះបីប្រជាពលរដ្ឋខ្លួនឯងធ្វើខុសក៏ដោយ រដ្ឋាភិបាលជាប់ជំពាក់ត្រូវតែការពារប្រជាពលរដ្ឋខ្លួនឯងហើយ ព្រោះយើងមិនអាចទៅកាន់ជើងបរទេសនោះទេៗ ទោះបីគេបាញ់ ឬប្រើវិធីណាក៏ដោយ រាប់ទាំងអ្នកចូលទៅកាប់ឈើក្រញូងក្នុងដីថៃ ក៏គង់យើងថ្កោលទោសថៃបាញ់ប្រជាពលរដ្ឋរបស់យើងៗ*

*បើដូចនេះ ទោះបីឯកឧត្តមបេះតែដើរជក ស្រាប់តែពេលណាមួយគេបាញ់ ខ្ញុំមិនអាច ថ្កោលទោសពួកឯកឧត្តមដែលបានស្លាប់ ឬរបួសទេ មុខតែថ្កោលទោសអ្នកដែលបាញ់ឯកឧត្តមហើយៗ អញ្ចឹងកម្លាំងត្រូវហែកហើយៗ តែកាត់ទោសរួចហើយ គឺរួចហើយ ហើយសូមផ្តាំទៅមិនបាច់សរសេរសំបុត្រមកសរសើរអីទេ, សួរឯកឧត្តម* **អេង ឆៃអៀង** *ដឹងហើយ, ឲ្យត្រៀមលិខិតស្នាម ហើយ (អ្នកសារពត៌មាន)* **សយ សុភាព** *ក៏ដឹងដែរ ព្រោះជាអ្នកឲ្យយោបល់ៗ*

ម្យ៉ាងវិញទៀត ដូចខ្ញុំបានលើកឡើងពីខាងដើមហើយដែរថា ការស្នេហាជាតិ និង ការការពារ បូរណភាពទឹកដី គឺជាសិទ្ធិ និង កាតព្វកិច្ចរបស់ពលរដ្ឋកម្ពុជាគ្រប់រូបៗ ក្នុងរយៈកាលកន្លងមក កងកម្លាំង ប្រដាប់

អាវុធគ្រប់ប្រភេទ និង ប្រជាជនកម្ពុជាដ៏ច្រើនកុះករ ពិសេសបងប្អូនប្រជាជនដែលរស់នៅតាម បណ្តោយព្រំដែននៅគ្រប់ទិសទី បានចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចការនេះ ទាំងដោយត្រង់ និង ដោយប្រយោល។ រាជរដ្ឋាភិបាលក៏បានបង្ហូរទុនវិនិយោគដ៏ច្រើនសន្ធឹកសន្ធាប់ផងដែរ ទៅកាន់តំបន់ជាយដែនសំខាន់ៗ ដើម្បី កសាងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងផ្តល់មធ្យោបាយសម្រួលសមស្រប សំដៅធានាឱ្យកងកម្លាំង និង ប្រជាជនយើងអាចបំពេញការងារ, រស់នៅ និងធ្វើការអភិវឌ្ឍភូមិឋានរបស់ខ្លួន។ ការបោះទីលំនៅជាប់លាប់ និង ការអភិវឌ្ឍភូមិឋាននៅតាមតំបន់ព្រំដែនទាំងអស់នោះ គឺជារបងការពារ បូរណភាពទឹកដីមួយយ៉ាងសំខាន់។ ដូច្នេះ ការចោទប្រកាន់ថា មានការអនុញ្ញាតឱ្យប្រទេសជិតខាងចូលមករំលោភ យកទឹកដីដោយស្រួលៗ អស់រាប់រយរាប់ពាន់គីឡូម៉ែត្រក្រឡានេះ គឺមានន័យស្មើនិងការមើលស្រាល ចំពោះកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលទទួលភារកិច្ចការពារខ្សែបន្ទាត់ព្រំដែន របស់ប្រទេសជាតិ និង ប្រជាជនកម្ពុជារាប់ម៉ឺនគ្រួសារ ដែលរស់នៅតាមបណ្តោយព្រំដែនទាំងនោះផងដែរ។

*សូមបងប្អូនកងកម្លាំងប្រដាប់អាវុធទាំងអស់ ដែលរស់នៅតាមតំបន់ព្រំដែន និងប្រជាជននៅតាមព្រំដែន មើលឲ្យឃើញ អំពីចរិតខ្មៅក្រខ្វក់របស់ពួកប្រឆាំងដែលមើលស្រាលបងប្អូន កំពុងការពារទឹកដី និងកំពុងរស់នៅទីនោះ។ ខ្ញុំមិនមែនចូលចិត្តកាស៊ីណូទេ ប៉ុន្តែការអនុញ្ញាតឲ្យធ្វើកាស៊ីណូ គោលដៅធំជាងគេគឺការពារព្រំដែន។ កាស៊ីណូខាងក្នុងនេះ មិនមែនខ្ញុំនាំមកទេ។ ការមានកាស៊ីណូនៅព្រំដែន ជាផ្នែកមួយនៃនយោបាយការពារព្រំដែនផងដែរ។ គេអាចដកបង្គោលព្រំដែនបាន តែគេ*

*មិនអាចដកសណ្ឋាគារ ៤ - ៥ ដាន់បានទេ។ អស់លោកបង្ខំឲ្យខ្ញុំនិយាយរឿងនេះ ដែលគួរតែជាអាថ៌កំបាំងនៃយុទ្ធសាស្ត្រការពារជាតិ ប៉ុន្តែ អស់លោកមិនទុកជម្រើសឲ្យខ្ញុំ។ អ្វីដែលសំខាន់ជាងនេះ អស់លោកកំពុងប្រមាថប្រជាជនរាប់ម៉ឺនគ្រួសារ ដែលនៅតាមព្រំដែន កម្លាំងរាប់ម៉ឺននៅការពារព្រំដែន រាប់ទាំងសមាជិកគណបក្សរបស់អស់លោកផង។*

ដូចដែលយើងទាំងអស់គ្នាបានដឹងស្រាប់ថា ដើម្បីសម្រេចបាននូវព្រំដែនមួយដែលប្រកបដោយ សន្តិភាព, មិត្តភាព, កិច្ចសហប្រតិបត្តិការ និង ការអភិវឌ្ឍ ប្រទេសនីមួយៗមិនអាចកសាងខ្សែព្រំដែនតែ ឯកឯងបាននោះទេ។ វាជាកាចាំបាច់ណាស់ដែលប្រទេសសាមីទាំងសងខាងខិតខំរកដំណោះស្រាយរួមគ្នា ដោយគោរពគ្នាទៅវិញទៅមក ក្នុងសុឆន្ទៈចង់ដោះស្រាយដោយពិតប្រាកដ ហើយឈរលើស្មារតីស្មោះត្រង់ មិនកេងចំណេញពីគ្នា។ ក្នុងន័យនេះ យើងគួរតែផ្តល់ការវាយតម្លៃសមស្រប ជូនដល់រដ្ឋាភិបាលវៀតណាម ដែលបានសម្តែងនូវសុឆន្ទៈ និង ការគោរពចំពោះឯករាជ្យ និង អធិបតេយ្យភាពជាតិរបស់កម្ពុជា ហើយធ្វើការចរចាដោយស្មោះត្រង់ ជាមួយនិងរាជរដ្ឋាភិបាល សំដៅស្វែងរកដំណោះស្រាយលើបញ្ហាព្រំដែនដ៏ស្មុគស្មាញនេះ ដើម្បីផលប្រយោជន៍របស់ប្រទេស និង ប្រជាជនទាំងសងខាង។

*បញ្ហានេះក៏ត្រូវបញ្ជាក់ឡើងវិញ។ វៀតណាមមុននេះមានពីរ គឺវៀតណាមខាងជើង និងវៀតណាមខាងត្បូង។ វៀតណាមខាងត្បូង ជានិច្ចកាលមិនទទួលស្គាល់ព្រំដែនយើងទេ ដោយបាន*

រំលោភបំពានរហូត ដូចជាការទម្លាក់គ្រាប់បែកនៅអន្លង់ក្រេះ ចន្ទ្រា ដាក់ដាង ស្អី។ ជាមួយគ្នា។ ឯវៀតណាមខាងជើង ហៅថា សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ទទួលស្គាល់ព្រំដែន។ ហេតុដូច្នេះហើយ ទើបសម្តេចព្រះ **នរោត្តម សីហនុ** ទទួលស្គាល់ រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម (វៀតណាម ខាងជើង) និងរដ្ឋាភិបាលបណ្តោះអាសន្នវៀតណាមខាងត្បូង(ដែល) តស៊ូខាងរណសិរ្ស។ តែជម្មោះមានជាហូរហែរតាំងពី **ង៉ោ ឌិញ យាម** រហូតមកជាបន្តបន្ទាប់ជាមួយវៀតណាមខាងត្បូង។

ជាការល្អហើយ ដែលសព្វថ្ងៃយើងចរចាជាមួយនិង (សាធារណរដ្ឋសង្គមនិយម)វៀតណាម ដែលបន្ទាប់ពីការឯក ភាពទឹកដី ប្រកាន់ជំហរវៀតណាមខាងជើង។ បន្តិចទៀត យើង មិនបានឃើញខ្សែព្រំដែនរបស់ ជីវគី នៅក្នុងតំបន់សមុទ្រទេ ព្រោះវៀតណាមខាងជើងអត់មានផែនទីខ្សែហ្នឹងទេ។ ប៉ុន្តែ បើ សិនវៀតណាមខាងត្បូងដែលជាសម្ព័ន្ធមិត្តរបស់ **លន់ នល់** និង របស់លោក **ស៊ីរិក ម៉ាតៈ** នៅបន្តនោះច្បាស់ជាកោះវៃបាត់ ទៅហើយ មិនបានមកយើងវិញទេ។

យើងត្រូវធ្វើ(កិច្ចការព្រំដែន) ជាមួយប្រទេសជិតខាង ដោយមិនអាចចង្អុលតែម្នាក់ឯងទេ។ គ្រាន់តែបញ្ហាដីគោក ខ្ញុំ បានប្រើពេលអស់បីម៉ោងហើយ។ ឥឡូវចូលដែនទឹក រួចហើយ

*បានចូលដល់សំណួរឯកឧត្តម* ***សុន ឆ័យ*** *ចុងក្រោយ។ យ៉ាងណាក្តី (ការរៀបរាប់)ពីខាងលើ(មក មានចរិត) គ្រប់ដណ្តប់ (រួចហើយ) ដើម្បីបង្ហាថា កុំអោយមួយស្មាបដំរីទាំងមូលទៅថា ដូចអំបោស មួយទៀតថាសរសរ មួយទៀតថាចង្អេរ។ ខ្ញុំចង់រំលេចឲ្យអស់បញ្ហា ដើម្បីថា បើឯកឧត្តមមិនយល់ ក៏ប្រជាពលរដ្ឋ និងព្រះសង្ឃនៅទូទាំងប្រទេសលោកយល់ដែរ។*

## II អំពី ព្រំដែនសមុទ្រ

នៅឆ្នាំ ១៩៦៤ កម្ពុជាបានយកផែនទីព្រំដែនសមុទ្រខ្នាត ១/៣០០ ០០០ បោះពុម្ពដោយក្រុមភូមិសាស្ត្រកម្ពុជា ដែលបានយកខ្សែប្រេវីយ៉េ (Brévié) ឆ្នាំ ១៩៣៩ កំណត់ជាខ្សែព្រំដែនសមុទ្ររវាងកម្ពុជា និងវៀតណាម ទៅតម្កល់ទុកនៅអង្គការសហប្រជាជាតិ និងបានស្នើសុំឱ្យសាមី និង អន្តរជាតិទទួលស្គាល់ខ្សែព្រំដែននេះ ថាជាខ្សែព្រំដែនសមុទ្ររវាងប្រទេសទាំងពីរ កម្ពុជា-វៀតណាម។ កម្ពុជា នាពេលនោះ ក៏ទទួលបានការគាំទ្រពីប្រទេសសាមី និងពីអន្តរជាតិមួយចំនួន ដោយទទួលស្គាល់ថាខ្សែប្រេវីយ៉េ ជាខ្សែព្រំដែនសមុទ្ររវាងកម្ពុជា និងវៀតណាម **(បង្ហាញផែនទីខ្សែប្រេវីយ៉េ)**។

តែនៅឆ្នាំ ១៩៧០ រដ្ឋាភិបាលធីវគីបានអនុម័តច្បាប់ស្តីពីប្រេងកាត ដែលបញ្ជាក់ពីតំបន់ខ្ពង់រាប បាតសមុទ្ររបស់វៀតណាម ហើយចាប់ផ្តើមធ្វើការកំណត់តំបន់ខ្ពង់រាបបាតសមុទ្រនេះ នៅឆ្នាំ ១៩៧១។ ផ្អែកលើច្បាប់នេះ នៅឆ្នាំ ១៩៧១ រដ្ឋាភិបាលធីវគី បានគូសខ្សែព្រំដែនសមុទ្ររបស់ខ្លួនមួយទៀត ដែលព័ទ្ធយកទាំងកោះរ៉ែរបស់កម្ពុជា **(បង្ហាញផែនទី ខ្សែ**

**១៩៧១)**។ នៅឆ្នាំ ១៩៧២ របបសាធារណរដ្ឋខ្មែរបានគូស ខ្សែព្រំដែនសមុទ្រមួយទៀតផ្សេងពីខ្សែប្រេវីយ៉េ ដោយឈរលើគោលការណ៍សមចម្ងាយ (Equidistance) ដែលជាខ្សែមួយមានចម្ងាយស្មើគ្នាពីឆ្នេរសមុទ្រ ឬពីកោះ ដោយនៅផ្នែកខាងលិចចាត់ទុកកោះគត់ ជា កោះព្រំដែន។ គេធ្វើនេះ គឺដោយយោងតាមសន្ធិសញ្ញាបារាំង-សៀម ឆ្នាំ ១៩០៧ ដែលចាត់ទុកថា នៅ ផ្នែកខាងកើត កោះត្រល់ និង កោះថូជូ គឺជារបស់ខ្មែរ **(បង្ហាញផែនទីខ្សែឆ្នាំ ១៩៧២)**។

ការវិវត្តិបន្តមកទៀត គឺមានការពាក់ព័ន្ធជាសំខាន់ទៅនឹងកិច្ចព្រមព្រៀងស្តីពីតំបន់ទឹកប្រវត្តិសាស្ត្រ ឆ្នាំ ១៩៨២។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតធ្វើការពន្យល់ដោយសង្ខេបអំពីកិច្ចព្រមព្រៀងនេះ។

**កិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្រឆ្នាំ ១៩៨២** ពុំទាន់បានកំណត់ព្រំដែនសមុទ្ររវាងប្រទេសទាំងពីរនៅឡើយទេ ទោះជានៅក្នុងឆ្នាំ ១៩៦៤ កម្ពុជាបានយកផែនទីដែលមានខ្សែប្រេវីយ៉េ ឆ្នាំ ១៩៣៩ ទៅឱ្យអន្តរជាតិទទួលស្គាល់ និង បានដាក់តម្កល់នៅអង្គការសហប្រជាជាតិហើយក៏ដោយ។ កិច្ចព្រមព្រៀងឆ្នាំ ១៩៨២ បានទុកចំហ អំពីភារកិច្ចលើការកំណត់ព្រំដែនសមុទ្រឱ្យរដ្ឋាភិបាលនៃប្រទេសទាំងពីរ **«ចរចាគ្នា ដើម្បីកំណត់ព្រំប្រទល់សមុទ្រក្នុងតំបន់ទឹកប្រវត្តិសាស្ត្រ»** នេះ។ កម្ពុជានាពេលនោះ មានជម្រើស ៣ ក្នុងការជ្រើសរើសយកខ្សែព្រំដែនសមុទ្ររវាងកម្ពុជា និង វៀតណាម គឺ៖ ទី១ - ខ្សែប្រេវីយ៉េ ឆ្នាំ ១៩៣៩, ទី២ - ខ្សែសាធារណរដ្ឋខ្មែរ ឆ្នាំ ១៩៧២ ពោលគឺខ្សែសមចម្ងាយ (Equidistance) ឬ ទី៣ - ការចរចាជាមួយវៀតណាម ដើម្បីកំណត់រកចំណុចប្រសព្វសូន្យក្នុងតំបន់ទឹកប្រវត្តិសាស្ត្រ ឆ្នាំ ១៩៨២ នៅលើខ្សែបន្ទាត់ដែលភ្ជាប់កោះថូជូ និង កោះវ៉ៃ ថាជាខ្សែព្រំដែនសមុទ្ររវាងកម្ពុជា និង វៀតណាម។

ភាគីទាំងពីរ កម្ពុជា-វៀតណាម បានទទួលស្គាល់ជាផ្លូវការ នូវការបែងចែកអធិបតេយ្យភាពលើកោះក្នុងឈូងសមុទ្រសៀម តាមរយៈការបែងចែកខ្សែប្រេវីយ៉េ ឆ្នាំ ១៩៣៩ និង បានឯកភាពពិភាក្សាគ្នា ដើម្បីកំណត់ចំណុចប្រសព្វសូន្យ ដែលជាចំណុចបែងចែកព្រំដែនសមុទ្ររវាងប្រទេសទាំងពីរនៅក្នុងតំបន់ទឹកប្រវត្តិសាស្ត្រ ក៏ដូចជាក្នុងតំបន់ខ្ពង់រាបបាតសមុទ្រ។ តែការចរចាដើម្បីកំណត់ចំណុចប្រសព្វសូន្យ រហូតមកដល់ពេលនេះ នៅពុំទាន់ឈានដល់ការឯកភាពគ្នានៅឡើយទេ ដោយកម្ពុជាទាមទារយកខ្សែប្រេវីយ៉េ ឆ្នាំ ១៩៣៩ ជាខ្សែព្រំដែនសមុទ្ររវាងប្រទេសទាំងពីរ តែភាគីវៀតណាមទាមទារយកខ្សែសមចម្ងាយ (Ligne d'équidistance) ដោយចាត់ទុកថា ខ្សែប្រេវីយ៉េ គ្រាន់តែជាខ្សែបែងចែកអធិបតេយ្យភាពលើកោះតែប៉ុណ្ណោះ **(បង្ហាញផែនទី)**។

ដូច្នេះ តើកិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្រ បានធ្វើឱ្យបាត់បង់ទឹកដី ១០ ០០០ គីឡូម៉ែត្រក្រឡា មែនឬទេ? ចម្លើយ គឺខ្លី និង សាមញ្ញណាស់ថា ឥតមានធ្វើឱ្យបាត់ទេ។ ដូចបានជម្រាបជូនពីខាងលើរួច ហើយថា កិច្ចព្រមព្រៀងនេះ ពុំទាន់បានកំណត់ព្រំដែនសមុទ្ររវាងប្រទេសទាំងពីរនៅឡើយទេ។ លើសពីនេះទៀត ភាគីទាំងពីរត្រូវបន្តការចរចារកចំណុចប្រសព្វសូន្យរវាងកោះវ៉ៃ និងកោះថូជូ ដើម្បីកំណត់ខ្សែ ព្រំដែននៅក្នុងតំបន់ទឹកប្រវត្តិសាស្ត្រ។

*ចំពោះការចោទប្រកាន់ថា (យើងធ្វើអោយ)បាត់បង់ដែនទឹកមួយម៉ឺនគីឡូម៉ែត្រនោះ (សួរថា) តើកម្ពុជា និងវៀតណាមនៅពេលនេះ មានព្រំដែនសមុទ្រពីកាលណា? ហេតុដូចម្តេចបានជាហ៊ានចោទថា យើងធ្វើឲ្យបាត់(ដែន)ទឹករហូតដល់មួយម៉ឺនគីឡូ*

*ម៉ែត្រការ៉េ? ពួកឡប់សតិទាំងនោះ បានធ្វើរហូតបង្ហោះតាមវ៉េបសាយត៍ (នូវការប្រឌិតមួលបង្កាច់ដ៏ថោកទាប)ថា កូនខ្ញុំមួយនោះ* (**ហ៊ុន ម៉ាណែត**) *ជាកូនរបស់* **ឡេ ឌឹកថ** *ជាមួយនាង* **ធី ត** (*ជាឈ្មោះដែលពួកវាបានហៅប្រពន្ធរបស់ខ្ញុំ*)។ (*ពួកនេះ បានប្រឌិត ថា*) **ឡេ ឌឹកថ** *បានយកនាង* **ធី ត** (*បន្ទាប់មក* **ឡេ ឌឹកថ** *ក៏*) *ប្រគល់* (**ធី ត** *និងកូន*) *ឲ្យ* **ហ៊ុន សែន** *រួច* **ហ៊ុន សែន** *យកមកឲ្យ* **ស្មុខ អាន** *ក្នុងឋានៈជាអ្នកជល់មាន់ផង ប៉ះកង់ផង ជួយចិញ្ចឹមឈាមជ័ររបស់* **ឡេ ឌឹកថ** *ដើម្បីអោយបន្តវេននៅថ្ងៃក្រោយ។ (គួរអោយអាសូរភរិយាខ្ញុំណាស់ នាង) ជាប់គុកនៅក្នុងប្រទេស បែកបាក់ ព្រាត់ប្រាសពីប្តី (បែរជាត្រូវគេប្រឌិតរឿងដ៏ថោកទាប មើលងាយថា) ខ្លួនជាស្រីរបស់មេដឹកនាំវៀតណាម* **ឡេ ឌឹកថ** *ប្រគល់ឲ្យ* **ហ៊ុន សែន** *ថែទាំ។ ឱ* **ហ៊ុន ម៉ាណែត** *កូនអើយ នៅក្នុងរបប ប៉ុល ពត គេជៀលថាជា កូនរបស់មេក្បត់ មកដល់ឥឡូវ គេចោទថាជាកូនរបស់វៀតណាមទៅទៀត។*

*អំពើដ៏ថោកទាបបែបនេះ អាចចេញពីមាត់មនុស្សធុនគាំទ្រអស់លោក។ ចំពោះទង្វើថោកទាបបែបនេះ តើពលរដ្ឋខ្មែរសមនឹងបោះឆ្នោតជូនដែរឬទេ? ខ្ញុំមិនសំដៅតែបក្សអស់លោកមួយទេ។ (ការដែល)ខ្ញុំចង្អុលទៅមុខ (មិនមែនបានន័យថា) ខ្ញុំចង្អុលមុខលោកទេ។ (ការដែល) អស់លោកបានបដិសេធ និង*

*បានរលាស់ខ្លួនចេញហ្នឹង ជាការល្អហើយ (សំដៅថា) មានគុណធម៌គ្រប់គ្រាន់។ (តែ សូមពិចារណាទៅមើល ពួកទាំងនេះបានផ្សព្វផ្សាយថា សម្តេច)* ***ជា ស៊ីម*** *ស្លាប់ ហើយកែងបន្ទំឯកសាររាប់មិនអស់ ព្រមទាំងបំពានមកដល់ប្រពន្ធខ្ញុំកូនខ្ញុំ។ (សួរថា តើ) ពួកអស់ហ្នឹងចេញពីណា? ពិតមែនហើយ ខ្ញុំមិននិយាយពីអស់លោកទេ តែ (ជាមួយទង្វើបែបនេះ) តើប្រជាពលរដ្ឋសមនឹងបោះឆ្នោតឲ្យបក្សដទៃ ដែលមិនមែនគណបក្សប្រជាជនទេ។*

តាមពិត ការចោទប្រកាន់ខាងលើនេះ ធ្វើឡើងដោយយោងទៅលើខ្សែឆ្នាំ ១៩៧២ ដែលត្រូវបានគូសជាឯកតោភាគីដោយរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ ធាតុពិតគេបានបំភ្លេចចោលនូវផែនទីខ្សែប្រេវីយ៉េ ឆ្នាំ ១៩៣៩ ដែលសម្តេចព្រះ **នរោត្តម សីហនុ** បានយកទៅតម្កល់នៅអង្គការសហប្រជាជាតិ នាឆ្នាំ ១៩៦៤ ហើយបានតស៊ូទាមទារយ៉ាងស្វិតស្វាញ សុំឱ្យអន្តរជាតិ និង ប្រទេសសាមី យល់ព្រមទទួលស្គាល់នោះ។ ដូច្នេះ បើមើលពីសម្បកក្រៅទៅឃើញថា អ្នកចោទប្រកាន់ មកលើកិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្ត្រនេះ ហាក់មានបំណងចង់ធ្វើការវាយប្រហារខាងនយោបាយ មកលើរដ្ឋាភិបាលនៃអតីតសាធារណរដ្ឋប្រជាមានិតកម្ពុជា ស្ថិតនៅក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា ដែលមានរូបខ្ញុំផ្ទាល់ជាហត្ថលេខី ក្នុងនាមជារដ្ឋមន្ត្រីក្រសួងការបរទេស នាពេលនោះ។ ក៏ប៉ុន្តែ បើពិនិត្យស៊ីជម្រៅផ្ទៃក្នុងទៅឃើញថា ការចោទប្រកាន់នេះ មានគោលដៅវែងឆ្ងាយជាងបំណងវាយប្រហារ ទៅលើគណបក្សប្រជាជនកម្ពុជា និងលើបុគ្គល **ហ៊ុន សែន** ខ្ញុំផ្ទាល់នេះទៅទៀត។ គោលបំណងស៊ីជម្រៅរបស់គេ គឺអាចជា ការចង់អះអាងអំពីភាពត្រឹមត្រូវនៃការ

ធ្វើរដ្ឋប្រហាររបស់ក្រុមសាធារណរដ្ឋ ដើម្បីផ្តួលរលំ ព្រះករុណា សម្តេចព្រះ **នរោត្តម សីហនុ** នៅឆ្នាំ ១៩៧០ ហើយលើកតម្កើងខ្លួនឯងជាវរជនស្នេហាជាតិខ្ពស់ជាង ព្រះវររាជបិតាជាតិខ្មែររបស់យើងពេលនេះទៅទៀត ។

ដើម្បីភាពច្បាស់លាស់បន្ថែមលើការអធិប្បាយខាងលើនេះ ខ្ញុំសូមអនុញ្ញាតធ្វើការបញ្ជាក់បន្តិច អំពីបញ្ហាកោះត្រល់ និង កោះវៃ។

*សូមបញ្ជាក់ចំណុចត្រង់នេះ។ គេចាត់ទុកការបាត់បង់ដោយសំអាងលើខ្នាតផែនទីឆ្នាំ ១៩៧២ (ដែលតាមផែនទីនោះ) មានន័យរួចទៅហើយថា បានតាំងខ្លួនជាអ្នកស្នេហាជាតិជាងសម្តេចព្រះ* ***នរោត្តម សីហនុ*** *ដែលប្រើប្រាស់ត្រឹមខ្សែប្រេវីយ៉េ ១៩៣៩។ (នេះឯងដែលថា) គោលដៅវែងឆ្ងាយរបស់គេ មិនមែនវាយ* ***ហ៊ុន សែន*** *តែមួយទេ តែគឺវាយសម្តេចព្រះ* ***នរោត្តម សីហនុ*** *ដោយសារ ព្រះអង្គបានយកផែនទីកំណត់ខ្សែព្រំដែនដោយ* Ligne *ប្រេវីយ៉េ ទៅតម្កល់ទុក (នៅឯអង្គការសហប្រជាជាតិ) ហើយដែលធ្វើឲ្យកម្ពុជាបាត់បង់សិទ្ធិទាមទារកោះត្រល់។*

*ត្រង់ចំណុចនេះ យើងមិនត្រូវមានហេតុផលណាមួយបន្ទោសចំពោះសម្តេចព្រះ* ***នរោត្តម សីហនុ*** *ទេ។ ខ្ញុំសូមបញ្ជាក់បន្ថែម ចំពោះអត្ថាធិប្បាយខាងលើ អំពីបញ្ហាកោះត្រល់ និងកោះវៃ ដើម្បីជំរាបជូនថា តើយើងគួរដាក់ទោសពួកអ្នកក្លែងបន្លំដើរស្រែកធ្វើរដ្ឋប្រហារ ឬដាក់ទោសខ្ញុំជាអ្នកចុះហត្ថលេខា ឬដាក់*

*ទោសសម្តេចព្រះ* ***នរោត្តម សីហនុ****? អំពី កោះត្រល់ ដែលខាងវៀតណាមហៅថា កោះហ្វូគួក យើងអាចសួរថា តើកោះត្រល់លែងជារបស់កម្ពុជាពីពេលណាមក? (សូមស្តាប់នូវការវិវត្តជាក់ស្តែងក្នុងប្រវត្តិសាស្ត្រ)* មាន បីចំណុច (*ដូចតទៅ*)។

**ទីមួយ** អំពី **កោះត្រល់៖** តើកោះត្រល់លែងជារបស់កម្ពុជា តាំងពីពេលណាមក? ចំពោះសំណួរនេះ ខ្ញុំសូមបញ្ជាក់ដូចតទៅ៖

- នៅឆ្នាំ ១៩៣៩ លោក **ប្រេវីយ៉េ** បានដាក់កោះត្រល់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាម (កូសាំងស៊ីន)

*ក្នុង* ***ចំណុចទី ១*** *នេះ មានការនិទានតគ្នាថា មូលហេតុដើមមួយ គឺមកពីចៅហ្វាយខេត្តកំពតពុលរលក។ មិនដឹងថាពិតឬមិនពិតទេ តែដែល លោក* ***ប្រេវយ៉េ*** *គូសខ្សែហ្នឹង គឺដើម្បីជាមូលដ្ឋានទារពន្ធ។ នេះ ជាលិខិត (ផ្ញើទៅ) ហាណូយ ថ្ងៃ ៣១ ខែ មករា ឆ្នាំ ១៩៣៩ ដែល អគ្គទេសាភិបាលឥណ្ឌូចិន ជំរាបលោកទេសាភិបាលប្រចាំដែនដីកូសាំងស៊ីន ថា កោះទាំងឡាយណាដែលស្ថិតនៅខាងត្បូងខ្សែនេះ ដោយរាប់ទាំងកោះ ហ្វូគួកផង ត្រូវបន្តគ្រប់គ្រងដោយអាជ្ញាធរកូសាំងស៊ីន។ ដូចនេះ លោក* ***ប្រេវយ៉េ*** *បានហៅកោះត្រល់ហ្នឹងថា ហ្វូគួក តាំងពីមុនឪពុកម្តាយយើងកើតទៅទៀត។*

*តាមការនិទានតគ្នា មូលហេតុដែលលោក* ***ប្រេវយ៉េ***

*(សម្រេចចិត្ត)បែបហ្នឹង មកពីចៅហ្វាយខេត្តកំពត(របស់កម្ពុជា) ជំនាន់ហ្នឹងពុលរលក មិនអាចជិះទូកទៅទារពន្ធបាន។ រឿងហ្នឹង ត្រូវបន្តសិក្សាស្រាវជ្រាវ តែរឿងដែលច្បាស់ គឺសេចក្តីសម្រេច របស់លោក* **ប្រេវយេ៉**។ *ដូចនេះ មូលដ្ឋាន (អំណះអំណាង) ទីមួយ គឺលោក* **ប្រេវយេ៉** *បានដាក់កោះត្រល់ ហើយកាលហ្នឹង មិនទាំងហៅថាកោះត្រល់ផង ហៅថា ហ្វ៊ូគួក តែម្តង (ក្រោមការគ្រប់គ្រងរបស់វៀតណាម)។*

- នៅឆ្នាំ ១៩៤៩ កូសាំងស៊ីន ត្រូវបានបារាំងប្រគល់ទៅឲ្យព្រះចៅបៅដាយ

***ទីពីរ*** *ទៀត ពេលនោះសភាបារាំងប្រជុំ (ដែលចូលរួមក្នុងសម័យប្រជុំនោះ) យើងបានបោះឆ្នោតអនុប្បវាទ លើដីខ្លួនឯង។ (ពិតហើយថា) ទោះបីបោះឆ្នោតប្រឆាំង ឬបោះឆ្នោតព្រមក៏ដោយ ក៏គ្មានឥទ្ធិពលលើការសម្រេច ប៉ុន្តែហោចណាស់មិនគួរបោះឆ្នោតអនុប្បវាទទេ។ កាលនោះគណប្រតិភូដឹកនាំដោយព្រះអង្គម្ចាស់* **ពីង ពាង**។ *ខ្ញុំសុំទោស វិញ្ញាណខន្ធរបស់ព្រះអង្គម្ចាស់ព្រះអង្គម្ចាស់ក្សត្រិយ៍ តែបើជាទូលបង្គំវិញ ពេលនោះទូលបង្គំបោះឆ្នោតប្រឆាំងហើយ មិនបោះអនុប្បវាទលើដីខ្លួនឯងទេ។*

- បន្ទាប់មកនៅឆ្នាំ ១៩៦៤ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះប្រមុខរដ្ឋនាពេលនោះ បានយកផែនទីខ្សែប្រេវីយេ៉ ឆ្នាំ ១៩៣៩ ទៅតម្កល់នៅអង្គការសហប្រជាជាតិ ហើយស្នើសុំ

ឲ្យអន្តរជាតិ និង ប្រទេសសាមី ទទួលស្គាល់ថាជាខ្សែព្រំដែនសមុទ្ររវាងកម្ពុជា និង វៀតណាម។

ចំណុចចុងក្រោយនេះ មានន័យថា កម្ពុជាឈប់ទាមទារយកកោះត្រល់មកវិញហើយ ពីព្រោះវាជាកោះខាងត្បូងខ្សែប្រេវីយ៉េ។ ជំហរនេះ ព្រះប្រមុខរដ្ឋ បានបញ្ជាក់ជាច្រើនដងជាមួយថ្នាក់ដឹកនាំ វៀតណាមខាងជើង និង វៀតណាមខាងត្បូង ថាព្រះអង្គមិនទាមទារយកកោះត្រល់មកវិញទេ។ រដ្ឋាភិបាលកម្ពុជា បន្តបន្ទាប់មកទៀត ក៏បានទទួលយកគោលជំហរនេះ ដោយគោរពតាមព្រះរាជតំរិះដ៏ ខ្ពង់ខ្ពស់បំផុតរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ដែលជាវិរជនជនស្នេហាជាតិ ដ៏កំពូលផុតគេរបស់កម្ពុជា។ ដោយឡែក មានតែរដ្ឋាភិបាលនៃសាធារណរដ្ឋខ្មែរមួយប៉ុណ្ណោះ ដែលបដិសេធមិនទទួលយកជំហរនេះ។ ក្រោយមកទៀត ព្រះមហាក្សត្រ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** បានបញ្ជាក់ជំហរនេះជាថ្មីម្តងទៀតនៅក្នុងព្រះរាជសារផ្ញើរជូនលោក **ផាំ វ៉ាន់ដុង** នាយករដ្ឋមន្ត្រីវៀតណាម ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩។

*នេះ ជាលិខិតរបស់ព្រះករុណាបានផ្ញើជូនទៅលោក* **ផាំ វ៉ាន់ដុង**។ *ចំណុចនេះ វាជួនលើចំណុចសំខាន់បី ដែលកម្ពុជាបោះបង់សិទ្ធិទាមទារកោះត្រល់ហើយ ឬថាកោះនានានៅខាងត្បូងខ្សែប្រេវីយ៉េទាំងអស់ មិនត្រឹមតែកោះត្រល់មួយទេ។ មូលហេតុគឺ លោក* **ប្រេវយ៉េ** *បានប្រគល់ឲ្យវៀតណាមនាឆ្នាំ ១៩៣៩ សភាបារាំងប្រគល់កូសាំងស៊ីនឲ្យវៀតណាម ១៩៤៩ មានន័យថា ១០ ឆ្នាំក្រោយ។ ដល់ចុងក្រោយ យើងយកផែនទីទៅតម្កល់ (នៅសហប្រជាជាតិ) សុំឲ្យទទួលស្គាល់នូវ* Ligne *ប្រេវីយ៉េ*

*ដែលមានន័យស្មើ នឹងយើងបានបោះបង់សិទ្ធិទាមទារនេះចោលរួចស្រេចទៅហើយ។ សុំបញ្ជាក់ជូនថា ខ្ញុំអត់ទាន់កាន់អំណាចទេពេលនោះ។ តែក៏សុំបញ្ជាក់ថា យើងគ្មានហេតុផលណាមួយត្រូវទំលាក់កំហុសទៅសម្តេចព្រះ* **នរោត្តម សីហនុ** *ទេ ពីព្រោះថាដោយសារហេតុផល ទី ១ និង ហេតុផលទី ២ ទើប ហេតុផល ទី ៣ កើតមាន។ ព្រះអង្គត្រូវតែតម្រូវយកផែនទី ដែលកំណត់* Ligne *ប្រេវីយ៉េ ជាខ្សែបន្ទាត់ព្រំដែន ព្រោះសមត្ថភាពកម្ពុជាយើងមានត្រឹមប៉ុណ្ណឹង។*

*(ពួកទាំងនេះគួរ) ឈប់ជេរខ្ញុំថា ធ្វើឲ្យបាត់ទឹកបាត់ដី ព្រោះនេះជារឿងតាំងពី ១៩៣៩ និង ១៩៤៩ គឺមុនខ្ញុំកើតទៅទៀត។ សូម្បីព្រះមហាក្សត្រ ដែលជាអ្នកស្នេហាជាតិដ៏កំពូល ក៏ព្រះអង្គត្រូវបង្ខំចិត្តធ្វើម៉េចឲ្យគេទទួលស្គាល់ថា* Ligne *ប្រេវីយ៉េនេះ គ្រប់គ្រាន់ហើយ។ ព្រះអង្គមិនលោភលន់ ដូចពួក* **លន់នល់** *ដែលពូកែត្រឹមតែគូរផែនទីនោះទេ។ នេះរឿងកោះត្រល់និងកោះទាំងឡាយនៅខាងត្បូង* Ligne *ប្រេវីយ៉េ។ ចង់អស់លោកថាយ៉ាងម៉េច ជារឿងរបស់អស់លោក តែរឿងផ្លូវច្បាប់គឺវាអញ្ចឹង។ នេះមិនមែនជាការនិយាយដោយខ្វះការទទួលខុសត្រូវចំពោះដោគវាសនាប្រទេសជាតិទេ។ សួរថាអស់លោកចង់ទៅយកតាមមធ្យោបាយណា។ បើចង់យកដោយប្រើផ្លូវច្បាប់ ក៏ប្រើ*

មិនឈ្នះគេ បើប្រើទាហានក៏ប្រើមិនឈ្នះគេ។ ប៉ុន្តែសម័យនេះ គេមិននិយមប្រើប្រាស់កម្លាំងដោះស្រាយបញ្ហាទេ មិនថា ប្រទេសវៀតណាមធំជាងទេ ទោះបីជាប្រទេសតូចជាង ក៏មិនត្រូវធ្វើបែបហ្នឹងដែរ។

កុំធ្វើដូច(អតីត)រដ្ឋាភិបាល **អភិសិទ្ធ** (នៃប្រទេសថៃ) ដែលប្រើកម្លាំងដោះស្រាយបញ្ហានោះ។ ឥឡូវរឿងយើងនិងថៃ បានធូរស្រាលបន្តិចហើយ នៅរង់ចាំតែតុលាការអន្តរជាតិ (ធ្វើការបកស្រាយសាលក្រមទេ)។ រហូតទាល់តែ **អភិសិទ្ធ** ធ្លាក់ពីតំណែង ទើបសភាពការណ៍ទល់ដែនបានស្រួល។ ហ្នឹងឯង ជាមិត្តភក្តិរបស់ឯកឧត្តម **សុន ឆ័យ**។ ទោះបីខ្ញុំ ក៏ត្រូវធ្វើការជាមួយ **អភិសិទ្ធ** ដែរ (បើ **អភិសិទ្ធ** នៅកាន់អំណាច) ព្រោះ ជៀសមិនរួច។ តែឥឡូវ ជៀសបានហើយ។ បើ **អភិសិទ្ធ** សុំទស្សនកិច្ចស្រុកខ្មែរ ខ្ញុំមិនឲ្យមកទេ។ តែពេល **អភិសិទ្ធ** ធ្វើរដ្ឋាភិបាល ខ្ញុំត្រូវធ្វើការជាមួយ។ ទោះបីវៃគ្នាក៏គង់តែត្រូវទៅមកប្រជុំជាមួយគ្នា។

និយាយពី កោះត្រល់ ឲ្យច្បាស់ទាំងអស់គ្នា។ បើអ្នកណាចង់ទាមទារសូមអញ្ជើញទៅខ្លួនឯងទៅ។ ចាំដល់លោកកាន់អំណាច ចង់ប្រើកំឡាំងយោធាក៏ប្រើទៅ។ ខ្ញុំជឿជាក់ថាប្រជាជនកម្ពុជា មិនគាំទ្រអស់លោកនាំកូនគេទៅច្បាំងងាប់អត់អំពើទេ។

*ការពារអ្វីដែលមានស្រាប់ មានន័យថា ទាមទារ Ligne ប្រេវីយេ៉ ឲ្យបានមក ជាការគ្រប់គ្រាន់ណាស់ហើយ។ ខ្ញុំនឹងពន្យល់ខាងក្រោម។*

**ទីពីរ** អំពី **កោះវ៉ៃ៖** ដោយយោងលើខ្សែឆ្នាំ ១៩៧១, នៅឆ្នាំ ១៩៧៤ កម្លាំងពួកធីវគីនៃវៀតណាម ខាងត្បូង បានប្រកាសកាន់កាប់យកកោះវ៉ៃនេះ ដោយបានដាក់ទ័ពនៅលើកោះនេះ និង បានបញ្ជាកប៉ាល់រកប្រេងរបស់ក្រុមហ៊ុនបារាំង ELF ឲ្យចាកចេញក្នុងរយៈពេល ១៥ ថ្ងៃ ។ ក្រុមហ៊ុនបារាំងនេះ ក៏បញ្ឈប់ការរុករកប្រេង ហើយចាកចេញពីតំបន់កោះនេះទៅ។ ហេតុដូច្នេះហើយ បានជាមានសេចក្តីត្រូវការចាំបាច់ ក្នុងការបែងចែកកោះទាំងនោះឲ្យបានច្បាស់លាស់ ស្របតាមសេចក្តីសំរេចរបស់លោកប្រេវីយេ៉ និង ស្របទៅនឹងគោលការណ៍ខ្សែព្រំដែនមិនកែប្រែ ដែលកម្ពុជាបានប្រកាសទទួលយករហូតមក ដើម្បីងាយស្រួល ក្នុងការការពារ, ការគ្រប់គ្រង និង ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋនៅតំបន់នោះ។ ត្រង់នេះ ខ្ញុំសូមគូសបញ្ជាក់ច្បាស់ថា គោលដៅចម្បងនៃកិច្ចព្រមព្រៀងតំបន់ទឹកប្រវត្តិសាស្រ្ត គឺការកំណត់អធិបតេយ្យភាពរបស់កម្ពុជាលើកោះវ៉ៃនេះឯង។

*ខ្ញុំសុំពន្យល់កន្លែងហ្នឹងជូន។ ហេតុអ្វី ចាំបាច់មានតំបន់ទឹកប្រវិត្តសាស្រ្ត។ សូមអស់លោកកត់ត្រាឲ្យច្បាស់កន្លែងហ្នឹង។ ប៉ុន្តែ បើអស់លោកមិនកត់ ក៏មានការថតទុកដែរ។ ថ្ងៃក្រោយអស់លោកសួរខ្ញុំពីរឿងហ្នឹង ខ្ញុំឲ្យចាក់ត្រង់ហ្នឹងជូនទៀត។ ហេតុអីចាំបាច់មានតំបន់ទឹកប្រវត្តិសាស្រ្ត? បើសិនជា កុំមានខ្សែបន្ទាត់*

*ព្រំដែនរបស់ ធីវគី ឆ្នាំ ៧១ ដែលគូសយកកោះវ៉ៃ និងការដាក់ទ័ពកាន់កាប់កោះវ៉ៃ ហើយបណ្តេញក្រុមហ៊ុនប្រេងចេញ ក៏គ្មានការចាំបាច់ធ្វើតំបន់ទឹកប្រវត្តិសាស្ត្រទេ។ គឺ ដោយសារតែខ្សែបន្ទាត់ ឆ្នាំ ៧១ ដែលគូសយកកោះវ៉ៃ និងដែនទឹកខ្មែរជិតមកដល់កោះតាង (បង្ហាញផែនទីឡើងវិញ) នេះ សូមមើលខ្សែពណ៌ខៀវនេះ ហើយជ្រុងក្រហមនេះគឺកោះវ៉ៃ (ដែលធ្វើអោយមានចំណោទថា) តើធ្វើម៉េច កំណត់អធិបតេយ្យភាពកម្ពុជាលើកោះវ៉ៃបាន បើខាងវៀតណាមទាមទារខ្សែសមចម្ងាយ ឯកម្ពុជាទារខ្សែប្រេវីយ៉េ។*

*ពិតមែនតែពេលចុះហត្ថលេខា ខ្ញុំទើបមានអាយុ ៣០ ឆ្នាំ គឺ(ឆ្នាំ ១៩) ៨២ ហើយខ្ញុំកើត (១៩)៥២, ឥឡូវ៦០ ឆ្នាំហើយ, ក៏មូលហេតុដើមចមរបស់វាចេញមកពីខ្សែពណ៌ខៀវរបស់ ធីវគី ហើយបន្ទាប់ទៅការដាក់ទ័ពលើកោះវ៉ៃ។ ដូចនេះ តើអតីតសាធារណរដ្ឋប្រជាមានិតកម្ពុជា មានការចាំបាច់កំណត់អធិបតេយ្យលើកោះវ៉ៃឬទេ? វាច្បាស់ជាមាន។ តែមានលើមូលដ្ឋានអី បើម្ខាងទាមទារខ្សែសមចម្ងាយ និងម្ខាងទាមទារ* Ligne *ប្រេវីយ៉េ។ (ក្នុងស្ថានភាពនោះហើយ ដែល) ទីបំផុតមានការស្រុះស្រួលគ្នាបង្កើតតំបន់ទឹកប្រវត្តិសាស្ត្រ ដោយតភ្ជាប់ម្ខាងចេញពីចំណុចកោះវ៉ៃរបស់កម្ពុជា និងម្ខាងទៅភ្ជាប់កោះថូជូ។ ហេតុនេះ គោល*

*ដោះចំបងគឺ ការកំណត់អធិបតេយ្យខ្មែរលើកោះវ៉ៃ តែរឿងទឹកដីបែងចែកស្អីៗ ក្រោយពីនោះ អត់ទាន់មានបាត់បង់អីទាំងអស់។ យើងនៅបន្តគោលជំហរនៃការចរចារ ជាមួយវៀតណាម ដោយយោងលើ* Ligne *ប្រេវីយ៉េ។*

*តើអស់លោកមានបានចោទសួរទេថា នៅពេលដែលកងទ័ពវៀតណាមស្ថិតនៅកម្ពុជានៅឡើយ រដ្ឋមន្ត្រីការបរទេសដ៏ក្មេងមួយនេះ ហ៊ានទាមទារជាមួយវៀតណាមអំពីបញ្ហា* Ligne *ប្រេវីយ៉េ ទេ? ប៉ុន្តែ ដោយសារហេតុផលខាងនយោបាយ អស់លោកគិតតែពីជេរប្រទេចផ្តាសា ដោយគ្មានបានដឹងពីការខិតខំទាំងនេះឡើយ។ (ខ្ញុំគិតថា) អស់លោកគួរធ្វើដំណើរ ដោយ(យើងសុខចិត្តចេញជា) ឧទ្ទម្ភាគចក្រ ឬជិះកប៉ាល់ជាមួយគ្នា - ទោះបីថាយើងមាននយោបាយខុសគ្នា, តែយើងខ្មែរដូចគ្នា - ទៅមើលកោះវ៉ៃម្តង។ ក្រោយពីចុះហត្ថលេខាហើយ កងទ័ពខ្មែរឈរជើងលើកោះវ៉ៃរហូត។ ការពិត ជំនាន់សម្តេចព្រះ* **នរោត្តម សីហនុ** *អត់ (ហើយជំនាន់)* **លន់ នល់** *ក៏អត់មានកងទ័ពនៅទីនោះដែរ។ ទោះមិនដាក់ទ័ពនៅលើកោះវ៉ៃក៏បាន នាពេលនោះ។ ប៉ុន្តែ យើងខ្ញុំត្រិះរិះថា ជាការចាំបាច់ (នៅពេលក្រោយមកនេះ) ទោះបីគ្មាន* **ប៉ុល ពត** *វាយនៅលើហ្នឹងក៏ដោយ។ ឥឡូវជាភ័ព្វសំណាងណាស់ ដែលអណ្តូងយើងជីកបានចេញទឹក។ ដូចនេះ*

*តាំងពីឆ្នាំ ១៩៨២ មក យើងមានកងទ័ពជើងទឹកប្រចាំការនៅទីនោះៗ*

*ឥឡូវ ខ្សែខៀវរបស់ពួក ជីវគី មិនមានប្រសិទ្ធភាពទៀតទេ បន្ទាប់ពីតំបន់ព្រំដែនទឹកប្រវត្តិសាស្ត្រកើតមានៗ វៀតណាមមានពីរ គឺវៀតណាមខាងជើងដែលក៏ថ្កោលទោស ជីវគី ដែលវ៉ៃកាន់កាប់កោះវ៉ៃដែរៗ សូមអស់លោកកុំមើលថា ពួកខ្ញុំនៅទីក្រុងភ្នំពេញសុទ្ធតែកូនក្មេងៗ យើងមានគោលដៅជាក់លាក់ ហើយប្រហែលជាថ្ងៃនេះ វៀតណាមភ្ញាក់ថា កាលពី ៣១ ឆ្នាំមុន* **ហ៊ុន សែន** *មានគំនិតអញ្ចឹងទេឬៗ គោលដៅ គឺ កំណត់អធិបតេយ្យភាពកម្ពុជាលើកោះវ៉ៃៗ ចំពោះរឿងហ្នឹង តើពួកកាកសំណល់ពីសម័យ* **លន់ នល់** *ដឹងពីខ្សែហ្នឹងទេ? ហើយដឹងថាគេដាក់ទ័ពទេ? បើខ្លួនមិនច្បាស់ទេ នៅឲ្យស្ងៀមទៅទុកឲ្យគេធ្វើៗ តែឥឡូវ (មានអ្វីត្រូវ)យកមក បើយើងកាន់កាប់ តាំងពីឆ្នាំ ១៩៨២ មកម៉្លេះៗ សមាជិកសភាទាំងអស់ រាប់ទាំងសមាជិកព្រឹទ្ធសភាផងអាចទៅមួយម៉ារីន ហើយខ្ញុំនឹងចេញថ្ងៃបាយដើម្បីឲ្យអស់លោកទៅឃើញកោះវ៉ៃដោយផ្ទាល់ៗ*

*(វារលែងតែបានទៅឃើញ ហើយ) បក្សនយោបាយមិនតម្រូវឲ្យអស់លោកនិយាយ ក៏ប៉ុន្តែបើបានទៅឃើញ អស់លោកនឹងបានដឹង ពីការលំបាករបស់កងទ័ពកាលពីមុនដូចម្ដេចៗ*

*ឥឡូវស្រួលបន្តិចហើយ ព្រោះម្យ៉ាងមានទឹកសាប ដែលអាចដោះដូរជាប្រេង និងជាត្រីបានទៀត ព្រោះអ្នកនេសាទត្រូវការទឹក។ បងប្អូនពិតជាកំពុងមើលការផ្សាយបន្តផ្ទាល់នេះហើយ។ ខ្ញុំបានបញ្ជាក់ច្បាស់ហើយអំពីកោះវ៉ៃ និងគោលដៅនៃតំបន់ទឹកប្រវត្តិសាស្ត្រ។ ដែនទឹកគ្មានការបាត់បង់ សូម្បីតែមួយដំណក់នៅឡើយទេ។ (អោយបាត់ដូចម្តេច) បើមិនទាន់ដឹងថានៅត្រង់ណាផង។ (យើង) កំពុងចរចានៅឡើយ ហើយ វៀតណាមទាមទារខ្មែរ សមចម្ងាយ ឯយើងទាមទារ* Ligne *ប្រេវីយ៉េ។ ការទាមទារ* Ligne *ប្រេវីយ៉េ នេះទៀត ក៏មិនមែនទើបតែធ្វើឥឡូវនេះទេ តែតាំងពីឆ្នាំ ១៩៨២ ឯនោះ។*

*ដោយសារតែ ការទាមទារ* Ligne *ប្រេវីយ៉េ មិនទាន់បាននោះឯងហើយ ឬការដែលយើងមិនព្រមទៅតាមសមចម្ងាយរបស់វៀតណាមនោះឯងហើយ ទើបចាំបាច់ត្រូវមានតំបន់ទឹកប្រវត្តិសាស្ត្រ ដើម្បីឈានទៅកំណត់អធិបតេយ្យភាពរបស់កម្ពុជាលើកោះវ៉ៃ។ ឥឡូវខ្ញុំចូលដល់សំនួររបស់ឯកឧត្តម* **សុន ឆ័យ** *ដែលជាចំណុចធំ ទី ៣។*

### III អំពី សំណួររបស់ឯកឧត្តម សុន ឆ័យ

ខ្ញុំមានជំនឿថា ការអធិប្បាយទាំងអម្បាលមាណពីខាងលើនេះពិតជាបានគ្របដណ្តប់ទៅលើសំណួរភាគច្រើនរបស់ឯកឧត្តម **សុន**

**ន័យ** រួចហើយ ។ ម្យ៉ាងទៀត ខ្ញុំក៏ដឹងដែរថា **"វាពិតជាការលំបាកខ្លាំងណាស់ កាលណាយើងខំនិយាយអំពីបញ្ហាមួយប្រាប់ដល់អ្នកត្រចៀកល្អតែធ្វើថ្លង់ ឬចង់បង្ហាញអ្វីមួយដល់អ្នកភ្នែកភ្លឺ តែធ្វើជាមើលមិនឃើញ"** នោះ។ យ៉ាងណាក៏ដោយ ដោយសារឯកឧត្តមលើកសំណួរមកហើយ ខ្ញុំសូមផ្តល់នូវការបំភ្លឺបន្ថែមតាមចំណុចមួយចំនួនដូចតទៅ៖

**<u>សំណួរទី១</u> ការធានាបូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា តាមព្រំដែនកំណត់ក្នុងផែនទី ដូចមានចែងក្នុងមាត្រា ២ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣។**

ជារួមខ្ញុំយល់ថា នៅក្នុងការអធិប្បាយខាងលើ ខ្ញុំពិតជាបានឆ្លើយនឹងសំណួរនេះសព្វគ្រប់អស់ហើយ។ នៅពេលនេះ ខ្ញុំគ្រាន់តែចង់គូសបញ្ជាក់បន្ថែមថា ប្រហែលជាដោយសារតែមានទស្សនៈនយោបាយចង្អៀតចង្អល់ខ្លាំងពេក បានជាអ្នកនយោបាយមួយចំនួនគិតថា នៅជុំវិញកម្ពុជាពុំមានប្រទេសណា ក្រៅពីប្រទេសវៀតណាមនោះទេ។ ហេតុនេះហើយ តាំងតែពីឆ្នាំ ១៩៩៣ មក គេនាំគ្នាគិតធ្វើបងផ្ទះតែម្ខាងនៅទិសខាងកើត។ មាត្រា ២ នៃរដ្ឋធម្មនុញ្ញចែងថា : **"បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាត ក្នុងព្រំដែនរបស់ខ្លួនដែលបានកំណត់ក្នុងផែនទីខ្នាត ១/១០០ ០០០ ធ្វើនៅចន្លោះ ឆ្នាំ ១៩៣៣–១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះឆ្នាំ ១៩៦៣- ១៩៦៩"** ។ ខ្ញុំសូមធ្វើការកត់សម្គាល់លើចំណុចមួយចំនួនជុំវិញមាត្រានេះ។

គេគ្រប់គ្នាដឹងច្បាស់ថា **តាមរយៈការបោះឆ្នោតដែលរៀបចំឆាកដោយ UNTAC នៅឆ្នាំ ១៩៩៣** គណបក្សប្រជាជនកម្ពុជាមិនបានផុសចេញមកជា គណបក្សដែលទទួលបានការគាំទ្រនាំមុខគេ និងមានអាសនៈ

ច្រើនជាងគេនៅក្នុងរដ្ឋសភានោះទេ។ បន្ថែមលើនេះ អារម្មណ៍របស់អ្នកនយោបាយដែលបានងើបចេញមកពីការបោះឆ្នោតដែលរៀបចំឆាកដោយ UNTAC ក្នុងនាមជាអ្នកឈ្នះនាពេលនោះ គឺ ពោរពេញទៅដោយការសង្ស័យចំពោះគណបក្សប្រជាជនកម្ពុជា។ គេចេះតែគិតថា គណបក្សប្រជាជនកម្ពុជា ជាអាយ៉ងរបស់វៀតណាម និង ឃុបឃិតជាមួយវៀតណាម។ល។ ដែលមកទល់ពេលនេះហើយ នៅតែមានអ្នកបន្តគិតយ៉ាងដូច្នេះនៅឡើយ ហើយថែមយកចំណុចនេះ មកដាក់ជាយុទ្ធសាស្ត្រសម្រាប់ការធ្វើអាជីវកម្មកេងចំណេញខាងនយោបាយរបស់ខ្លួនទៀតផង។ គឺអាចដោយសារហេតុដូច្នេះហើយ បានជា អ្នកតាក់តែងរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ សរសេរមាត្រា ២ នៃរដ្ឋធម្មនុញ្ញនេះ ដោយផ្ដោតអារម្មណ៍របស់ខ្លួន សំដៅតែលើព្រំដែននៃទិសខាងកើតរបស់ប្រទេសតែប៉ុណ្ណោះ ដោយភ្លេចគិតថា កម្ពុជាមានព្រំដែនទិសខាងលិចជាមួយថៃ និង ទិសខាងជើងជាមួយនិងឡាវ។ ប្រការនេះ បានធ្វើឲ្យគេភ្លេចសូន្យឈឹង អំពីភាពចាំបាច់ក្នុងការបញ្ចូលផែនទីព្រំដែនអន្តរជាតិ កម្ពុជា–ថៃ ខ្នាត ១/២០០ ០០០ ទៅក្នុងមាត្រា ២ នេះ នៃរដ្ឋធម្មនុញ្ញ។

មួយវិញទៀត ការកំណត់ឆ្នាំបោះពុម្ពផ្សាយលើផែនទីនៅចន្លោះឆ្នាំ ១៩៣៣–១៩៥៣ ក៏មិនស្របទៅនឹងការជាក់ស្ដែងទេ ព្រោះថា៖

- ផែនទីកំណត់ព្រំដែន និង បោះបង្គោលព្រំដែនរវាងកម្ពុជា–កូសាំងស៊ីន–អាណ្ណាមមានតាំងពីទសវត្សរ៍ឆ្នាំ ១៨៨០ មកម្ល៉េះ ឈ្មោះថា ផែនទីមណ្ឌលរដ្ឋបាលកូសាំស៊ីន។
- ផែនទីព្រំដែនកម្ពុជា–ថៃ កំណត់ដោយអនុសញ្ញា និង សន្ធិសញ្ញាបារាំង–សៀម ឆ្នាំ១៩០៤ និង ឆ្នាំ ១៩០៧ មានខ្នាត ១/២០០ ០០០ បោះពុម្ព ក្នុងឆ្នាំ ១៩០៧ ដល់ ១៩០៩។

ដូចគ្នានោះដែរ ការកំណត់ខ្នាតផែនទីត្រឹម ១/១០០ ០០០ ជាការខ្វះខាតមួយដ៏មានគ្រោះថ្នាក់ដល់ប្រទេសជាតិ ព្រោះផែនទីព្រំដែនជាមួយសៀម ពុំមែនមានខ្នាត ១/១០០ ០០០ ទេ តែជាផែនទី ដែលធ្វើឡើងបន្ទាប់ពីអនុសញ្ញា និង សន្ធិសញ្ញាបារាំង–សៀម ឆ្នាំ ១៩០៤ និង ឆ្នាំ ១៩០៧ ដែលមានខ្នាត ១/២០០ ០០០ ហើយមាន ៧ តំបន់ (៧សន្លឹក)។ គឺផែនទីនេះហើយ ដែលព្រះប្រមុខរដ្ឋ សម្តេចព្រះ **នរោត្តម សីហនុ** បានយកទៅតម្កល់នៅអង្គការសហប្រជាជាតិ នៅឆ្នាំ ១៩៦៤ ហើយគឺផែនទីនេះដែរ ដែលកម្ពុជាយើងយកមកប្រើសព្វថ្ងៃ នៅតុលាការយុត្តិធម៌អន្តរជាតិក្រុងឡាអេ ក្នុងរឿងក្តីក្តាំជាមួយថៃ សុំឲ្យតុលាការធ្វើការបកស្រាយសាលក្រម ឆ្នាំ ១៩៦២ នោះ។ ដូច្នេះ ខ្ញុំយល់ថា យើងគួរតែខិតខំធ្វើការ ដើម្បីលុបបំបាត់ភាពចន្លោះប្រហោងនេះ។

*ខ្ញុំសុំអភ័យទោសពី ព្រះតេជគុណ ព្រះសង្ឃគ្រប់ព្រះអង្គ ពីបងប្អូនជនរួមជាតិ មេត្តាយោគយល់។ ត្រង់ចំណុចនេះ ខ្ញុំមិនគួរយកមកនិយាយទេ ប៉ុន្តែមានអ្នកគិតគូរផលប្រយោជន៍ផ្ទាល់ខ្លួនជ្រុលហួសហេតុពេក ដែលខ្ញុំមិនអាចទ្រាំបាននឹងការឈឺចាប់ត្រូវតែនិយាយ ដើម្បីបង្ហាញពីតម្លាភាព តែដែលតម្លាភាពនេះបានធ្វើឲ្យមានផលប៉ះពាល់តិច ឬច្រើនដោយសារអស់លោកបង្ខំ។ ខ្ញុំសូមបញ្ជាក់ថា រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ពិតមែនតែមានសមាសភាពពីគណបក្សប្រជាជន តែក្នុងឋានៈជាបក្សដែលគេសង្ស័យ យើងអត់បាននិយាយអ្វីទាំងអស់លើបញ្ហាទាក់ទិន នឹងមាត្រា ២។ ប៉ុន្តែ សួរថា មាត្រា ២ មានន័យគ្រប់គ្រាន់ទេ? (សូម*

*ទាញអារម្មណ៍ថា តាមមាត្រានេះ វាដូចជាកម្ពុជា មាន) ព្រំដែន (ត្រូវការពារ) តែពីវៀតណាមប៉ុណ្ណោះ។*

*អារម្មណ៍មនុស្សទាំងឡាយពេលនោះ ពោរពេញទៅដោយការសង្ស័យថា ពួកនេះ (គណបក្សប្រជាជន) ជាពួកអាយ៉ងវៀតណាម។ (ដោយហេតុនេះ គេនាំគ្នា) ភ្លេចគិតដល់ព្រំដែនជាមួយថៃ ព្រំដែនជាមួយឡាវ ដែលត្រូវប្រើប្រាស់ខ្នាតផែនទីផ្សេង និងភ្លេចពីចន្លោះប្រហោងក្នុងតំបន់សមុទ្រ។ ជាចន្លោះប្រហោងមួយធំណាស់។ ការកំណត់ឆ្នាំនៃផែនទីហ្នឹងក៏គ្រោះថ្នាក់ទៀត។ (ក្នុងរដ្ឋធម្មនុញ្ញ) យើងបានកំណត់ (ការប្រើប្រាស់ផែនទី) ត្រឹមឆ្នាំ ១៩៣៣ ដែលមានន័យថា បើផុតឆ្នាំ ១៩៣៣ អត់អាចប្រើប្រាស់បានទេ។ ប៉ុន្តែ កិច្ចព្រមព្រៀង (ឬសន្ធិសញ្ញា) ដាក់ថា កាលបរិច្ឆេទមុនឆ្នាំ ១៩៥៤ ឬកៀកបំផុតឆ្នាំ ១៩៥៤ អញ្ចឹងមានន័យថា មុន ១៩៥៤ ដល់ឆ្នាំ ១៨០០ ក៏អាចទាញមកប្រើប្រាស់បាន។ ការដែលយើងមកចងដៃខ្លួនឯងក្នុងរដ្ឋធម្មនុញ្ញនេះ តើត្រូវកែឬយ៉ាងម៉េច។ ឥឡូវសូមអង្គសភាពិចារណាទៅ តើត្រូវកែរដ្ឋធម្មនុញ្ញ ឬយ៉ាងម៉េច? ការធ្វើរបងផ្ទះតែម្ខាងនេះ មិនមែន (មកពីការ) គិតជាតិទេ តែមកពីការគិតធ្វើជាសត្រូវតែជាមួយវៀតណាមហ្នឹង។ បើជាការគិតពីជាតិ គេពិតជាត្រូវគិតទាំងសងខាង ឬត្រូវមានរបងជុំវិញទាំងអស់។*

*ពេលនោះ គណបក្សប្រជាជន ក្នុងឋានៈជាអ្នកបាត់ប្រៀប ទ្រាំខាំមាត់សង្កត់ចិត្ត តែថ្ងៃនេះមិនសង្កត់ចិត្តបានទេ។ សូមព្រះសង្ឃ និងប្រជាពលរដ្ឋយោគយល់ចំពោះការលំបាករបស់ខ្ញុំព្រះករុណាខ្ញុំ ព្រោះគេមិនឲ្យយើងសុខ ហើយផែនដីហ្នឹងក៏យើងទូលម្នាក់ឯងមិនរួចដែរ។ ដោយសារជាផែនដីទាំងអស់គ្នានេះហើយ បើយើងទុកឲ្យគេបន្តរឿងហ្នឹងតទៅទៀត សភាពការណ៍នឹងមិនស្ងប់ឡើយ។ យើងគួរតែកែប្រែឥរិយាបថខ្លះ កុំជ្រុលហួស កុំជ្រុលនិយម កុំផ្កាប់មុខពេក។ ដីយើងត្រូវមានរបង មិនថាពីខាងជើង ខាងត្បូង ឬខាងលិចទេ ត្រូវធ្វើទាំងអស់។ ឥឡូវយើងកំពុងបន្តចរចាជាមួយឡាវ ដែលចំណុចមួយចំនួនក៏ស្របគ្នាហើយ និងចំណុចមួយចំនួនក៏មិនទាន់ស្រប ដូចជារឿងស៊ុំទឹកនេះ ឡាវមិនទាន់ឆ្លើយតប។*

យ៉ាងណាក៏ដោយ ក្នុងការបំពេញការងាររបស់ខ្លួន រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់គិតគូរដល់ របងជុំវិញផ្ទះ ដោយយើងបានដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្ររួម សម្រាប់ដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងទាំងអស់ ហើយប្រឹងប្រែងអនុវត្តគោលនយោបាយជាយុទ្ធសាស្ត្រនេះ ឲ្យសម្រេចបានផ្លែផ្កាល្អប្រសើរមួយចំនួន។ ក៏ប៉ុន្តែដោយសារតែផលប្រយោជន៍នយោបាយផ្ទាល់ខ្លួនលើកនេះ ក៏ដូចជាលើកមុនៗ ដែរ ឯកឧត្តម **សុន ឆ័យ** និងសហសេរីកមិនមានកង្វល់នឹងរបងផ្ទះរបស់កម្ពុជា ដែល ត្រូវប្រឈមនឹងការលំបាកនៅកន្លែងផ្សេងទៀតប៉ុន្មាននោះទេ។ ហេតុនេះហើយ ទើបពេលនេះ ខ្ញុំត្រូវផ្តល់ការបំភ្លឺជូនដល់

អង្គរដ្ឋសភា និង ប្រជាពលរដ្ឋកម្ពុជាទាំងមូលជ្រាប ដើម្បីជម្រះនូវមន្ទិលទាំងឡាយពាក់ពន្ធ័នឹងការងារដោះស្រាយបញ្ហាព្រំដែន តែជាមួយនឹងប្រទេសវៀតណាមមួយប៉ុណ្ណោះ។

មួយវិញទៀត ដូចបានលើកឡើងពីខាងដើម ខ្ញុំចង់ធ្វើការបញ្ជាក់បន្ថែមខ្លះទៀត អំពីផ្ទៃក្រឡាដីរបស់កម្ពុជា ដែលគេគ្រប់គ្នាចាំរត់មាត់ថាមានទំហំ ១៨១ ០៣៥ គីឡូម៉ែត្រក្រឡានោះ។ តាមពិតអំពីទំហំផ្ទៃក្រឡានេះ គឺមានតួលេខច្រើនខុសគ្នា និង ចេញពីប្រភពដើមដោយឡែកពីគ្នាគឺ៖

**ទី១** តួលេខ ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា ដែលមានប្រើជាផ្លូវការនៅក្នុងសៀវភៅសិក្សាអប់រំជាយូរមកហើយ។ ពីខាងដើម ខ្ញុំក៏បានសាកល្បងពន្យល់ហើយដែរ អំពីប្រភពនៃការគណនារកតួលេខនេះ។

**ទី២** តួលេខ ១៧៥ ៤៥០ គីឡូម៉ែត្រក្រឡា ដែលតំណាងជាន់ខ្ពស់បារាំងនៅកម្ពុជាបានរាយការណ៍ ឲ្យទៅអគ្គទេសាភិបាលឥណ្ឌូចិន បន្ទាប់ពីបានខេត្តបាត់ដំបង សៀមរាប ស៊ីសុផុន ពីសៀមមកវិញ។

**ទី៣** តួលេខ ១៧៩ ០០០ គីឡូម៉ែត្រក្រឡា ដែលខុទ្ទកាល័យអគ្គទេសាភិបាលបានកំណត់ឲ្យ។

**ទី៤** តួលេខ ១៨១ ៦០៦ គីឡូម៉ែត្រក្រឡា ដែលអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន បាន បង្ហាញឲ្យឃើញ បន្ទាប់ពីធ្វើការគណនាតាមបណ្តាញកុំព្យូទ័រ លើខ្សែព្រំដែនដែលមាននៅលើផ្ទៃទីខ្នាត ១/៥០ ០០០ របស់សហរដ្ឋអាមេរិក ។ តែ តួលេខនេះ ត្រូវបានកែសម្រួលតាមប្រព័ន្ធព័ត៌មានភូមិសាស្ត្រវិទ្យា Arc-GIS ថ្មី ដែលផ្តល់ឲ្យនូវតួលេខ ២ គឺ៖ ១៨១ ៤៣៦ គីឡូម៉ែត្រក្រឡា តាមផែនទី ខ្នាត ១/២០០ ០០០ (ខ្សែព្រំដែនកម្ពុជា-ថៃ) និង ១៨១ ៣១២ គីឡូ ម៉ែត្រក្រឡា តាមផែនទីខ្នាត

១/៥០ ០០០ DMA (ខ្សែព្រំដែនកម្ពុជា-ថៃ)។

*ឥឡូវនេះ តើយកតួលេខមួយណា ១៨១,៦០៦ គីឡូម៉ែត្រក្រឡា ឬ ១៨១,៤៣៦ គីឡូម៉ែត្រក្រឡា។ បើយើងគន់គួរនៅទីនេះ ទាបបំផុតដីរបស់យើងមានច្រើនជាងរាល់ថ្ងៃ។ ហើយ ១៨១,៣១២ គីឡូម៉ែត្រក្រឡានេះ មិនត្រូវបានកាត់ឲ្យអ្នកណាទាំងអស់ ព្រោះមកពីអ្នកមុនគិតខុសទេ។ ដីខ្មែរនៅតែដីខ្មែរអត់មានថា ខាងភាគីថៃមកសុំកាត់ប៉ុណ្ណោះ ភាគីវៀតណាមសុំមកកាត់ប៉ុណ្ណោះ ភាគីឡាវកាត់ប៉ុណ្ណោះបានទេ ព្រោះមានរបងរួចហើយ។ (ឥឡូវឃើញថា) យើងមានអស់ហើយ ចំណុចគោលថាតើជាមួយវៀតណាមប្រើផែនទីអី ជាមួយឡាវប្រើផែនទីអី ជាមួយថៃ (យើងប្រើ)* MOU *ឆ្នាំ ២០០០ ។*

*ឥឡូវ ជាបណ្តោះអាសន្ន យើងសុំប្រើ ១៨១,០៣៥ គីឡូម៉ែត្រក្រឡាសិន ដោយយើង មិនទាន់មានទិន្នន័យ ហើយសៀវភៅក្មេងរៀនក៏ប៉ុណ្ណឹងដែរ។ សូមអស់លោកកុំព្រួយថា រាជរដ្ឋាភិបាលនឹងយកដីនោះទៅលក់ឲ្យគេ។ ខ្ញុំប្រើពាក្យអស់លោកហ្នឹង មិនមែនសំដៅមនុស្សតែប៉ុន្មាននាក់នៅខាងមុខនេះទេ គឺមានទាំងលោក* **ស៊ាច ម៉េចសេ** *ស្អី។ ផ្សេងទៀតផង។ កន្ទង់ទៅយើងប្រើប្រាស់តួលេខហ្នឹង ព្រោះយើងមិនទាន់អាចប្រើប្រាស់តួលេខផ្សេង។ ប៉ុន្តែយើងក៏មានតួលេខបណ្តោះអាសន្ន ដែល*

*យើងវាស់វែងដោយខ្លួនឯង មិនមែនតាមប្រព័ន្ធមួយភូតកុហកទេ។ ហើយផ្ទៃក្រឡានោះ ក៏មិនទាន់គិតបណ្តាកោះទាំង ៦៤ ដែរ។*

គួរបញ្ជាក់បន្ថែមថា តួលេខផ្ទៃក្រឡាដីដែលបានគណនានេះ គឺមិនបានបូកបញ្ចូលផ្ទៃដីកោះ ដែលស្ថិតនៅក្នុងដែនសមុទ្រ នៃព្រះរាជាណាចក្រកម្ពុជា នោះទេ (**បង្ហាញផែនទី**) ។

ដោយមានតួលេខច្រើនដូច្នេះហើយ ទើបរាជរដ្ឋាភិបាលបានសម្រេចប្រើតួលេខ ១៨១ ០៣៥ គីឡូម៉ែតក្រឡាបន្តទៀតជាបណ្តោះអាសន្នសិន រហូតដល់ការងារកំណត់ព្រំដែនខ័ណ្ឌសីមាជាមួយប្រទេសទាំងបី គឺ ឡាវ – ថៃ – វៀតណាម បានដំណើរការទៅចប់សព្វគ្រប់ ព្រោះនេះគឺជាតួលេខ ដែលយើងបានប្រើប្រាស់ពីដើមរៀងមកដល់បច្ចុប្បន្ន ហើយប្រជាពលរដ្ឋកម្ពុជាក៏បានរៀនសូត្រចេះចាំស្ទាត់មាត់ ហើយដែរ។

មួយវិញទៀតខ្ញុំក៏សូមបញ្ជាក់បន្ថែមផងដែរ អំពីការផលិតផែនទីខ្នាត ១/២៥ ០០០។ ដូចបានបញ្ជាក់ពីខាងលើ បន្ទាប់ពីការងារកំណត់ខណ្ឌសីមា និង ការបោះបង្គោលព្រំដែន បានដំណើរការចប់ កម្ពុជា និង វៀតណាម នឹងរួមគ្នាផលិតផែនទីឋានលេខាព្រំដែនមួយដែលមានខ្នាត ១/២៥ ០០០ ដែលមានបង្ហាញទីតាំងបង្គោលព្រំដែន និងខ្សែខណ្ឌសីមាព្រំដែនរវាងប្រទេសទាំងពីរ។ ក្រុមហ៊ុន BlomInfo A/S នៃប្រទេសដាណឺម៉ាក គឺជាអ្នកដេញថ្លៃបានការងារនេះ ហើយត្រូវទទួលរ៉ាប់រងធ្វើផែនទីនេះក្រោមការត្រួតពិនិត្យរបស់អ្នកបច្ចេកទេសចម្រុះនៃប្រទេសទាំងពីរ។

បន្ថែមលើនេះ ខ្ញុំសូមគូសរំលេចចំណុចមួយទៀត ដែលពាក់ព័ន្ធនឹងអនុស្សារណៈនៃការយោគយល់គ្នា ឆ្នាំ ២០១១។ អនុស្សារណៈនៃការ

យោគយល់គ្នា ស្តីពីការកែសម្រួលខ្សែព្រំដែនគោកនៅតំបន់ដែលនៅសេសសល់មួយចំនួននេះ ត្រូវបានចុះហត្ថលេខានៅថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១១ ក្នុងគោលដៅដោះស្រាយបញ្ហាគាំងស្ទះមួយចំនួន ដើម្បីរក្សាការគ្រប់គ្រងបច្ចុប្បន្នរបស់ប្រជាពលរដ្ឋនៅតាមព្រំដែន សំដៅជំរុញការអភិវឌ្ឍន៍, កាត់បន្ថយភាពក្រីក្រ និង សម្រួលដល់ការរស់នៅ ប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ។ នេះជាការចាំបាច់ណាស់ ពីព្រោះ កិច្ចការមានការគាំងស្ទះជាច្រើនឆ្នាំមកហើយ។ មុនដំបូងភាគីទាំងពីរ គ្រោងបញ្ចប់ការងារនេះ នៅឆ្នាំ ២០០៨។ ក្រោយមក ក៏មានការពន្យារពេលដល់ឆ្នាំ ២០១២។ ឥឡូវនៅសល់ ៥ ខែទៀតប៉ុណ្ណោះ ត្រូវដាច់ឆ្នាំ ២០១២ ហើយ ក៏ប៉ុន្តែ ការគាំងស្ទះនៅតែមិនទាន់ត្រូវបានដោះស្រាយនៅឡើយ មានដូចជា៖

**ទីមួយ** ការធ្វើសវនកម្មខ្សែព្រំដែនលើផែនទីនៅសល់ ៥ ផ្ទាំង។ កិច្ចការនេះ បានដំណើរការជាង ២ឆ្នាំមកហើយ ក៏ប៉ុន្តែ សូម្បីផែនទីមួយផ្ទាំងក៏មិនទាន់ចេញដែរ ដោយភាគីទាំងពីរពុំឯកភាពគ្នាលើការគូសចម្លងខ្សែព្រំដែន។

**ទីពីរ** ពុំទាន់មានការឯកភាពគ្នា ក្នុងការកំណត់ទីតាំងបង្គោលព្រំដែនមួយចំនួននៅលើដីជាក់ស្តែង និង មិនមានការឯកភាពគ្នាលើខ្សែខណ្ឌសីមាព្រំដែន ជាច្រើនកំណាត់។

ប្រការទាំងនេះ សរបញ្ជាក់ឱ្យឃើញ អ្នកបច្ចេកទេសរបស់កម្ពុជាទាំង ៧ ក្រុម ពុំបានធ្វើអ្វីតាមតែអ្នកផ្សេងបង្គាប់ដូចការចោទប្រកាន់របស់មជ្ឈដ្ឋានមួយចំនួននោះទេ។ បើពុំដូច្នោះ កិច្ចការដែលនៅសេសសល់ទាំងអស់នេះ ប្រហែលជាត្រូវបានបញ្ចប់តាំងពីយូរណាស់មកហើយ។

*ខ្ញុំសូមបញ្ជាក់ជូនថា បើធ្វើអាយ៉ងគេ វាមិនពិបាកទេ។ គេឲ្យបោះត្រង់ណាបោះត្រង់ហ្នឹង ទៅវាចប់ហើយ។ ប៉ុន្តែដោយសារចរិតជាម្ចាស់ប្រទេស បានជាកូនខ្មែរត្រូវធ្វើការងារនេះ។ ខ្ញុំគិតថា អស់លោកគួរឲ្យតំលៃប្រជាជនខ្លះផង។ ការផ្តល់ឲ្យគណបក្សប្រជាជន ៩០ អាសនៈ ក្នុងរដ្ឋសភា មិនមែនជាការលេងសើចទេ។ បើអ្នកនៅទល់ដែនគិតថា បាត់ដីនៅទល់ដែនគាត់ច្បាស់ជាមិនបោះឆ្នោតឲ្យគណបក្សប្រជាជនទេ។ បញ្ហាឃុំដា និងឃុំជាំ អាចជាបាតុភាពមួយផ្សេង ដោយបោះឆ្នោតថ្នាក់ឃុំចាញ់ តែបោះឆ្នោតថ្នាក់ជាតិឈ្នះវិញ។ ខ្ញុំកំពុងសិក្សារកមូលហេតុថាតើមកពីអ្វី។ ប៉ុន្តែ ឃុំដទៃទៀតតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម គណបក្សប្រជាជនមិនទាន់ចាញ់ទេ។ បើសិនជាបាត់ដីពិតប្រាកដ គឺអស់លោកជាអ្នកឈ្នះហើយ។ តែប៉ុណ្ណឹងក៏អាចគ្រប់គ្រាន់ហើយ។ សម័យបច្ចុប្បន្ន សូម្បីនៅអាមេរិក គង់គេទូរស័ព្ទសួរបងប្អូនគេ បាត់ដីដូចគេថា ឬអត់។ ដូចយ៉ាង អ្នកនៅកោះធំ ឬក៏តាមជាយដែន បើមានការបាត់ដីដូចគេថា មែននោះ ហេតុម៉េចគេមិនដឹង? តើភូតគេដល់ណាទៀត។*

**<u>សំណួរទី២</u> ការងារបច្ចេកទេសវាស់វែង រកចំណុចបង្គោលព្រំដែន។**

នេះគឺជាលើកទី ៣ ហើយ ដែលឯកឧត្តម **សុន ឆ័យ** លើកសំណួរដដែលនេះមករាជរដ្ឋាភិបាល។ ឯកឧត្តមនៅតែពុំយល់ ឬធ្វើជាពុំយល់

អំពីអ្វីដែលរាជរដ្ឋាភិបាលបាន និង កំពុងធ្វើនោះទេ។ ប្រហែលជាឯកឧត្តមគិតដូចប្រធានរបស់ឯកឧត្តមដែរថា សម្ភារៈវាស់វែងរបស់ក្រុមបច្ចេកទេសព្រំដែន គឺជាល្បែងក្មេងលេងដែលលក់នៅតាមដងវិថី។

ខ្ញុំសូមធ្វើការបញ្ជាក់ជាថ្មីម្តងទៀតថា ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ក្រុមការងារនៃភាគីទាំងសងខាង ប្រើប្រាស់ឧបករណ៍ និង បច្ចេកវិទ្យាទំនើបៗ ដូចមានបង្ហាញជូន ក្នុងរូបភាពនៅលើអេក្រង់នេះ (**បង្ហាញស្លាយដ៍អំពីបញ្ជីឈ្មោះឧបករណ៍ និង រូបភាពនៃឧបករណ៍**) ដើម្បីរកវត្ថុធាតុគោលនៅលើដីជាក់ស្តែង។ គួបផ្សំជាមួយនឹងឧបករណ៍ទាំងនេះ យើងនៅបានប្រើប្រាស់ផែនទីបោន (Bonne) ខ្នាត ១/១០០ ០០០ បោះពុម្ពដោយក្រុមភូមិសាស្ត្រឥណ្ឌូចិន សម្រាប់ជាមូលដ្ឋាននៃការវាស់វែងស្របតាមមាត្រា ២ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ គួបផ្សំនឹងផែនទី UTM ខ្នាត ១/៥០ ០០០ ជាឧបករណ៍ជំនួយក្នុងការចុះវាស់វែងកំណត់ទីតាំងបង្គោលព្រំដែននៅលើដីជាក់ស្តែង ដូចដែលមានចែងក្នុងសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ ២០០៥ ដែលត្រូវបានរដ្ឋសភា និង ព្រឹទ្ធសភាអនុម័ត ហើយព្រះករុណាព្រះមហាក្សត្រ ក៏ទ្រង់បានឡាយព្រះហស្តលេខាលើព្រះរាជក្រមដាក់ឱ្យប្រើច្បាប់នេះ នាខែវិច្ឆិកា ឆ្នាំ ២០០៥ កន្លងទៅ។ បន្ថែមលើនេះទៀត យើងក៏ប្រើប្រាស់ផងដែរ នូវផែនទីបោន (Bonne) ដែលបានមកពីការធ្វើសវនកម្មខ្សែព្រំដែនឆ្នាំ ១៩៨៥ ដោយគូសចម្លងពីផែនទីបោន (Bonne) ខ្នាត ១/១០០ ០០០ មកលើផែនទី UTM ខ្នាត ១/៥០ ០០០ ដែលសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ ២០០៥ អនុញ្ញាតឱ្យប្រើ។

សរុបសេចក្តីមក ការលើកឡើងថា កម្ពុជាខ្វះខាតបច្ចេកទេស និងឧបករណ៍វាស់វែង និង ខ្វះខាតធនធានមនុស្សសម្រាប់បំពេញការងារនោះ គឺមិនត្រឹមត្រូវទេ។ ដូចបានបញ្ជាក់ខាងលើ យើងមានធនធានមនុស្ស និង

ឧបករណ៍ទំនើប រួមទាំងមធ្យោបាយដឹកជញ្ជូនគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់ក្នុងការបំពេញបេសកកម្មព្រំដែននេះ ឱ្យបានប្រកបដោយប្រសិទ្ធភាព ជាមួយនិងប្រទេសជិតខាងទាំងបី។

ជាការពិត មន្ត្រីដឹកនាំ និង អ្នកបច្ចេកទេសរបស់យើងឆ្លងកាត់នូវការលំបាករាប់មិនអស់ទេ នៅក្នុងការខិតខំបំពេញភារកិច្ចជាប្រវត្តិសាស្ត្រជូនជាតិមាតុភូមិនៃយើង។ យើងបានបាត់បង់វីរជននៃការងារព្រំដែនរបស់យើង ២ នាក់ដែលបានបូជាជីវិត និង មួយចំនួនទៀតត្រូវរងរបួសពិការមួយជីវិត ដើម្បីបុព្វហេតុជាតិដ៏មានសារសំខាន់នេះ។ ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ក្រុមបច្ចេកទេសរបស់យើងត្រូវចូលលុកក្នុងព្រៃ ដែលមានសម្បូរទៅដោយគ្រាប់មីនបង្កប់តាំងពីសម័យសង្គ្រាមស៊ីវិលមក ជាកន្លែងដែលប្រឈមនឹងជំងឺគ្រុនចាញ់ សត្វសាហាវ គ្មានផ្លូវគមនាគមន៍ទៅដល់ ហើយត្រូវសម្រាកនៅតំបន់ដាច់ស្រយាលដែលខ្វះកន្លែងបោះជំរុំ គ្មានទឹកស្អាតប្រើប្រាស់ប្រចាំថ្ងៃ ខ្វះអនាម័យ ។ល។និង។ល។

វីរភាពទាំងអស់នេះ គួរតែត្រូវបានមើលឃើញ និង ផ្តល់តម្លៃគោរពកោតសរសើ។ ក៏ប៉ុន្តែ ផ្ទុយទៅវិញ កិច្ចការមួយចំនួនដែលសម្រេចបានមកដោយលំបាកលំបិននេះ បែរជាត្រូវប្រឈមនឹងការបាត់បង់ ដោយសារមហិច្ឆតានយោបាយរបស់ក្រុមជនមួយចំនួនតូចទៅវិញ។ អាស្រ័យហេតុនេះ ខ្ញុំសូមឆ្លៀតយកឱកាសនេះ តាងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា សំដែងនូវការដឹងគុណ និង ការកោតសរសើរដោយស្មោះ ជូនចំពោះក្រុមការងារបច្ចេកទេស និង មន្ត្រីគ្រប់ជាន់ថ្នាក់ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន នៅក្រោមការដឹកនាំរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** និង ឯកឧត្តមទេសរដ្ឋមន្ត្រី **វ៉ា គឹមហុង** ដែលបានបូជានូវកម្លាំងកាយប្រាជ្ញា និងស្មារតីរបស់ខ្លួន ដើម្បីបុព្វហេតុនៃកិច្ចការព្រំដែនដ៏មានសារៈ

សំខាន់សម្រាប់ប្រទេសជាតិនេះ។

**<u>សំណួរទី ៣</u> ការបាត់បង់ភូមិខ្មែរតាមបណ្តោយព្រំដែន ជាពិសេសភូមិថ្លុកត្រាច និង ភូមិអន្លង់ជ្រៃ (បង្ហាញផែនទី )។**

*ឥឡូវបញ្ហានៅត្រង់អី? យើងសាកល្បងដើម្បីធ្វើការពន្យល់ពីបញ្ហានេះ។ បញ្ហារបស់យើងស្ថិតនៅត្រង់ បញ្ហាបារាំងគូរផែនទី ដោយមិនបានគិតថាកាត់ភូមិណាអីភូមិណាទេ។ កុំថាឡើយដល់ទៅព្រំដែន សូម្បីតែ (ការកំណត់ព្រំ)ដីសម្បទានសេដ្ឋកិច្ច ក៏ជាន់លើដីប្រជាជន ដែលឥឡូវរាជរដ្ឋាភិបាលត្រូវតែឲ្យមានការចុះវាស់វែង។ បារាំងគូរដោយបារាំងទៅ (បន្សល់ទុកនូវទំនាស់រវាង) ភូមិវៀតណាម និងភូមិខ្មែរ។ តើយើងត្រូវដោះស្រាយយ៉ាងម៉េច។ មានវិធីបី ដែលត្រូវដោះស្រាយ៖*

***វិធីទី ១*** *យកតាមផែនទីទាំងស្រុងដោយគ្មានការកែប្រែ ហើយកាត់ដី និងភូមិខ្មែរណាដែលផែនទីវត់កាត់ថាជាដីរបស់វៀតណាម ឲ្យចូលទៅក្នុងដីវៀតណាមទៅ ហើយកាត់ដី និងភូមិវៀតណាមណា ដែលខ្សែផែនទីវត់កាត់ថាជាដីរបស់កម្ពុជា ឲ្យទៅក្នុងដីរបស់កម្ពុជា ប្រៀបដូចជាការដូរជាតិសាសន៍ ហើយខ្មែរក្លាយទៅជាវៀតណាម វៀតណាមក្លាយទៅជាខ្មែរ។ តែជម្រើសនេះមិនអាចធ្វើទៅកើតទេ។*

***វិធីទី ២*** *រើភូមិចេញតែម្តង។ យើងអត់សំអាងលើអីក្រៅពី*

*ផែនទីទេ ហើយក៏មិនអាចបង្អុលៗ បានដែរ។ បើសិនជាផែនទីវត់ទៅចំភូមិហ្នឹងជាភូមិខ្មែរ តែនៅក្នុងដីវៀតណាម ផ្អែកលើផែនទីត្រូវរើភូមិហ្នឹងចូលមកដីខ្មែរ ហើយ(ក្នុងករណីដូចគ្នាចំពោះវៀតណាម) ត្រូវរើភូមិវៀតណាម ចេញទៅដីវៀតណាមវិញ។ ជម្រើសនេះក៏ទៅមិនរួច។*

***វិធីទី ៣*** *រក្សាស្ថានភាពដដែល តាមការកាន់កាប់របស់ប្រជាជន តាមរយៈការដោះដូរ ដូចមានចែងក្នុងអនុស្សារណៈ ស្តីពី ការយោគយល់គ្នា ថ្ងៃ ទី ២៣ ខែ មេសា ឆ្នាំ ២០១១។*

យោងតាមផែនទីតម្កល់នៅអង្គការសហប្រជាជាតិ ខ្នាត ១/១០០ 000 របស់ក្រុមភូមិសាស្រ្តឥណ្ឌូចិន មួយផ្នែកធំនៃភូមិនេះ ស្ថិតនៅក្នុងទឹកដីខ្មែរ ក្រោមឈ្មោះថា ភូមិអន្លង់ក្រេះ និងមួយផ្នែកតូចនៃភូមិនេះ ស្ថិតនៅក្នុងទឹកដីវៀតណាម។

ដូចខ្ញុំបានជម្រាបពីខាងលើរួចមកហើយ ក្នុងគោលដៅនៃការស្វះស្វែងរកដំណោះស្រាយលើបញ្ហាមួយចំនួន ដែលនៅគាំងស្ទះមិនទាន់អាចដោះស្រាយបាន រដ្ឋាភិបាលនៃប្រទេសទាំងពីរបានឯកភាពគ្នាធ្វើអនុស្សារណៈនៃការយោគយល់គ្នាមួយ ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១១ ស្តីពីការកែសម្រួលខ្សែព្រំដែនគោកនៅតំបន់ដែលនៅសេសសល់មួយចំនួន។ កិច្ចការនេះ ត្រូវបានធ្វើឡើង ដើម្បីគោលដៅបន្តរក្សាការគ្រប់គ្រងកាន់កាប់ភូមិករ និង ដីធ្លីស្រែចំការរបស់ប្រជាពលរដ្ឋ ដែលបានតាំងទីលំនៅ និង ធ្វើការបង្កបង្កើនផលជាយូរឆ្នាំមកហើយឱ្យបានបន្តរស់នៅ និង បន្តកាន់កាប់ដីធ្លីទាំងនោះដដែល។ នៅក្នុងក្របខ័ណ្ឌនៃការងារ

នេះ ក្រុមជំនាញចម្រុះនឹងត្រូវចុះសិក្សាលម្អិត មុននឹងធ្វើការដោះដូរគ្នា **«ស្មើទៅ-ស្មើមក»** ទៅតាមលក្ខណៈភូមិសាស្ត្រ និង ស្ថានភាពដី ដោយយកខ្សែគូសចម្លងពីផែនទីបោន (Bonne) ខ្នាត ១/១០០ ០០០ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន មកលើផែនទី UTM ធ្វើជាមូលដ្ឋាន ស្របតាមការអនុញ្ញាតនៃសន្ធិសញ្ញាបំពេញបន្ថែម។ គោលការណ៍សំខាន់នៅទីនេះ គឺធានាឱ្យបានដាច់ខាតថាកម្ពុជានឹងមិនខាត ឬបាត់បង់ដីឡើយ សូម្បីតែ ១ ម៉ែត្រក្រឡាក៏ដោយ។

ទោះជាមានគម្រោងធ្វើការដោះដូរដូច្នេះមែនក្តី តែយើងនៅរក្សាផ្ទៃដីសរុបឱ្យនៅដដែល ព្រោះវាជាការដោះដូរ **«ស្មើទៅ-ស្មើមក»** ពោលគឺ បើ ១ ហិកតាទៅ គឺត្រូវបាន ១ ហិកតាមកវិញ នៅក្នុងខេត្តជាមួយគ្នា លើកលែងតែករណីក្នុងខេត្តនោះពុំមានដីដោះដូរ ទើបអនុញ្ញាតឱ្យឆ្លងទៅដូរជាមួយនិងខេត្តមួយផ្សេងទៀតបាន ដើម្បីធ្វើការទូរទាត់សងគ្នាឱ្យបានស្មើ និង គ្រប់ចំនួន។ ការធ្វើដូច្នេះ គ្មានអ្វីផ្ទុយនឹងច្បាប់ជាតិ ក៏ដូចជាច្បាប់អន្តរជាតិ ដូចមតិមួយចំនួនធ្វើការចោទប្រកាន់នោះទេ ព្រោះថា នេះ គឺជាមរតកប្រវត្តិសាស្ត្រដែលអាណានិគមបន្សល់ទុកឱ្យ ហើយវាសមស្របទៅនឹងគោលការណ៍នៃការសម្រុះសម្រួលគ្នា ដែលត្រូវបានអនុវត្តជាអន្តរជាតិ និងត្រូវបានលើកទឹកចិត្តឱ្យអនុវត្ត ដោយអង្គការសហប្រជាជាតិ និង តុលាការយុត្តិធម៌អន្តរជាតិក្រុងឡាអេផងដែរ។

រហូតមកដល់ពេលនេះ ខ្ញុំសូមបញ្ជាក់ថា ពុំមានភូមិខ្មែរណាមួយត្រូវបានបាត់បង់នោះទេ។ ម៉្យាងវិញទៀត ដូចបានបញ្ជាក់អម្បាញ់មិញ ករណីដោះដូរនេះ ពុំមែនមានតែនៅកម្ពុជា និង វៀតណាមនោះទេ។ វៀតណាម និង ឡាវ, វៀតណាម និង ចិន ក៏បានអនុវត្តតាមវិធីសាស្ត្រនេះដែរ។ ឧទាហរណ៍ បែបនេះមានច្រើនណាស់នៅតាមតំបន់ និង ទ្វីបផ្សេងទៀត រួម

មានដូចជា បារាំង និង ប៉ែលហ្ស៊ិក ដែលបានបន្តដោះដូរជាមួយគ្នា ខណៈដែលប្រទេសទាំងពីរ បានទទួលស្គាល់ព្រំដែនគ្នាតាំងពីឆ្នាំ ១៨៣០។ ប៉ែលហ្ស៊ិក និងហូឡង់ ក៏បានធ្វើការដោះដូរដីដូចគ្នាដែរ។ គេធ្វើនេះ គឺដើម្បីសម្របសម្រួលទៅនឹងការកាន់កាប់ជាក់ស្តែងនៅលើដែនដី និងដើម្បីងាយស្រួលធ្វើការគ្រប់គ្រងលើទ្រព្យសម្បត្តិផង ព្រមទាំងសម្រួលជីវភាពរស់នៅរបស់ប្រជាពលរដ្ឋផង។ ប្រទេសឆេក និងស្លូវ៉ាកក៏បានដោះដូរភូមិ និងដីជាមួយគ្នាដែរ ក្រោយពីប្រទេសទាំងពីរនេះបានបែកគ្នាចេញពីប្រទេសឆេកូស្លូវ៉ាគី។

បច្ចុប្បន្ន ភូមិទាំងពីរ ត្រូវបានភាគីទាំងពីរ ឯកភាពឲ្យក្រុម បច្ចេកទេសចម្រុះ ចុះទៅធ្វើការវាស់វែងដើម្បីគណនារកផ្ទៃក្រឡាដីចេញ-ចូលពិតប្រាកដ រួចហើយទុកធ្វើការទូទាត់ឲ្យគ្នាទៅវិញទៅមកនៅពេលក្រោយតាមគោលការណ៍ដូចបានបញ្ជាក់ខាងលើ។ បន្ថែមលើនេះ ខ្ញុំសូមបញ្ជាក់ថា ភូមិអន្លង់ជ្រៃនេះពុំមាននៅក្នុងផែនទីមណ្ឌលរដ្ឋបាល កូសាំងស៊ីនឆ្នាំ ១៨៧៣ ដូចការអះអាងពីអ្នកជំនាញឯនាយសមុទ្រនោះទេ (**បង្ហាញផែនទីមណ្ឌលរដ្ឋបាលកូសាំងស៊ីន ឆ្នាំ ១៨៧៣**)។

ដោយឡែក ពាក់ព័ន្ធនឹងវឌ្ឍនភាពនៃការងារវាស់វែងផ្ទៃដីចេញ-ចូលសម្រាប់ការដោះដូរគ្នានេះ ខ្ញុំសូមជម្រាបជូនថា ជារួមក្រុមការងារបច្ចេកទេស បានធ្វើការវាស់វែងផ្ទៃដីចេញ-ចូលគ្នាទៅវិញទៅមកនេះនៅគ្រប់ខេត្តទាំង ១០ រួចហើយ ដែលក្នុងនោះនៅខេត្តភាគច្រើនខាងកម្ពុជាបានធ្វើការវាស់វែងជាឯកតោភាគី ដោយមិនទាន់មានការទទួលស្គាល់ជាទ្វេភាគីនៅឡើយ លើកលែងតែខេត្តកំពង់ចាម កំពត និងតាកែវ ដែលក្រុមបច្ចេកទេសចម្រុះ បានចុះហត្ថលេខាទទួលយកជាទ្វេភាគីហើយ ប៉ុន្តែប្រធានគណៈកម្មការចម្រុះព្រំដែននៃប្រទេសទាំងពីរ មិនទាន់បាន

អនុម័តទទួលយកកំណត់ហេតុនេះនៅឡើយ។ សរុបការវាស់វែងផ្ទៃដីចេញ-ចូលគ្នាទូទាំងខ្សែព្រំដែនរវាងកម្ពុជា-វៀតណាម, ទាំងតួលេខដែលបានឯកភាពគ្នា ទាំងតួលេខដែលមិនទាន់បានឯកភាពគ្នា, ឃើញថាកម្ពុជាគ្រប់គ្រងចូលដីវៀតណាម មានចំនួនប្រមាណជា ៩១៦,៧ ហិកតា, រីឯវៀតណាមគ្រប់គ្រងចូលដីកម្ពុជា មានចំនួនប្រមាណ ២១៦០,៦ ហិកតា។ ទៅថ្ងៃអនាគត បើតួលេខនេះត្រូវបានទទួលស្គាល់ដោយភាគីទាំងសងខាង ជាតួលេខផ្លូវការ នោះវៀតណាមត្រូវរកដីសងឲ្យកម្ពុជាប្រមាណ ១២៤៣,៩ ហិកតា ដែលនេះគឺជាដំណោះស្រាយតាម MOU ឆ្នាំ ២០១១ (**បង្ហាញផែនទី ៤ ខេត្ត** )។

*ដូច្នេះ រឿងកើតមាននៅឃុំ ចន្ទមូល នៅ បឹងជ្រោង ជាដើម វង់ចាំតែការដោះដូរទេ។ យើងនឹងមិនអោយបងប្អូនយើងបាត់បង់ដីទេ សូមកុំព្រួយ។ សំរាប់ខេត្តស្វាយរៀង ការវាស់វែង(បានធ្វើជា)ឯកតោភាគី ឯខេត្តកំពង់ចាម បានឯកភាពគ្នាហើយៗ មានទាំងទីតាំងភូមិរួចហើយដែរ នៅចាំតែការដោះដូរទេ។ ផ្អែកលើគោលការណ៍នេះ ផែនទីព្រំដែននឹងមានសភាពដូចធ្មេញរណាអញ្ចឹង ដោយសារតែត្រូវធ្មៀល ដើម្បីរក្សាការកាន់កាប់របស់ប្រជាជនទាំងសងខាង។ មានតែវិធីហ្នឹងទេ ដែលល្អនោះ។*

*បើតាមខ្សែព្រំដែនវៀតណាម ឲ្យទៅវៀតណាមក៏អត់បាន កាត់ភូមិវៀតណាមក៏អត់បាន ឲ្យរើភូមិក៏វាមិនបាន ដូច្នេះ វិធីតែមួយដែលល្អជាងគេ គឺសម្រួលខ្សែព្រំដែនតាមការកាន់កាប់ជាក់ស្តែងរបស់ប្រជាជនវិញ ដោយហេតុថា ផ្ទះដូនតាទាំងខាង*

*កម្ពុជាទាំងខាងវៀតណាម រក្សានៅហ្នឹងកន្លែងទាំងអស់គ្នា។ យើងសុខចិត្តដូរខ្សែផែនទី ហើយមិនមានអ្វីខាតបង់ទេ ទំហំដីនៅដដែល។ ដោយឡែកនៅខេត្តស្វាយរៀង កម្ពុជាចូលទៅវៀតណាម យើងរាស់ជាឯកតោភាគីទេ ២៨៩ ហិកតា ឯវៀតណាមចូលមកកម្ពុជា ១១០០ ហិកតា។ ឃើញថា ពីរខេត្តនេះ យើងមិនចាំបាច់ត្រូវរកដីសងវៀតណាមទេ តែវៀតណាមត្រូវរកដីសងយើងវិញ។*

*នៅខេត្ត ព្រៃវែង យើងបានវាស់ជាឯកតោភាគីហើយដោយកម្ពុជាចូលទៅវៀតណាម ៥៤ ហិកតា ឯវៀតណាម ចូលមកកម្ពុជា ៣០,៩ ហិកតា។ ករណីនេះ យើងជំពាក់វៀតណាមវិញ។ នៅខេត្តតាកែវ កម្ពុជាចូលទៅវៀតណាម ១៥៩,១ ហិកតា ហើយវៀតណាមចូលមកកម្ពុជា ១៥១,៧ ហិចតា។ ហ្នឹងយើងជំពាក់វៀតណាមទៀត។ ខេត្តកំពត កម្ពុជាចូលទៅវៀតណាម ២៩,១ ហិកតា ហើយវៀតណាមចូលមកកម្ពុជា ៥៣ ហិកតា។ ករណីនេះ វៀតណាមជំពាក់យើង។*

*ជាគោលការណ៍ អនុញ្ញាតឲ្យខេត្ត និងខេត្តធ្វើការដោះដូរគ្នាមុន។ បើខ្វះទើបអនុញ្ញាតឲ្យទៅខេត្តផ្សេង។ កម្ពុជាចូលទៅវៀតណាមសរុប ៩១៦,៧ ហិកតា ឯវៀតណាមចូលមកកម្ពុជា ២១៦០,៦ ហិកតា។ ដូចនេះ វៀតណាមត្រូវសងមកកម្ពុជាវិញ*

*១២២៣,៩ ហិកតា។ ទាំងនេះសុទ្ធតែកំពុងស្ថិតក្នុងដំណាក់កាលនៃការចរចា ឯខេត្តដែលបានឯកភាពគ្នាហើយមានកំពង់ចាម តាកែវ កំពត ហើយខេត្តដែលយើងបានវាស់ជាឯកតោភាគីមាន ស្វាយរៀង និងព្រៃវែង។*

*បើយោងទៅលើផែនទីនេះ តាមការកាន់កាប់ជាក់ស្តែង ដោយប្រជាជន វៀតណាមនៅជំពាក់ដីខាងកម្ពុជា ហើយការដោះដូរត្រូវធ្វើតាមគោលការណ៍មួយទៅមួយមក។ នាយករដ្ឋមន្ត្រី (នៃប្រទេសទាំងពីរ) នឹងត្រូវធ្វើការអនុម័ត នៅពេលដែលគណៈកម្មការធ្វើការវាស់វែងរួច។ ដោយឡែក ភូមិសម្តេច* **ហោះ សំរិន** *ធ្វើបានលឿនជាងគេ។ តាមពិតទៅ មិនទាន់បានដោះដូរផង គាត់យកត្រាក់ទ័រទៅធ្វើប្រឡាយទឹកបាត់ទៅហើយ។*

*ខ្ញុំអរគុណណាស់ ជាពិសេស អ្នកតំណាងរាស្ត្រនៃម្ចាស់សំណួរ ដែលបានប្រឹងប្រែងអត្ថយស្តាប់ ទោះបីវាជូរវាចត់យ៉ាងណាក្តី។ សូមកោតសរសើរ ចំពោះភាពក្លាហាន ហើយបើយើងសហការគ្នាលើកនេះបាន ថ្ងៃក្រោយយើងអាចជិះកប៉ាល់ទៅជាមួយគ្នាមើលកោះមួយចំនួន ដោយមិនចោទគ្នាថាក្បត់ជាតិលក់ដីឲ្យគេ។ យើងអាចមានមោទនភាពជាមួយគ្នា ក្នុងឋានៈជាជនរួមជាតិតែមួយ រីឯការចោទប្រកាន់គ្នាថាក្បត់ជាតិ ឬអាយ៉ងអ្នកនេះអ្នកនោះ វាជាការកាត់សាច់ឯងឲ្យគេតែប៉ុណ្ណោះ។*

*ខ្ញុំអរគុណឯកឧត្តមលោកជំទាវ ដែលបានអង្គុយស្តាប់នូវរឿងដែល ខ្ញុំជាប់ជំពាក់ត្រូវតែនិយាយ ព្រោះឯកឧត្តម លោកជំទាវបានបង្ខំឲ្យនិយាយ។ សូមកុំទៅបោកប្រាស់គេទៀត។ គ្មានអ្វីដែលច្បាស់ជាងកន្លែងនេះទៀតទេ។ ការស្រែកថាបាត់ត្រង់ណេះ បាត់ត្រង់ណោះ អត់បានការអីទេ។ ហើយបើចាំបាច់ (ថាមានការបកស្រាយមិនច្បាស់ត្រង់ណា) ទូរទស្សន៍ក៏ចាក់ផ្សាយត្រង់ចំណុចនោះ ទៅតាមប្រធានបទ។ សូមអរគុណចំពោះ (ការតាមដានស្តាប់ និងទស្សនារបស់) ព្រះសង្ឃ និងប្រជាពលរដ្ឋរាប់លាននាក់នៅទូទាំងប្រទេស។*

**<u>សំណួរទី ៤</u> បង្គោលព្រំដែនលេខ ៣១៤ និងការធានាបូរណភាពទឹកដីកម្ពុជា។**

រហូតមកដល់ពេលនេះ យើងបានបោះបង្គោលព្រំដែនសម្រេចបានចំនួន ២៣៦ ទីតាំង លើចំនួនទីតាំងសរុប ៣១៤។ គិតជាចំនួនបង្គោលសរុប គឺសម្រេចបានចំនួន ២៨៥ លើ ៣៧៥ បង្គោល (ទោល ភ្លោះ ត្រី) ដែលត្រូវជា ៧៦% នៃចំនួនបង្គោលសរុប។ ក្នុងនេះ ទីតាំងដែលបានសាងសង់រួចមានចំនួន ២០៨ លើ ៣១៤។ គិតជាបង្គោល គឺស្មើនឹង ២៥២ លើ ៣៧៥ បង្គោល។ ការងារខណ្ឌសីមាព្រំដែនសម្រេចប្រវែង ៧០០ គីឡូម៉ែត្រ នៃខ្សែព្រំដែនសរុប ដែលមានប្រវែងប្រមាណជា ១ ២៧០គីឡូម៉ែត្រ ពោលគឺស្មើនឹង ៥៨% នៃខ្សែព្រំដែនទាំងមូល។

ខ្ញុំសូមបញ្ជាក់ជូនថា បង្គោលព្រំដែនលេខ ៣១៤ គឺជាបង្គោលចុងក្រោយបំផុត នៃខ្សែព្រំដែនគោករវាងប្រទេសទាំងពីរ កម្ពុជា-វៀតណាម។

ចំពោះមុខ កម្ពុជាមានគោលដៅបន្ត ឆ្ពោះទៅកំណត់ព្រំដែនសមុទ្រនៅក្នុងឈូងសមុទ្រសៀមបន្ថែមទៀត ដោយចាប់ផ្តើមចេញ ពីបង្គោល ៣១៤ នេះទៅ។ បង្គោលនេះមានសារៈសំខាន់ណាស់ ទោះបីជាក្នុងរូបភាពនៃជំរើសខ្សែព្រំដែនណាមួយក៏ដោយ ពោលគឺទាំងជម្រើសប្រើខ្សែប្រេវីយ៉េ ឆ្នាំ ១៩៣៩ ទាំងជំរើសប្រើខ្សែសមចម្ងាយ ពីព្រោះថា ភាគីទាំងពីរចាំបាច់ត្រូវធ្វើការចរចាគ្នាដោយផ្តើមចេញពីចំណុចដីគោកនេះ ដើម្បីកំណត់ខ្សែព្រំដែនសមុទ្ររវាងប្រទេសទាំងពីរ។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមលើកឡើងនូវជំហរដ៏ត្រឹមត្រូវ និងភ្លឺស្វាងមួយរបស់ ព្រះករុណាសម្តេចព្រះ **នរោត្តម សីហនុ** ដែលព្រះអង្គបានបញ្ជាក់នៅក្នុងព្រះរាជសារចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ១៩៩៩ ថា «*ក្នុងប្រវត្តិសាស្ត្រកម្ពុជា ទឹកដីកម្ពុជាក្រោមទាំងមូលបានបាត់បង់រួចទៅហើយ។ បន្ទាប់មកកោះត្រល់ដែលវៀតណាមឲ្យឈ្មោះថា ហ្វ៊ូកុក នោះ និងកោះមួយចំនួនដែលស្ថិតនៅខាងត្បូងខ្សែបន្ទាត់ប្រេវីយ៉េ ក៏បន្តបាត់ទៀត ដោយសារសោរាចររបស់លោកអគ្គទេសាភិបាលបារាំង ថ្ងៃទី ៣១ ខែមករា ឆ្នាំ ១៩៣៩។ ម្យ៉ាងវិញទៀតកាលពីឆ្នាំ ១៩៦៤ រាជរដ្ឋាភិបាលកម្ពុជាពេលនោះបានយកផែនទី ១ ដែលបោះពុម្ពដោយក្រុមភូមិសាស្ត្រកម្ពុជាផ្អែកតាមផែនទីបារាំង Service Hydro-graphique ខ្នាត ១/៣០០ ០០០ ភ្ជាប់ជាមួយផែនទីដីគោក ទៅឲ្យអន្តរជាតិទទួលស្គាល់ និងបានតម្កល់ទុកនៅអង្គការសហប្រជាជាតិ នោះគឺយើងបានគូសខ្សែប្រេវីយ៉េជាព្រំដែនសមុទ្រជាមួយវៀតណាមផងដែរ។ ផែនទី និងឯកសារទាំងអស់នេះហើយ ដែលអតីតរាជរដ្ឋាភិបាលរបស់ខ្ញុំ អតីតរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា រដ្ឋកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្នកំណត់ថា ជាព្រំដែនបច្ចុប្បន្នរបស់កម្ពុជា។ ដូចនេះហើយ ខ្ញុំយល់ឃើញថា សម័យកាលបច្ចុប្បន្ននេះ ដែលសកលលោកទាំងមូលកំពុងស្វែងរកការសម្របសម្រួល*

*អំពីព្រំដែន យើងគួរយកខ្សែប្រេវីយ៉េនេះ ដើម្បីខណ្ឌព្រំសីមាដែនសមុទ្ររបស់ប្រទេសយើងទាំងពីរ ដើម្បីទុកឲ្យកូនចៅយើងជំនាន់ក្រោយ ទទួលបាននូវមរតកមួយដ៏ច្បាស់លាស់សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍប្រទេសរៀងៗ ខ្លួន»។*

បង្គោលព្រំដែនដែលភាគីទាំងពីរកម្ពុជា-វៀតណាម បាននឹងកំពុងធ្វើនេះមិនត្រឹមតែជាកិច្ចការរួម ធ្វើឡើងដើម្បីសម្គាល់ការខណ្ឌចែកទឹកដីរវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម ប៉ុណ្ណោះទេ ប៉ុន្តែវាជាចំណែកមួយយ៉ាងសំខាន់ដែលនឹងផ្តល់ជាវិភាគទានមិនអាចកាត់ថ្លៃបាន ដល់កិច្ចការពារបូរណភាពដែនដី នៃព្រះរាជាណាចក្រកម្ពុជាឲ្យកាន់តែមានភាពរឹងមាំ និងរួមចំណែកដល់ការធានាសុខសន្តិភាព, ការជំរុញលើកស្ទួយកំណើនសេដ្ឋកិច្ច, ការអភិវឌ្ឍន៍សង្គម, ការលើកកម្ពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនទៀតផង។

*សម្តេចចក្រី ប្រធានរដ្ឋសភា*
*ឯកឧត្តម លោកជំទាវ លោក លោកស្រី*

នៅចុងបញ្ចប់នេះ ខ្ញុំសូមគូសបញ្ជាក់ជាថ្មីម្តងទៀតអំពីការប្តេជ្ញាដ៏មោះមុតឥតងាករេរបស់រាជរដ្ឋាភិបាល ក្នុងការពុះពារជំនះគ្រប់ឧបស័គ្គ ដើម្បីបន្តដំណើរឆ្ពោះទៅសម្រេចឲ្យខាងតែបាន នូវគោលដៅជាយុទ្ធសាស្ត្ររបស់ខ្លួន ក្នុងការកសាងខ្សែបន្ទាត់ព្រំដែនកម្ពុជាមួយដែលមានភាពច្បាស់លាស់ត្រឹមត្រូវ, ជាព្រំដែនសន្តិភាព, មិត្តភាព, សហប្រតិបត្តិការ និងការអភិវឌ្ឍន៍ ដើម្បីឧត្តមប្រយោជន៍របស់ប្រទេសជាតិ និងប្រជាជនកម្ពុជាគ្រប់ស្រទាប់ជាន់ថ្នាក់។

ជាមួយគ្នានេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំក៏សូមសម្តែងនូវការ

ដឹងគុណដ៏ជ្រាលជ្រៅផងដែរ ជូនចំពោះអង្គរដ្ឋសភាដ៏ឧត្តុងឧត្តម ដែលជានិច្ចកាលតែងផ្តល់នូវការគាំទ្រដ៏មាន តម្លៃចំពោះគោលនយោបាយ និងរាល់សកម្មភាពរបស់រាជរដ្ឋាភិបាល។ ខ្ញុំសូមសម្តែងអំណរគុណជាពិសេសចំពោះសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងអង្គរដ្ឋសភាទាំងមូល ដែលបានអនុញ្ញាតឲ្យរូបខ្ញុំ ដឹកនាំសហការីមកផ្តល់ការបំភ្លឺជូនដល់អង្គរដ្ឋសភា និងតាមរយៈអង្គរដ្ឋសភាដ៏ឧត្តុងឧត្តមនេះ ជូនដល់ប្រជាជនកម្ពុជាទាំងមូល លើប្រធានបទដ៏មានសារសំខាន់ ស្តីពីការងារបោះបង្គោលព្រំដែន រវាង ព្រះរាជាណាចក្រកម្ពុជា និងសធារណរដ្ឋសង្គមនិយមវៀតណាម។

ខ្ញុំសូមប្រសិទ្ធពរជ័យបវរមហាប្រសើរ ជូនសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសមាជិក-សមាជិការទាំងអស់នៃអង្គរដ្ឋសភា សូមបានប្រកបដោយសុខភាពល្អបរិបូណ៌ និងសម្រេចបានជោគជ័យត្រចះត្រចង់ក្នុងគ្រប់ភារកិច្ច ដើម្បីបុព្វហេតុជាតិ និងប្រជាជន។

<u>សូមអគុណ</u>

# ឧបសម្ព័ន្ធ ១/១៖ លិខិតក្លែងបន្លំ ចុះថ្ងៃ ៤ សីហា ឆ្នាំ ២០១២ ធ្វើជាលិខិតរបស់ សម្តេចតេជោនាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**សូមគោរពជូន**

**ជនរួមជាតិកម្ពុជាទាំងអស់**

**កម្មវត្ថុ៖** ករណីយបញ្ហាព្រំដែនដែលគណបក្ស សម រង្ស៊ី បានស្នើសុំឲ្យថ្នាក់ដឹកនាំរាជរដ្ឋាភិបាលឆ្លើយបំភ្លឺទាក់ទងនឹងការកាត់ភូមិឲ្យប្រទេសវៀតណាម និងការបោះបង្គោលព្រំដែនលេខ៣១៨។

**យោង ៖** លិខិតលេខ៩១០ស.ស ចុះថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ២០១២ របស់រដ្ឋសភា និង ការសន្យារបស់ខ្ញុំ ហ៊ុន សែន ប្រមុខរាជរដ្ឋាភិបាលក្នុងការឡើងមកបំភ្លឺបញ្ហាព្រំដែនកាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០១២។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ជម្រាបជូនជនរួមជាតិជាទីគោរពថាការសន្យារបស់ខ្ញុំក្នុងការឡើងមកបកស្រាយបំភ្លឺបញ្ហាព្រំដែននៅរដ្ឋសភានៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០១២ ខាងមុខនេះនឹងត្រូវបានប្រព្រឹត្តទៅតាមកាលបរិច្ឆេទដោយគ្រាន់តែមាន កែប្រែក្នុងនីតិវិធីឆ្លើយតបតែប៉ុណ្ណោះ។ ពោលគឺបញ្ហានេះនឹងមិនត្រូវបាន បើកឲ្យសួរដេញដោលជាចំហរទេដោយខ្ញុំគ្រាន់តែមកអានរបាយការណ៍ជូនតែប៉ុណ្ណោះ។ លើសពីនេះទៅទៀតគឺបកស្រាយត្រឹមតែ ក្រោយពីការគ្រប់គ្រងឆ្នាំ១៩៩៣ទេ។ ការណ៍ធ្វើបែបនេះ ដោយសារតែខ្ញុំបានទទួលការណែនាំ ដ៏ខ្ពង់ខ្ពស់ពីឯកឧត្តម **ង្វៀន តាន់យុង** នាយករដ្ឋមន្ត្រីប្រទេសវៀតណាមជាមិត្តថាបញ្ហាព្រំដែនគឺរាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលវៀតណាមបានព្រមព្រៀងគ្នារួចអស់ហើយ ដូចបានចែងនៅក្នុងស្មារតីនៃសន្ធិសញ្ញាទឹកប្រវត្តិសាស្ត្រ ឆ្នាំ ១៩៨២ និងសន្ធិសញ្ញាបំពេញបន្ថែម ឆ្នាំ ២០០៥។ ដូច្នេះបញ្ហានេះគ្មានអ្វីត្រូវចោទសួរទៀតទេ។

សេចក្តីដូចបានជំរាបជូនខាងលើសូមជនរួមជាតិជាទីគោរពទាំងអស់មេត្តាជ្រាបជាដំណឹងនិង សូមរង់ចាំតែស្តាប់ការអានរបាយការណ៍របស់ខ្ញុំដែលនឹងត្រូវជម្រាបជូនតាមការគួរ។

សូមជនរួមជាតិជាទីគោរពទាំងអស់ មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែសីហា ឆ្នាំ ២០១២*

**ហ៊ុន សែន**

**ចម្លងជូន៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ស្ថានទូតវៀតណាមនៅកម្ពុជា
- ឯកសារកាលប្បវត្តិ

# ឧបសម្ព័ន្ធ ១/២៖ លិខិតក្លែងបន្លំ ចុះថ្ងៃ ៥ សីហា ឆ្នាំ ២០១២ ជូនដំណឹង អំពី មរណភាព របស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា



**សម្តេចព្រះពោធិសាល ជា ស៊ីម**

## ដំណឹងមរណៈទុក្ខ

ភ្នំពេញថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១២

យើងខ្ញុំជាកូន ចៅ និងចៅទួត មានការសោកស្តាយ និងទុក្ខយ៉ាងក្រៀមក្រំ ដោយលោកឪពុក ឪពុកក្មេក ជីតា និងតាទួត នាម **សម្តេចព្រះពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលមរណៈភាពកាលពីរាត្រីថ្ងៃសៅរ៍ ទី០៩ ខែសីហា ឆ្នាំ២០១២ កន្លងមកនេះ បន្ទាប់ពីត្រឡប់មកពីព្យាបាលនៅប្រទេសសាំងហ្គាពួ ។

ការស្លាប់បង់នូវអាយុជីវិតរបស់ សម្តេច គឺជាការបាត់បង់ដ៏ធំធេងនូវលោកឪពុក ឪពុកក្មេក ជីតា និងតាទួត របស់យើងខ្ញុំ ជាពិសេសគឺការបាត់បង់នូវវីរៈបុរសដែលបានលះបង់គ្រប់បែបយ៉ាងដើម្បីបុព្វហេតុជាតិ និងប្រជាពលរដ្ឋខ្មែរ ។

ដោយបំណាច់នៃអំពើល្អរបស់សម្តេច យើងខ្ញុំសូមបួងសួងដល់ទេវតាបារមីនៃវត្ថុសក្តិសិទ្ធិក្នុងលោក គុណព្រះរតនត្រ័យទាំងបីសូមជួយថែរក្សាការពារសម្តេច សូមឲ្យសម្តេចបានទៅកាន់សុគតិភពកុំបីអាក់ខានឡើយ ។

ដំណឹងនេះចាត់ទុកជាការអញ្ជើញ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ ព្រមទាំងបងប្អូន ញាតិមិត្តជិតឆ្ងាយនៃសព ៕

ពត៌មានបន្ថែមសូមទំនាក់ទំនង

ទូរស័ព្ទលេខ ០៧៧៩០៣៥០៦

# ឧបសម្ព័ន្ធ ១/៣៖ លិខិតក្លែងបន្លំ ចុះថ្ងៃ ៥ សីហា ឆ្នាំ ២០១២ ធ្វើជាលិខិតរបស់ សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា
លេខ ......... រ.ស.

**គោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

*សូមសម្តេចមេត្តាជ្រាប*

**កម្មវត្ថុ៖** លិខិតរបស់សម្តេចចុះថ្ងៃទី០៥ខែសីហាឆ្នាំ២០១២ ជម្រាបជូនអគ្គលេខាធិការដ្ឋានរដ្ឋសភាជាតិ ធ្វើជូនជនរួមជាតិកម្ពុជាទាក់ទងការឡើងបកស្រាយបញ្ហាព្រំដែនរបស់សម្តេចនៅថ្ងៃទី០៥ខែសីហា ឆ្នាំ២០១២។

យោងសេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយស សូមជម្រាបជូនសម្តេច បានជ្រាបថា លិខិតរបស់សម្តេចធ្វើជូនជនរួមជាតិ មិនអាចផ្សព្វផ្សាយទៅបានទេ។ ព្រោះការផ្សព្វផ្សាយលិខិតនេះនឹងធ្វើឲ្យប្រជាជនកើនឡើងប្រឆាំងនឹងរដ្ឋាភិបាល គណបក្សប្រឆាំងនឹងកេងយកចំណេញ និងទីបំផុតធ្វើឲ្យគណបក្សប្រជាជនរបស់យើងបាត់បង់ការគាំទ្រ។ លើសពីនេះអាចធ្វើឲ្យមានទំនាស់ជាមួយប្រទេសវៀតណាមជាមិត្តនិងជាអ្នកមានគុណរបស់ប្រជាជនកម្ពុជាថែមទៀត។

ដូច្នេះសូមសម្តេច មេត្តាដកការផ្សព្វផ្សាយលិខិតនេះជាបន្ទាន់ដើម្បីបុព្វហេតុគណបក្សប្រជាជនកម្ពុជា ប្រទេសកម្ពុជា និងមិត្តភាពយូរអង្វែងនៃប្រទេសទាំងពីរ កម្ពុជា វៀតណាម។ ចំពោះរឿងបញ្ហាមិនឆាយដេញដោល ក្នុងពេលសម្តេចឡើងបកស្រាយ រដ្ឋសភាជាតិនឹងប្រើប្រាស់ បទបញ្ជាផ្ទៃក្នុង និងនីតិវិធីរបស់ខ្លួនដើម្បីទប់ស្កាត់ការចោទសួរណាមួយពីបក្សប្រឆាំងដែលគិតថា ប្រកាន់ផលប្រយោជន៍របស់បក្សប្រជាជនកម្ពុជា និងស្មុគស្មាញប្រទេសជាតិបានដោយស្របច្បាប់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសម្តេចជ្រាប និងចាត់ការជាបន្ទាន់តាមការគួរ។
សូមសម្តេចមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គណបក្សប្រជាជនកម្ពុជា
- ខុទ្ទកាល័យសម្តេចហេង សំរិន
- ស្ថានទូតវៀតណាមនៅកម្ពុជា
- ឯកសារកាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១២
**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

វិមានរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (855-23) 213 535, 220 628 ទូរសារ: (855-23)220 629
សារអេឡិចត្រូនិច: sg@national-assembly.org.kh
គេហទំព័រ www.national-assembly.org.kh

## ឧបសម្ព័ន្ធ ២/១៖ ផែនទីមណ្ឌលរដ្ឋបាលតៃនីញ បង្ហាញទីតាំង បង្គោលព្រំដែនពីលេខ ០១-៣៣ រវាងកម្ពុជា-កូសាំងស៊ីន



# ឧបសម្ព័ន្ធ ២/២៖ ផែនទីមណ្ឌលរដ្ឋបាលតាន់ អាន បង្ហាញទីតាំង បង្គោលព្រំដែនពីលេខ ៣៤-៦០ រវាងកម្ពុជា-កូសាំងស៊ីន



## ឧបសម្ព័ន្ធ ២/៣៖ ផែនទីមណ្ឌលរដ្ឋបាលចូវ ដុក បង្ហាញទីតាំង បង្គោលព្រំដែនពីលេខ ៦០-១២៤ រវាងកម្ពុជា-កូសាំងស៊ីន



# ឧបសម្ព័ន្ធ ២/៤៖ ផែនទី បង្ហាញពីគ្រឹះបង្គោលសេសសល់ ក្នុងមណ្ឌលរដ្ឋបាលចូវ ដុក



## ឧបសម្ព័ន្ធ ២/៥៖ រូបភាពបង្គោលព្រំដែនរវាងកម្ពុជា-កូសាំងស៊ីន បោះនៅទសវត្សរ៍ ឆ្នាំ១៨៦០-១៨៧០





ឧបសម្ព័ន្ធ ២/៦៖ រូបភាពបង្គោលព្រំដែនរវាងកម្ពុជា-កូសាំងស៊ីន
បោះនៅទសវត្សរ៍ ឆ្នាំ១៨៦០-១៨៧០



## ឧបសម្ព័ន្ធ ៣/១៖ ផែនទីព្រំដែនគោក តម្កល់នៅ អ.ស.ប ឆ្នាំ១៩៦៤



# ឧបសម្ព័ន្ធ ៣/២៖ ផែនទីព្រំដែនគោក តម្កល់នៅ អ.ស.ប ឆ្នាំ១៩៦៤



# ឧបសម្ព័ន្ធ ៤៖ សេចក្ដីប្រកាសព័ត៌មាន

*(បកប្រែក្រៅផ្លូវការ)*

**សេចក្ដីប្រកាសព័ត៌មាន**

ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ១៩៩៥

រវាង

នាយករដ្ឋមន្ត្រីវៀតណាម

និង

នាយករដ្ឋមន្ត្រីកម្ពុជា

**៨.** ភាគីទាំងពីរបញ្ជាក់សារជាថ្មីពីឆន្ទៈរបស់ខ្លួនក្នុងការកសាងព្រំដែនរវាងប្រទេសទាំងពីរឲ្យក្លាយទៅជាព្រំដែនសន្តិភាព មិត្តភាព និងស្ថេរភាព ដើម្បីចូលរួមក្នុងការអភិវឌ្ឍ និងកិច្ចសហប្រតិបត្តិការ និងភាពអ្នកជិតខាងល្អ រវាងប្រទេសទាំងពីរ ។ ដោយរង់ចាំដំណោះស្រាយលើបញ្ហាព្រំដែនដ៏សំខាន់នេះ ភាគីទាំងពីរឯកភាពរក្សាស្ថានភាពការគ្រប់គ្រងបច្ចុប្បន្ន ដោយមិនឲ្យមានការផ្លាស់ប្ដូរ ឬរំកិលបង្គោលព្រំដែន និងអប់រំប្រជាជន ដោយហាមប្រាមពួកគាត់មិនឲ្យធ្វើស្រែចំការ ឬតាំងទីលំនៅឆ្លងកាត់ព្រំដែន និងសហការគ្នារក្សាបាននូវព្រំដែនសុវត្ថិភាព និងសណ្ដាប់ធ្នាប់ ។

# ឧបសម្ព័ន្ធ ៥៖ ផែនទី ខ្សែប្រេវីយេ ឆ្នាំ១៩៣៩
# តម្កល់នៅ អ.ស.ប



# ឧបសម្ព័ន្ធ ៦៖ ខ្សែវៀតណាមខាងត្បូង ឆ្នាំ១៩៧១



# ឧបសម្ព័ន្ធ ៧/១៖ ផែនទីតាមក្រឹត្យសាធារណរដ្ឋ ឆ្នាំ១៩៧២



# ឧបសម្ព័ន្ធ ៧/២៖ ខ្សែសាធារណរដ្ឋខ្មែរ ឆ្នាំ១៩៧២



# ឧបសម្ព័ន្ធ ៨/១៖ ផែនទី តំបន់ទឹកប្រវត្តិសាស្ត្រ ឆ្នាំ១៩៨២



# ឧបសម្ព័ន្ធ ៨/២៖ គំនូសផែនទីភ្ជាប់ជាមួយក្រឹត្យលេខ ១ក្រ ចុះថ្ងៃទី៣១/៧/១៩៨២



# ឧបសម្ព័ន្ធ ៨/៣៖ ខ្សែសមចម្ងាយដែលវៀតណាមទាមទារ



# ឧបសម្ព័ន្ធ ៩៖ ផែនទីព្រះរាជាណាចក្រកម្ពុជា
# ទំហំផ្ទៃ ១៨១ ៤៣៦ គីឡូម៉ែត្រក្រឡា



ឧបសម្ព័ន្ធ ១០/១៖ ឧបករណ៍ប្រើប្រាស់ក្នុងការវាស់វែងព្រំដែន

ឧបករណ៍ប្រើប្រាស់ក្នុងការវាស់វែងព្រំដែន :

- GPS Garmin 76Csx
- Total Station Leica- TPS1200
- Total Station Topcon GTS-N100
- Total Station Sokia
- GPS Dual Frequcy Leica- 1200

## ឧបសម្ព័ន្ធ ១០/២៖ ឧបករណ៍វាស់វែងពីផ្កាយរណប

GPS Dual Frequency Leica-1200



## ឧបសម្ព័ន្ធ ១០/៣៖ ឧបករណ៍វាស់វែងពីផ្កាយរណប

GPS Dual Frequency





## ឧបសម្ព័ន្ធ ១០/៤៖ តម្លើងបង្គោលតម្រង់ទិស ដើម្បីវាស់វែង ដោយប្រើឧបករណ៍ Total Station



# ឧបសម្ព័ន្ធ ១០/៥៖ បណ្តាញវាស់វែងប្រចពីវិភាគ ដើម្បីកំណត់ទិន្នន័យ មូលដ្ឋានរួមរវាងកម្ពុជា-វៀតណាម ដោយភ្ជាប់ជាមួយបណ្តារប្រទេស ក្នុងតំបន់អាស៊ីប៉ាស៊ីភិច ឧបករណ៍ GPS Dual Frequency

## Network Adjustment Report

*Project : Cambodia*

| | | | |
|---|---|---|---|
| User name | Mr. SIN SOTHEANY | Date & Time | 10/28/2009 |
| Coordinate System | UTM | Zone | 48 North |
| Project Datum | ITRF2000 | | |
| Vertical Datum | | Geoid Model | EGM96 (Global) |
| Coordinate Units | Meters | | |
| Distance Units | Meters | | |
| Height Units | Meters | | |

Adjustment I

### Adjusted Coordinates

Adjustment performed in ITRF2000

Number of Points : 14
Number of Constrained Points : 3
Horizontal and Height Only : 3

Adjusted Grid Coordinates Errors are reported using 1.96σ.

| Point Name | Northing | N error | Easting | E error | Elevation | e error |
|---|---|---|---|---|---|---|
| N-11 | 1378939.941m | 0.008m | 736839.907m | 0.008m | 700.378 | N/A |
| N16 | 1519708.935m | 0.006m | 714655.888m | 0.007m | 315.060 | N/A |
| N-21 | 1213406.023m | 0.002m | 477047.778m | 0.003m | 6.336 | N/A |
| PENH | 1279428.548m | 0.000m | 491013.771m | 0.000m | N/A | N/A |
| 301 | 1306372.900m | 0.005m | 629903.321m | 0.005m | 87.942 | N/A |
| STUE | 1490014.008m | 0.000m | 605070.839m | 0.000m | N/A | N/A |
| NT04 | 1137764.332m | 0.004m | 449907.651m | 0.004m | N/A | N/A |
| Siha | 1173319.045m | 0.000m | 338477.631m | 0.000m | N/A | N/A |
| KT-A | 1589133.218m | 0.010m | 825575.570m | 0.012m | 542.839 | N/A |
| QT03 | 1779873.374m | 0.013m | 844578.897m | 0.016m | N/A | N/A |
| DL-B | 1403920.291m | 0.012m | 829318.023m | 0.013m | 451.090 | N/A |
| BP-C | 1275911.504m | 0.007m | 703707.318m | 0.007m | 93.453 | N/A |
| QT04 | 1145179.178m | 0.010m | 728490.995m | 0.010m | N/A | N/A |
| LA-D | 1189842.923m | 0.005m | 602242.746m | 0.005m | 3.9380 | N/A |



ឧបសម្ព័ន្ធ ១១/១៖ ការរុករកវត្ថុធាតុគោល-វត្ថុសម្គាល់ ឬវត្ថុយោង
នៅលើដីជាក់ស្តែង ដូចជា វត្តអារាម សាលារៀន ស្ទឹង ព្រៃក
សញ្ញាសំគាល់...





## ឧបសម្ព័ន្ធ ១១/២៖ ការរុករកវត្ថុធាតុគោល-វត្ថុសម្គាល់ ឬវត្ថុយោង នៅលើដីជាក់ស្តែង ដូចជា វត្តអារាម សាលារៀន ស្ទឹង ព្រៃក សញ្ញាសំគាល់...





## ឧបសម្ព័ន្ធ ១១/៣៖ ការរុករកវត្ថុធាតុគោល-វត្ថុសម្គាល់ ឬវត្ថុយោង នៅលើដីជាក់ស្តែង ដូចជា វត្តអារាម សាលារៀន ស្ទឹង ព្រៃក សញ្ញាសំគាល់...






# ឧបសម្ព័ន្ធ ១២/១៖ ផែនទី BONNE តំបន់ភូមិអន្លង់ជ្រៃ និងភូមិថ្លុកត្រាច ខេត្តកំពង់ចាម



# ឧបសម្ព័ន្ធ ១២/២៖ ផែនទី UTM តំបន់ភូមិអន្លង់ជ្រៃ ខេត្តកំពង់ចាម



# ឧបសម្ព័ន្ធ ១២/៣៖ ផែនទីរូបថតពីលើអាកាស បង្ហាញដីតំបន់ ភូមិអន្លង់ជ្រៃ និងថ្លុកក្រោច ខេត្តកំពង់ចាម



ឧបសម្ព័ន្ធ ១៣/១៖ ផែនទីបង្ហាញទីតាំងបង្គោលព្រំដែនស្ថិតនៅតាមបណ្តោយព្រំដែនរវាងខេត្តកំពង់ចាម (កម្ពុជា) និងខេត្តតៃនិញ ប៊ិញភឿក (វៀតណាម) និងលទ្ធផលបោះបង្គោលព្រំដែន ក្នុងឆ្នាំ២០១០



## ឧបសម្ព័ន្ធ ១៣/២៖ ផែនទីបង្ហាញទីតាំង និងលទ្ធផលបោះបង្គោល ខ័ណ្ឌសីមាព្រំដែន តាមបណ្តោយព្រំដែនរវាងខេត្ត ស្វាយរៀង (កម្ពុជា) និង ឡុងអាន តៃនិញ (វៀតណាម)



## ឧបសម្ព័ន្ធ ១៣/៣៖ ផែនទីបង្ហាញទីតាំងបង្គោលព្រំដែនស្ថិតនៅតាមបណ្ដោយព្រំដែនរវាងខេត្ត ព្រៃវែង(កម្ពុជា) និង ដុងថាប់(វៀតណាម) និង លទ្ធផលការងារក្នុងឆ្នាំ ២០១០ របស់ក្រុមបច្ចេកទេសចម្រុះ ខ.ស.ប.ប.ព ក្នុងកំណាត់ខេត្តព្រៃវែង



# ឧបសម្ព័ន្ធ ១៣/៤៖ ផែនទីបង្ហាញលទ្ធផលការងារបោះបង្គោល និង ខណ្ឌសីមាព្រំដែនរវាងកម្ពុជា-វៀតណាម ក្នុងកំណាត់ខេត្តតាកែវ និង កំពត និងទីតាំងដែលត្រូវធ្វើការដោះស្រាយបន្ត



# ឧបសម្ព័ន្ធ ១៤/១៖

**ព្រះករុណាព្រះបាទសម្តេច**
**ព្រះនរោត្តម សីហនុ**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

**ឯកឧត្តម ផាំ វ៉ាន់ដុង ជាទីស្រឡាញ់រាប់អានដ៏ខ្ពង់ខ្ពស់បំផុត**

ខ្ញុំមានបីតិសោមនស្សរីករាយ និងមហាកិត្តិយសប្រកបដោយមនោសញ្ចេតនារលឹករឭក និងផ្ញើព្រះរាជសារលិខិតមួយនេះ ដើម្បីជម្រាបសួរសុខទុក្ខឯកឧត្តមដែលជាមហាមិត្តដ៏ឧត្តុង្គឧត្តមរបស់ខ្ញុំ ក៏ដូចជារបស់ប្រជាជនកម្ពុជាគ្រប់រូប ។

ក្នុងឱកាសដ៏កម្រនេះ ខ្ញុំសូមសម្តែងនូវមហាករុណាធិគុណដ៏ជ្រាលជ្រៅ ចំពោះមនោសញ្ចេតនាមិត្តភាពដ៏ស្មោះស្ម័គ្រ និងសាមគ្គីភាព ដែលឯកឧត្តមតែងបានផ្តល់ចំពោះរូបខ្ញុំក៏ ដូចជាចំពោះប្រជាជនកម្ពុជាក្នុងរយៈកាលកន្លងមក ដែលយើងនិងប្រជាជនយើងទាំងពីរតែងតែរួបរួមកម្លាំងគ្នាជួយគ្នាទៅវិញទៅមក ប្រកៀកស្មាគ្នាតស៊ូរំដោះប្រទេសជាតិពីសត្រូវរួម រហូតបានជោគជ័យរៀង១ខ្លួនដល់សព្វថ្ងៃនេះ។ សន្និសីទកំពូលប្រជាជនឥណ្ឌូចិននៅទីក្រុងភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ១៩៦៥ និងទីក្រុងកង់តុង ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ១៩៧០ ការចរចារវាងខ្ញុំ និងឯកឧត្តមផ្ទាល់នៅទីក្រុងប៉េកាំងនាឆ្នាំ ១៩៦៤ និងការជួបគ្នាជាបន្តបន្ទាប់មកទៀត ក៏ដូចជាសេចក្តីថ្លែងការណ៍របស់រណសិរ្សជាតិរំដោះវៀតណាមខាងត្បូង និងសេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម ដែលឯកឧត្តមជាប្រមុខ នាឆ្នាំ១៩៦៧ សុទ្ធតែបានបញ្ជាក់ពីចំណងមិត្តភាព យុទ្ធសាមគ្គីភាព ព្រមទាំងការទទួលស្គាល់ព្រំដែនបច្ចុប្បន្នរបស់កម្ពុជា និងគោរពអធិបតេយ្យ បូរណភាពទឹកដី

## ឧបសម្ព័ន្ធ ១៤/២៖

គ្នាទៅវិញទៅមក។ រាល់ប្រសាសន៍ប្រកបដោយខ្លឹមសាររបស់ឯកឧត្តម ក្នុងឱកាសជួបប្រាស្រ័យជាមួយខ្ញុំកន្លងមកតែងតែធ្វើឱ្យខ្ញុំមានទំនុកចិត្ត និងការកក់ក្ដៅជានិច្ចចំពោះដំណោះស្រាយនានា ដែលទាក់ទងទៅនឹងផលប្រយោជន៍របស់ប្រទេសយើងទាំងពីរ ដែលជាអ្នកភូមិផងរបងជាមួយគ្នាដ៏ល្អ និងស្មោះត្រង់ ។

ឯកឧត្តមជាអ្នកធ្លាប់សិក្សាស្រាវជ្រាវយ៉ាងច្បាស់លាស់ ពីប្រវត្តិសាស្ត្រជូរចត់របស់ប្រទេសកម្ពុជាយើងខ្ញុំ ហើយឯកឧត្តមបានក្លាយទៅជាវីរជនមួយរូប ដែលបានខិតខំពង្រីកពង្រឹង មិត្តភាព យុទ្ធសាមគ្គីភាពជាមួយប្រទេសទាំងបី នៅក្នុងជ្រោយឥណ្ឌូចិនយើងនេះ តស៊ូរំដោះប្រទេសជាតិបានជោគជ័យជាស្ថាពរ ហើយកំពុងកសាងប្រទេសតាមវិទ្យាសាស្ត្របច្ចេកទេសទំនើបថ្មីដើម្បីឈានទៅរកវឌ្ឍនភាព និងសុភមង្គល ឯកឧត្តមគង់យល់ច្បាស់ អំពីភាពចាំបាច់ដែលប្រទេសយើងទាំងពីរត្រូវមានខ្សែព្រំដែនមួយសមភាពយុត្តិធម៌ និងមានផលប្រយោជន៍ទាំងសងខាង។ ជំហរនេះហើយដែលខ្ញុំសង្កេតឃើញថាអ្នកដឹកនាំរដ្ឋាភិបាលយើងទាំងពីរកំពុងយកចិត្តទុកដាក់ចរចារកដំណោះស្រាយបញ្ហាព្រំដែនដើម្បីកសាងខ្សែព្រំដែនមួយឱ្យក្លាយទៅជាខ្សែព្រំដែនសន្តិភាព សន្តិសុខ-ស្ថិរភាព-មិត្តភាព និងសហប្រតិបត្តិការ។ ឆ្លៀតឱកាសនេះដែរ ខ្ញុំក៏សូមកោតសរសើរ និងគាំទ្រដោយស្មោះចំពោះជំហរដ៏មុឹងម៉ាត់ ប្រកបដោយសុឆន្ទៈរបស់ឯកឧត្តមអគ្គលេខាធិការគណបក្សកុម្មុយ-នីស្តវៀតណាម **ឡេ ខា ភៀវ** ក្នុងឱកាសទស្សនកិច្ចនៅកម្ពុជាថ្មីៗនេះ ដែលចង់ឱ្យបញ្ហាព្រំដែននៃប្រទេសយើងទាំងពីរត្រូវបានដោះស្រាយចប់មុនដំណាច់ឆ្នាំ ២០០០ នេះ ។

ក៏ប៉ុន្តែក្នុងដំណើរការចរចានានា ដើម្បីកំណត់ព្រំដែនសមុទ្រនៃប្រទេសយើងទាំងពីរនោះ ខ្ញុំបានទទួលរបាយការណ៍ថា នៅមានការខ្វែងគំនិតគ្នានៅឡើយដែលចាំបាច់ខ្ញុំយល់ថាមានតែឯកឧត្តមដែលជាមហាមិត្តរបស់ខ្ញុំទេ ដែលលោកមានការយោគយល់បញ្ហា ហើយអាចជួយតម្រង់ទិសឱ្យគណៈកម្មការចម្រុះកិច្ចការព្រំដែនប្រទេសយើងទាំងពីរ មានពន្លឺក្នុង

# ឧបសម្ព័ន្ធ ១៤/៣៖

ការស្វែងរកដំណោះស្រាយមួយសមហេតុសមផល ស្របតាមផលប្រយោជន៍របស់ប្រជាជនយើងទាំងពីរ ។

ឯកឧត្តម ជាទីរាប់អានដ៏ខ្ពង់ខ្ពស់បំផុត

ក្នុងប្រវត្តិសាស្ត្រកម្ពុជា ទឹកដីកម្ពុជាក្រោមទាំងមូលបានបាត់បង់រួចទៅហើយ បន្ទាប់មកកោះត្រល់ដែលវៀតណាមឱ្យឈ្មោះថា ហ្វ៊ូ កុក និងកោះមួយចំនួនដែលស្ថិតនៅខាងត្បូងខ្សែបន្ទាត់ ប្រេវីយេ ក៏បន្តបាត់ទៀតដោយសារសារាចររបស់លោកអគ្គទេសាភិបាលបារាំងថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៣៩ ។ ម្យ៉ាងវិញទៀត កាលពីឆ្នាំ ១៩៦៤ រាជរដ្ឋាភិបាលកម្ពុជាពេលនោះ បានយកផែនទីមួយដែលបោះពុម្ពដោយក្រុមភូមិសាស្ត្រកម្ពុជា ផ្អែកតាមផែនទីបារាំងរបស់ Service Hydrographique ខ្នាត ១/៣00.000 ភ្ជាប់ជាមួយផែនទីដីគោកទៅឱ្យអន្តរជាតិទទួលស្គាល់ និងបានតម្កល់ទុកនៅអង្គការសហប្រជាជាតិនោះ គឺយើងបានគូសខ្សែប្រេវីយេ ជាព្រំដែនសមុទ្រជាមួយវៀតណាមផងដែរ ។ផែនទី និងឯកសារទាំងអស់នោះហើយ ដែលអតីតរាជរដ្ឋាភិបាលរបស់ខ្ញុំ អតីតរាជរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា រដ្ឋកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន កំណត់ថាជាព្រំដែនបច្ចុប្បន្នរបស់កម្ពុជា។ ដូច្នេះហើយ ខ្ញុំយល់ឃើញថា សម័យកាលបច្ចុប្បន្ននេះ ដែលសកលលោកទាំងមូលកំពុង ស្វែងរកការសម្របសម្រួលអំពីព្រំដែន យើងគួរយកខ្សែប្រេវីយេនេះ ដើម្បីខ័ណ្ឌព្រំសីមា ដែនសមុទ្ររបស់ប្រទេសយើងទាំងពីរ ដើម្បីទុកឱ្យកូនចៅយើងជំនាន់ក្រោយទទួលបាននូវមរតកមួយដ៏ច្បាស់លាស់សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍន៍ប្រទេសរៀង១ខ្លួន។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងនូវក្តីសង្ឃឹមជឿជាក់ថា ប្រទេសយើងទាំងពីរនឹងបន្តអនុវត្តគុំរូវីរភាពរបស់យុទ្ធជន យុទ្ធនារីយើង ដើម្បីរក្សាមិត្តភាព សាមគ្គីភាព សហប្រតិបត្តិការដ៏យូរលង់រវាងប្រជាជន និងប្រជាជាតិយើងទាំងពីរ ខិតខំកសាងខ្សែព្រំដែនគោក

## ឧបសម្ព័ន្ធ ១៤/៤៖

និងសមុទ្រឱ្យបានទៅជាខ្សែព្រំដែនមួយសន្តិភាព សន្តិសុខ ស្ថិរភាព មិត្តភាព និងសហប្រតិបត្តិការឱ្យបានមុនឆ្នាំ ២០០០ ស្របតាមបំណងប្រាថ្នារបស់ប្រជាជនយើងទាំងពីរ ។

សូមឯកឧត្តមទទួលនូវការនឹករលឹក និងការរាប់អានប្រកបដោយមនោសញ្ចេតនាជាភាតរៈដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

ឧបសម្ព័ន្ធ ១៥/១៖ រូបភាព បង្គោលព្រំដែនប្រភេទ A បោះនៅច្រកទ្វារអន្តរជាតិ ( លក-កំពត )



ឧបសម្ព័ន្ធ ១៥/២៖ រូបភាព បង្គោលព្រំដែនប្រភេទ B បោះនៅច្រក
ទ្វេភាគី (កំពង់ចាម)



## ឧបសម្ព័ន្ធ ១៥/៣៖ រូបភាព បង្គោលព្រំដែនប្រភេទ C បោះនៅច្រកតំបន់ និងនៅតំបន់លិចទឹក



## ឧបសម្ព័ន្ធ ១៥/៤៖ បង្គោលព្រំដែនលេខ (០) នៅព្រំដែន ៣ ប្រទេសកម្ពុជា-ឡាវ-វៀតណាម



ចងក្រងដោយ
ក្រុម ព្រឹត្តិប័ត្រ និងបោះពុម្ពផ្សាយ **កម្ពុជាទស្សនៈថ្មី**
ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ